សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ប្រព័ន្ធដោះស្រាយវិវាទពាណិជ្ជកម្មអន្តរជាតិរបស់អង្គការពាណិជ្ជកម្មពិភពលោក

ស្រាវជ្រាវពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៥

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ពេជ្រ សុផានី**

សាស្ត្រាចារ្យណែនាំ
លោក **ឃីម គិរី**

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ
ជំនាន់ទី ២០ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១១
ឆ្នាំសរសេរសារណា ២០១៥

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ពេជ្រ សុផានី** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ជំនាន់ទី២០ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១១-២០១៥។

សូមសម្តែងនូវសេចក្តីគោរព និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ៖

លោកឪពុក **បឹង ពេជ្រ** និងអ្នកម្តាយ **មុត សារ៉ាត់** ដែលលោកអ្នកមានគុណទាំងពីរ បានផ្តល់កំណើត ព្រមទាំងចិញ្ចឹមបីបាច់ថែរក្សា ផ្គត់ផ្គង់ និងអប់រំរូបកូនទាំងពីតូចរហូតដល់ធំពេញវ័យ និងក្លាយជាសិស្សល្អ និងពលរដ្ឋល្អនៅក្នុងសង្គម។ ប្រសិនបើមិនមានការគាំទ្រយ៉ាងពេញទំហឹងទាំងផ្នែកសម្ភារៈ និងផ្នែកស្មារតីពីសំណាក់រូបលោកទាំងពីរទេ រូបកូនក៏មិនអាចដើរមកដល់ថ្ងៃនេះដែរ។ លើសពីនេះទៀត អាស្រ័យដោយមានការគាំទ្ររបស់លោក ទើបធ្វើអោយកូនតែងតែទទួលបាននូវភាពជោគជ័យនៅក្នុងគ្រប់ភារកិច្ច ជាពិសេសការសិក្សារហូតអាចសម្រេចកិច្ចការសារណានេះ។

បងស្រីបង្កើត **ពេជ្រ ធាវី** និងសាច់ញាតិរបស់ខ្ញុំបាទនៅឯស្រុកកំណើត ដែលលោកទាំងអស់គ្នាតែងតែជួយជំរុញ និងផ្គត់ផ្គង់ដល់ការសិក្សារបស់ខ្ញុំនៅភ្នំពេញរហូតទទួលបានជោគជ័យ។

**ឯកឧត្តមសាកលវិទ្យាធិការ គណៈគ្រប់គ្រងសាកលវិទ្យាល័យ លោក លោកស្រីសាស្ត្រាចារ្យ ការិយាល័យស្រាវជ្រាវ និងបុគ្គលិកសិក្សា**នៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានជួយសម្រួលដល់កិច្ចការរបស់ខ្ញុំបាទ។

លោកសាស្ត្រាចារ្យ **ឃឹម គិរី** ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ព្រមទាំងកម្លាំងកាយ កម្លាំងចិត្ត ក្នុងការណែនាំ ពិនិត្យ កែសម្រួល និងកែប្រែកំហុសឆ្គងកិច្ចការសារណានេះ ថែមទាំងចង្អុលបង្ហាញនូវប្រភពឯកសារ និងព័ត៌មាននានាដែលទាក់ទងនឹងប្រធានបទសារណា រហូតដល់ខ្ញុំអាចចងក្រងបានស្នាដៃសារណាមួយនេះឡើង។

រូបខ្ញុំបាទមិនអាចបំភ្លេចបានឡើយនូវគុណូបការៈដ៏ថ្លៃថ្លាទាំងនេះ ហើយសូមធ្វើការគោរពលំអោនកាយវាចាចិត្ត សម្តែងនូវការដឹងគុណ និងសូមប្រសិទ្ធិពរជ័យ បួងសួងដល់គុណព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិក្នុងលោក អោយតាមជួយថែរក្សាលោកទាំងអស់គ្នា និងសូមអោយជួបនិងពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈកុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ជាការពិត ក្នុងអំឡុងទសវត្សចុងក្រោយនេះ កម្ពុជាបាននឹងកំពុងកែប្រែមុខមាត់ថ្មីក្នុងឆាកអន្តរជាតិ តាមរយៈការផ្សារភ្ជាប់ទំនាក់ទំនងជាមួយនឹងប្រទេសនានានៅក្នុងសកលលោក និងការចូលរួមជាសមាជិកនៃអង្គការអន្តរជាតិសំខាន់ៗ ដែលក្នុងនោះក៏មានអង្គការពាណិជ្ជកម្មពិភពលោកផងដែរ ដែលកម្ពុជាបានចូលជាសមាជិកនៅថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០០៤។ ការចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក ធ្វើឲ្យសកម្មភាពពាណិជ្ជកម្មរបស់កម្ពុជាដែលពីមុនធ្លាប់តែមានភាពទន់ខ្សោយ បែរជាមកចាប់ផ្តើមដំណើរការល្អប្រសើរបន្តិចម្តងៗ ដោយកម្ពុជាអាចធ្វើពាណិជ្ជកម្មយ៉ាងទូលំទូលាយក្នុងក្របខណ្ឌអង្គការពាណិជ្ជកម្មពិភពលោក និងដោយមានការអនុគ្រោះលើផ្នែកពាណិជ្ជកម្មច្រើនពីសំណាក់ប្រទេសមួយចំនួនដែលជាសមាជិករបស់អង្គការ។

ក៏ប៉ុន្តែ ដោយសារថាប្រទេសកម្ពុជាយើង ជាប្រទេសមានការអភិវឌ្ឍន៍តិចតួចនៅឡើយ ដូច្នេះហើយការយល់ដឹងពីបញ្ហាច្បាប់នានានៅក្នុងអង្គការ អាចថានៅមានកម្រិតនៅឡើយ ជាក់ស្តែងដូចជា ការស្វែងយល់ពីការដោះស្រាយវិវាទពាណិជ្ជកម្មអន្តរជាតិរបស់រដ្ឋជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកជាដើម។ បញ្ហានេះអាចផ្តល់ផលមិនល្អដល់កម្ពុជា ក្នុងការការពារនូវសិទ្ធិ និងផលប្រយោជន៍របស់ខ្លួន ក្នុងករណីកម្ពុជាមានវិវាទពាណិជ្ជកម្មជាមួយសមាជិកដទៃទៀត។

យោងលើកត្តាទាំងនេះហើយ ទើបខ្ញុំសម្រេចជ្រើសរើសយកប្រធានបទ "ប្រព័ន្ធដោះស្រាយវិវាទពាណិជ្ជកម្មអន្តរជាតិរបស់អង្គការពាណិជ្ជកម្មពិភពលោក" ធ្វើជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះ។ ការចងក្រងសារណានេះ ខ្ញុំបាទពឹងផ្អែកលើប្រភពឯកសារជាភាសាបរទេសភាគច្រើន ដោយហេតុថាមានកង្វះខាតនូវឯកសារជាភាសាខ្មែរ។

សង្ឃឹមថា សារណានេះនឹងក្លាយជាការរួមចំណែកដល់ការយល់ដឹងលើផ្នែកនីតិអន្តរជាតិ ជាពិសេសយន្តការដោះស្រាយវិវាទពាក់ព័ន្ធនឹងអង្គការពាណិជ្ជកម្មពិភពលោកបន្ថែមទៀត ហើយក៏រំពឹងថាវានឹងអាចក្លាយជាទុនមួយសម្រាប់និស្សិត និងមិត្តអ្នកអានក្នុងការសិក្សាស្រាវជ្រាវលើផ្នែកមួយនេះ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំជឿថាស្នាដៃនេះនៅមានចំណុចខ្វះខាត ហើយខ្ញុំសូមស្វាគមន៍ជានិច្ចចំពោះការរិះគន់ក្នុងន័យស្ថាបនា។

# មាតិកា

សេចក្តីថ្លែងអំណរគុណ

អារម្ភកថា

តារាងសម្គាល់អក្សរកាត់

សេចក្តីផ្តើម ........ 1

ជំពូកទី១ សញ្ញាណទូទៅអំពីប្រព័ន្ធដោះស្រាយវិវាទពាណិជ្ជកម្មអន្តរជាតិរបស់អង្គការពាណិជ្ជកម្មពិភពលោក ........ 3

១.១. អំពីអង្គការពាណិជ្ជកម្មពិភពលោក ........ 3

១.១.១. តើអង្គការពាណិជ្ជកម្មពិភពលោកជាអ្វី? ........ 3

១.១.២. គោលបំណងរបស់អង្គការ ........ 4

១.១.៣. មុខងាររបស់អង្គការ ........ 5

១.១.៤. រចនាសម្ព័ន្ធរបស់អង្គការ ........ 6

១.១.៤.១. សន្និសីទថ្នាក់រដ្ឋមន្ត្រី ........ 6

១.១.៤.២. អគ្គក្រុមប្រឹក្សា ........ 6

១.១.៤.៣. ក្រុមប្រឹក្សាពាណិជ្ជកម្មលើទំនិញ ........ 7

១.១.៤.៤. ក្រុមប្រឹក្សាពាណិជ្ជកម្មលើសេវាកម្ម ........ 7

១.១.៤.៥. ក្រុមប្រឹក្សាផ្នែកកម្មសិទ្ធិបញ្ញា ........ 7

១.១.៤.៦. អង្គភាពដោះស្រាយវិវាទ ........ 7

១.១.៤.៧. លេខាធិការដ្ឋាន WTO ........ 7

១.១.៤.៨. ស្ថាប័នជំនាញរាយរងផ្សេងៗទៀត ........ 8

១.១.៥. សមាជិកភាព និងការសម្រេចសេចក្តីនៅក្នុងWTO ........ 8

១.២. អំពីប្រវត្តិ និងការវិវត្តន៍នៃប្រព័ន្ធដោះស្រាយវិវាទ ........ 8

១.៣. អំពីមុខងារ កម្មវត្ថុ និងលក្ខណៈសំខាន់ៗរបស់ប្រព័ន្ធដោះស្រាយវិវាទ ........ 11

១.៣.១. មុខងាររបស់ប្រព័ន្ធដោះស្រាយវិវាទ ........ 11

១.៣.១.១. ផ្ដល់សុវត្ថិភាព និងភាពអាចព្យាករណ៍បាន ដល់ប្រព័ន្ធនៃការធ្វើពាណិជ្ជកម្មពហុភាគី 11
១.៣.១.២. ធានាសិទ្ធិ និងកាតព្វកិច្ចរបស់សមាជិកអង្គការពាណិជ្ជកម្មពិភពលោក 12
១.៣.១.៣. បកស្រាយបទបញ្ញត្តិនៅក្នុងកិច្ចព្រមព្រៀងនានា ដែលពាក់ព័ន្ធនឹងកិច្ចការពាណិជ្ជកម្មអន្តរជាតិក្នុង WTO 13
១.៣.២. កម្មវត្ថុនៃប្រព័ន្ធដោះស្រាយវិវាទ 15
១.៣.២.១. ស្វែងរកដំណោះស្រាយដែលមានការព្រមព្រៀងទទួលយកពីសំណាក់ភាគី 15
១.៣.២.២. ការដោះស្រាយវិវាទប្រកបដោយភាពត្រឹមត្រូវ 15
១.៣.២.៣. ហាមឃាត់ការសម្រេចសេចក្ដីដោយឯកតោភាគី 17
១.៣.៣. លក្ខណៈសម្គាល់នៃប្រព័ន្ធដោះស្រាយវិវាទ 18
១.៣.៣.១. យុត្តាធិការផ្ដាច់មុខ 18
១.៣.៣.២. លក្ខណៈចាប់បង្ខំ 18
១.៣.៣.៣. លក្ខខណ្ឌបណ្ដឹងដែលស្ថិតក្នុងសមត្ថកិច្ចរបស់ប្រព័ន្ធដោះស្រាយវិវាទ 19
១.៤. តួអង្គពាក់ព័ន្ធនៅក្នុងប្រព័ន្ធដោះស្រាយវិវាទ 20
១.៤.១. ភាគី 20
១.៤.២.អង្គភាពដោះស្រាយវិវាទ 21
១.៤.២.១. សមាសភាព 21
១.៤.២.២. អំពីប្រធានអង្គភាពដោះស្រាយវិវាទ 21
១.៤.២.៣. តួនាទី និងសិទ្ធិអំណាចរបស់អង្គភាព 22
១.៤.២.៤. ដំណើរការសម្រេចសេចក្ដីក្នុងអង្គភាព 23
១.៤.៣. គណៈវិនិច្ឆ័យ 24
១.៤.៣.១. សមាសភាព 24
១.៤.៣.២. មុខងាររបស់គណៈវិនិច្ឆ័យ 27
១.៤.៤. អង្គភាពឧទ្ធរណ៍ 28
១.៤.៤.១. ប្រវត្តិ និងមូលហេតុនៃការបង្កើតអង្គភាពឧទ្ធរណ៍ 28
១.៤.៤.២. សមាសភាពរបស់អង្គភាពឧទ្ធរណ៍ 29

១.៤.៤.៣. លេខាធិការដ្ឋានអង្គភាពឧទ្ធរណ៍.....29
១.៤.៤.៤. មុខងាររបស់អង្គភាពឧទ្ធរណ៍.....30
១.៤.៥. អគ្គនាយក និងលេខាធិការដ្ឋានអង្គការពាណិជ្ជកម្មពិភពលោក.....30
១.៤.៥.១. អគ្គនាយក.....30
១.៤.៥.២. លេខាធិការដ្ឋាន.....31
១.៤.៦. មជ្ឈត្តករ.....31
១.៤.៧. អ្នកជំនាញ.....33
១.៥. បទដ្ឋានគតិយុត្តសម្រាប់ការដោះស្រាយវិវាទ.....34
១.៥.១. កិច្ចព្រមព្រៀងទីក្រុង Marrakesh ស្តីពីការបង្កើតអង្គការពាណិជ្ជកម្មពិភពលោក.....34
១.៥.២. ឧបសម្ព័ន្ធ ២ ស្តីពីការយល់ដឹងអំពីវិធាន និងនីតិវិធីគ្រប់គ្រងលើការដោះស្រាយវិវាទ.....35
១.៥.៣. កិច្ចព្រមព្រៀងពាណិជ្ជកម្មពហុភាគី និងកិច្ចព្រមព្រៀងពាណិជ្ជកម្មច្រើនភាគី.36
១.៥.៤. កិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្ម និងពន្ធគយ GATT.....36
១.៥.៥. កិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មលើសេវាកម្ម.....36
១.៥.៦. កិច្ចព្រមព្រៀងផ្សេងៗទៀត.....37
ជំពូកទី២ ដំណើរការដោះស្រាយវិវាទរបស់អង្គការពាណិជ្ជកម្មពិភពលោក.....38
២.១. ការប្រឹក្សារវាងភាគី.....38
២.១.១. កម្មវត្ថុនៃការប្រឹក្សា.....38
២.១.២. មូលដ្ឋានច្បាប់ និងលក្ខខណ្ឌដើម្បីស្នើសុំការប្រឹក្សា.....39
២.១.៣. នីតិវិធីនៃការប្រឹក្សា.....40
២.១.៤. ភាគីទីបីនៅក្នុងការប្រឹក្សា.....41
២.២. ការដោះស្រាយវិវាទនៅក្នុងគណៈវិនិច្ឆ័យ.....42
២.២.១. ការចាប់ផ្តើម (ការបង្កើតនូវគណៈវិនិច្ឆ័យ).....43
២.២.២. ការចូលរួមរបស់ភាគីទីបីក្នុងការជំនុំជម្រះនៅគណៈវិនិច្ឆ័យ.....45

២.២.៣. នីតិវិធីក្នុងគណៈវិនិច្ឆ័យ ........................................................................ 46
២.២.៣.១. ការដាក់សំណុំឯកសារ និងការទាញហេតុផលផ្ទាល់មាត់ ........................ 47
២.២.៣.២. ការពិភាក្សារបស់គណៈវិនិច្ឆ័យ ........................................................ 50
២.២.៣.៣. ការរៀបចំនូវសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យ ...................................... 51
២.២.៣.៤. សេចក្តីសម្រេច សេចក្តីសន្និដ្ឋាន អនុសាសន៍ និងការណែនាំលើការអនុវត្ត .. 51
២.២.៣.៥. ការត្រួតពិនិត្យអន្តរកាល Interim Review ............................................. 53
២.២.៣.៦. ការដាក់ចេញនិងការផ្សព្វផ្សាយនូវសេចក្តីសម្រេចចុងក្រោយរបស់គណៈវិនិច្ឆ័យ ........................................................................................................ 54
២.២.៣.៧. ការអនុម័តនូវសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យ ...................................... 54
២.៣. ការជំនុំជម្រះក្តីនៅក្នុងអង្គភាពឧទ្ធរណ៍ ........................................................ 56
២.៣.១. ការដាក់ពាក្យបណ្តឹងឧទ្ធរណ៍ និងលក្ខខណ្ឌបណ្តឹង .................................. 56
២.៣.២. នីតិវិធីនៃការជំនុំជម្រះ .......................................................................... 58
២.៣.៣. អំពីសេចក្តីសម្រេចរបស់អង្គភាពឧទ្ធរណ៍ ................................................ 59
២.៣.៤. ការអនុម័តនូវសេចក្តីសម្រេចរបស់អង្គភាពឧទ្ធរណ៍ ...................................... 59
២.៤. អានុភាពនៃសេចក្តីសម្រេចដែលអនុម័តដោយអង្គភាពដោះស្រាយវិវាទ ....... 61
២.៤.១. ការអនុវត្តតាមសេចក្តីសម្រេចរបស់ភាគី ................................................ 61
២.៤.២. ចំណាត់ការចំពោះការមិនអនុវត្តតាមសេចក្តីសម្រេច ................................ 62
២.៤.២.១. អំពីសំណងការខូចខាត ............................................................... 62
២.៤.២.២. វិធានការតបត(ការព្យួរកាតព្វកិច្ច) ................................................. 63
២.៥. ការអនុគ្រោះពិសេសក្នុងដំណើរការដោះស្រាយវិវាទចំពោះប្រទេសកំពុងអភិវឌ្ឍនិងប្រទេសមានការអភិវឌ្ឍន៍តិចតួចដែលជាប់ពាក់ព័ន្ធក្នុងបញ្ហាវិវាទ .... 63
២.៥.១. ការអនុគ្រោះចំពោះប្រទេសកំពុងអភិវឌ្ឍន៍ .............................................. 64
២.៥.១.១. ការអនុគ្រោះពិសេស និងដាច់ដោយឡែកនៅក្នុងការប្រឹក្សា ........................ 66
២.៥.១.២. ការអនុគ្រោះពិសេស និងដាច់ដោយឡែកនៅក្នុងដំណាក់កាលគណៈវិនិច្ឆ័យ ........................................................................................................ 66
២.៥.១.៣. ការអនុគ្រោះពិសេស និងដាច់ដោយឡែកនៅក្នុងដំណាក់កាលអនុវត្ត ........ 67

២.៥.២. ប្រទេសមានការអភិវឌ្ឍន៍តិចតួចពាក់ព័ន្ធក្នុងជម្លោះ ..................................... 68
២.៦. ចំណុចខ្លាំង និងចំណុចខ្សោយរបស់ប្រព័ន្ធដោះស្រាយវិវាទ ............................. 69
**សេចក្ដីសន្និដ្ឋាន** ..................................................................................................... 71
**អនុសាសន៍** ............................................................................................................. 74
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# តារាងសម្គាល់អក្សរកាត់

WTO : World Trade Orgainzation

DSU : Dispute Settlement Understanding

DSB : Dispute settlement Body

GATT : General Agreement on Tariffs and Trade

GATS : General Agreement on Trade in Services

TRIPS : Trade-Related Aspects of Intellectual Property Rights

TPRIM : Trade Policy Review Machanism

IMF : International Monetary Fund

TBT : Technical Barriers to Trade

SPS : Sanitary and Phytosanitary Measures

# សេចក្តីផ្តើម

ការធ្វើពាណិជ្ជកម្មអន្តរជាតិ មានប្រវត្តិតាំងពីយូរយាណាស់មកហើយនៅក្នុងពិភពលោក ត្បិតថាពាណិជ្ជកម្មជាផ្នែកមួយនៃដង្ហើមសេដ្ឋកិច្ចសម្រាប់ប្រជាជាតិនីមួយៗ និងសកលលោកទាំងមូល។ ក្នុងនោះមានប្រព័ន្ធនៃការធ្វើពាណិជ្ជកម្មអន្តរជាតិសំខាន់ពីរ គឺពាណិជ្ជកម្មអន្តរជាតិក្នុងក្របខណ្ឌកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម ហៅកាត់ថា GATT ឆ្នាំ១៩៤៧ រហូតដល់ជំនួសមកវិញនូវការធ្វើពាណិជ្ជកម្មអន្តរជាតិ ក្នុងក្របខណ្ឌអង្គការពាណិជ្ជកម្មពិភពលោក WTO ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៥។ ប្រព័ន្ធនៃការធ្វើពាណិជ្ជកម្មទាំងពីរនេះ សុទ្ធតែត្រូវបានបង្កើតឡើងដើម្បីផ្តល់នូវស្ថេរភាព សុវត្ថិភាពនៃការធ្វើពាណិជ្ជកម្មអន្តរជាតិ និងផលប្រយោជន៍ទៅវិញទៅមករវាងភាគីនៃការធ្វើពាណិជ្ជកម្ម។

ទន្ទឹមគ្នានឹងសារៈសំខាន់នៃការធ្វើពាណិជ្ជកម្មអន្តរជាតិ ការដោះស្រាយវិវាទពាណិជ្ជកម្ម ក៏ដើរតួនាទីសំខាន់មិនអាចខ្វះបានផងដែរ ត្បិតថាទោះបីជាកិច្ចព្រមព្រៀងអន្តរជាតិមួយត្រូវបានបង្កើតឡើងយ៉ាងល្អប៉ុណ្ណាក៏ដោយ ក៏កិច្ចព្រមព្រៀងនោះនឹងក្លាយជាគ្មានតម្លៃទៅវិញ បើភាគីនៃកិច្ចព្រមព្រៀងនោះមិនអនុវត្តតាម ឬអនុវត្តមិនបានពេញលេញនូវកាតព្វកិច្ចដែលមានចែងក្នុងកិច្ចព្រមព្រៀង។ អ្វីដែលធ្ងន់ធ្ងរជាងនេះទៀតនោះ គឺករណីដែលមិនអាចស្វែងរកនូវដំណោះស្រាយណាមួយចំពោះបញ្ហាការរំលោភបំពានលើកិច្ចព្រមព្រៀងអន្តរជាតិនោះ។ ពាក់ព័ន្ធនឹងបញ្ហានេះ ប្រព័ន្ធនៃការធ្វើពាណិជ្ជកម្មអន្តរជាតិតាម GATT បានបង្កើតអោយមាននូវយន្តការនៃការដោះស្រាយវិវាទដើម្បីដោះស្រាយបញ្ហានៃការរំលោភបំពានកិច្ចព្រមព្រៀង។ ក៏ប៉ុន្តែ ប្រព័ន្ធដោះស្រាយវិវាទនេះ នៅតែមានចំណុចខ្វះខាត ដែលមិនអាចអនុវត្តបានប្រកបដោយប្រសិទ្ធិភាព និងជួយជំរុញនូវការប្តេជ្ញារបស់ភាគីក្នុងការអនុវត្តតាមកិច្ចព្រមព្រៀងនៅឡើយ។

អាស្រ័យហេតុនេះហើយ ទើបក្នុងកិច្ចប្រជុំតុមូលនៅអ៊ុយរ៉ាហ្គាយ ស្តីពីការចរចាពាណិជ្ជកម្មពហុភាគី ប្រទេសជាសមាជិកបានបង្កើតនូវប្រព័ន្ធដោះស្រាយវិវាទមួយ ដែលធ្វើការកែសម្រួលបំពេញបន្ថែមនូវចំណុចខ្វះខាតរបស់ប្រព័ន្ធដោះស្រាយវិវាទពីមុន នោះគឺប្រព័ន្ធដោះស្រាយវិវាទពាណិជ្ជកម្មអន្តរជាតិរបស់អង្គការពាណិជ្ជកម្មពិភពលោក។ វាជាប្រព័ន្ធដោះស្រាយវិវាទមួយដែលកំពុងត្រូវបានប្រើប្រាស់សម្រាប់ការដោះស្រាយវិវាទក្នុងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអង្គការ WTO នាពេលបច្ចុប្បន្ន។

ដោយហេតុថា ការយល់ដឹងអំពីប្រព័ន្ធដោះស្រាយវិវាទពាណិជ្ជកម្មនេះមានសារៈសំខាន់ជាពិសេសប្រទេសជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោកដូចជាកម្ពុជា ដូចនេះ វាមានភាពចាំបាច់ក្នុងការដឹងថា ប្រព័ន្ធដោះស្រាយវិវាទពាណិជ្ជកម្មអន្តរជាតិរបស់អង្គការពាណិជ្ជកម្មពិភពលោកមានលក្ខណៈបែបណា ហើយថាតើការដោះស្រាយវិវាទក្នុងប្រព័ន្ធនេះ មាននីតិវិធី និងដំណើរការបែបណាខ្លះ។

ជាការពិតក្នុងនាមជាប្រទេសសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ដែលធ្វើពាណិជ្ជកម្មជាមួយនឹងបណ្តាប្រទេសជាសមាជិកដទៃទៀត កម្ពុជាអាចនឹងមាននូវបញ្ហាវិវាទពាណិជ្ជកម្មដោយប្រការណាមួយ។ ដូចនេះ គោលបំណងនៃការស្រាវជ្រាវលើប្រធានបទនេះ គឺដើម្បីជាការទាញអារម្មណ៍ឲ្យយើងងាកមកធ្វើការសិក្សាស្វែងយល់ពីប្រព័ន្ធដោះស្រាយវិវាទនេះ ដើម្បីឲ្យកម្ពុជាអាចមានមូលដ្ឋានរឹងមាំ ក្នុងការការពារនូវសិទ្ធិ និងផលប្រយោជន៍របស់ខ្លួននៅក្នុងអង្គការនេះ ជាពិសេសក្នុងករណីដែលកម្ពុជាមានបញ្ហាវិវាទពាណិជ្ជកម្មជាមួយប្រទេសជាសមាជិកណាមួយ។

គួរបញ្ជាក់ថា ការសិក្សាអំពីប្រព័ន្ធដោះស្រាយវិវាទពាណិជ្ជកម្មរបស់អង្គការពាណិជ្ជកម្មពិភពលោក មានលក្ខណៈស៊ីជម្រៅ និងស្មុគស្មាញខ្លាំង កិច្ចការសារណានេះ សូមធ្វើការលើកឡើងតែទិដ្ឋភាពទូទៅនៃប្រព័ន្ធដោះស្រាយវិវាទ និងដំណាក់កាលសំខាន់ៗ នៅក្នុងនីតិវិធីនៃការដោះស្រាយវិវាទក្នុងប្រព័ន្ធនេះប៉ុណ្ណោះ។ ជាមួយគ្នានេះដែរ កិច្ចការសារណានេះ សូមកំណត់យកចាប់ពីពេលដែលបង្កើតអោយមាននូវប្រព័ន្ធដោះស្រាយវិវាទនេះ រហូតមកដល់បច្ចុប្បន្ន ក៏ប៉ុន្តែសូមផ្តោតជាសំខាន់ទៅលើបច្ចុប្បន្នភាពនៃប្រព័ន្ធដោះស្រាយវិវាទពាណិជ្ជកម្មអន្តរជាតិនេះ។

ប្រធានបទនេះជាប្រធានបទមួយថ្មី ហើយមានកង្វះខាតឯកសារជាភាសាខ្មែរ ទើបកិច្ចការសារណានេះពឹងផ្អែកជាសំខាន់ទៅលើឯកសារជាភាសាបរទេស ដែលរកបានតាមប្រព័ន្ធអ៊ីនធឺណេតដូចជាលិខិតបទដ្ឋានគតិយុត្តអន្តរជាតិនានាដែលគ្របដណ្តប់លើបញ្ហានេះ ព្រមទាំងឯកសារនៅក្នុងវ៉ែបសាយរបស់អង្គការពាណិជ្ជកម្មពិភពលោកជាដើម។ ខ្លឹមសារទាំងមូលពឹងផ្អែកលើការបកប្រែពីភាសាបរទេសមកជាភាសាខ្មែរ រួមបញ្ចូលនឹងការស្វែងយល់បន្ថែមជាច្រើនទៀត។

នៅក្នុងកិច្ចការសារណានេះ នឹងធ្វើការបែងចែកជាពីរជំពូកធំៗនោះគឺ ជំពូកទី១ ធ្វើការបង្ហាញពី សញ្ញាណទូទៅនៃប្រព័ន្ធដោះស្រាយវិវាទពាណិជ្ជកម្មរបស់អង្គការពាណិជ្ជកម្មពិភពលោកដោយរួមបញ្ចូលទាំងប្រវត្តិ មុខងារ និងលក្ខណៈនៃប្រព័ន្ធនេះជាដើម។ ចំណែកជំពូកទី២ នឹងធ្វើការបង្ហាញអំពីដំណើរការ ឬនីតិវិធីនៃការដោះស្រាយវិវាទពាណិជ្ជកម្មអន្តរជាតិនៅក្នុងប្រព័ន្ធនេះ។

# ជំពូកទី១ សញ្ញាណទូទៅអំពីប្រព័ន្ធដោះស្រាយវិវាទពាណិជ្ជកម្មអន្តរជាតិ របស់អង្គការពាណិជ្ជកម្មពិភពលោក

ក្នុងការស្វែងយល់អំពីសញ្ញាណទូទៅនៃប្រព័ន្ធដោះស្រាយវិវាទពាណិជ្ជកម្មអន្តរជាតិ របស់អង្គការពាណិជ្ជកម្មពិភពលោក គេត្រូវដឹងអំពីព័ត៌មានទូទៅស្តីពីអង្គការនេះ ប្រវត្តិ មុខងារ តួអង្គពាក់ព័ន្ធ និងបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងប្រព័ន្ធដោះស្រាយវិវាទនេះ។

## ១.១. អំពីអង្គការពាណិជ្ជកម្មពិភពលោក

មុននឹងឈានទៅស្វែងយល់អំពី សញ្ញាណទូទៅនៃប្រព័ន្ធដោះស្រាយវិវាទពាណិជ្ជកម្មរបស់អង្គការពាណិជ្ជកម្មពិភពលោក វាពិតជាមានសារៈសំខាន់ក្នុងការយល់ថាតើអ្វីជាអង្គការពាណិជ្ជកម្មពិភពលោក ហើយអង្គការនេះត្រូវបានបង្កើតឡើងក្នុងគោលបំណងអ្វី មានមុខងារ និងរចនាសម្ព័ន្ធបែបណាខ្លះ។

### ១.១.១. តើអង្គការពាណិជ្ជកម្មពិភពលោកជាអ្វី?

អង្គការពាណិជ្ជកម្មពិភពលោក ហៅថាកាត់ថា WTO គឺជាអង្គការអន្តរជាតិមួយដែលធ្វើកិច្ចការពាក់ព័ន្ធនឹងវិធាននៃការធ្វើពាណិជ្ជកម្មរវាងប្រជាជាតិនានា ដែលមានលក្ខណៈជាសកល ព្រមទាំងបើកឲ្យមាននូវការធ្វើពាណិជ្ជកម្ម ដែលអាចផ្តល់ផលប្រយោជន៍សម្រាប់ប្រជាជាតិជាសមាជិកទាំងអស់ តាមរយៈការបង្កើតអោយមាននូវវេទិកាសម្រាប់ធ្វើការចរចាបង្កើតនូវកិច្ចព្រមព្រៀងនានាក្នុងគោលបំណងកាត់បន្ថយនូវឧបសគ្គនៅក្នុងការធ្វើពាណិជ្ជកម្មអន្តរជាតិ និងធានានូវការតបតចំពោះគ្នានៅក្នុងវិស័យដូចគ្នា(Level playing Field) ក្នុងកិច្ចការពាណិជ្ជកម្មសម្រាប់សមាជិកទាំងអស់ ។ ជាក់ស្តែង តាមកិច្ចព្រមព្រៀង Marrakesh ស្តីពីការបង្កើតអង្គការពាណិជ្ជកម្មពិភពលោក ឬកិច្ចព្រមព្រៀង WTO អង្គការពាណិជ្ជកម្មពិភពលោក គឺជាអង្គការកំពូលមួយទទួលខុសត្រូវក្នុងការពិនិត្យមើលការអនុវត្តន៍កិច្ចព្រមព្រៀងពហុភាគី និងច្រើនភាគី ដែលបានលើកមកចរចានៅវគ្គចរចានៅអ៊ុយរ៉ាហ្គាយ និងខ្លះទៀតត្រូវលើកយកមកចរចានាពេលអនាគតខាងមុខ។

ដូចនេះ អង្គការពាណិជ្ជកម្មពិភពលោក គឺជាអង្គការមួយដែលផ្តល់នូវក្របខណ្ឌគតិយុត្តនិងស្ថាប័នសម្រាប់ការអនុវត្ត និងដឹកនាំនូវកិច្ចព្រមព្រៀងដែលត្រូវបានបង្កើតឡើង ព្រមទាំងធ្វើការដោះស្រាយនូវវិវាទដែលកើតចេញមកពីការបកស្រាយ និងការអនុវត្តនូវកិច្ចព្រមព្រៀងទាំងនោះផងដែរ។[1] បច្ចុប្បន្ននេះ មានកិច្ចព្រមព្រៀងពាណិជ្ជកម្មជាច្រើននៅក្នុងអង្គការពាណិជ្ជកម្មពិភពលោកមួយនេះ ដែលរួមមានកិច្ចព្រមព្រៀងពហុភាគីចំនួន១៦ផ្សេងៗគ្នា ដែលមានរដ្ឋជាសមាជិក

[1] កិច្ចព្រមព្រៀងបង្កើតអង្គការពាណិជ្ជកម្មពិភពលោក, 1995, មាត្រា 2។

អង្គការទាំងអស់ជាភាគីនៃកិច្ចព្រមព្រៀង ហើយនិងកិច្ចព្រមព្រៀង២ទៀត ដែលមានតែសមាជិកមួយចំនួនរបស់អង្គការប៉ុណ្ណោះជាភាគីនៃកិច្ចព្រមព្រៀង។

អង្គការពាណិជ្ជកម្មពិភពលោក ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩៥ តាមរយៈកិច្ចព្រមព្រៀងស្តីពីការបង្កើតអង្គការពាណិជ្ជកម្មពិភពលោកនៅទីក្រុង Marakesh។ ប៉ុន្តែគួរបញ្ជាក់ថា នៅមុនពេលមានអង្គការ WTOនេះ ក៏មានអង្គការមួយផងដែរ ដែលបង្កើតឡើងតាមរយៈកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្ម និងពន្ធគយ ហៅកាត់ថា GATT ដែលក្រោយមកត្រូវបានរួមបញ្ចូលតាមផ្លូវច្បាប់ទៅជា WTO។ កន្លងមកជាង៦០ឆ្នាំមកនេះ WTO និងអង្គការពីមុនរបស់វា (GATT) បានជួយបង្កើតនូវប្រព័ន្ធនៃការធ្វើពាណិជ្ជកម្មអន្តរជាតិដែលមានភាពរឹងមាំ និងល្អប្រសើរច្រើន ហើយដែលតាមរយៈនេះ អង្គការបានរួមចំណែកនៅក្នុងការធ្វើឲ្យលូតលាស់នូវសេដ្ឋកិច្ចសកលលោកដែលមិនធ្លាប់មានពីមុនមក។

### ១.១.២. គោលបំណងរបស់អង្គការ

នៅក្នុងបុព្វកថានៃកិច្ចព្រមព្រៀងបង្កើតអង្គការ WTO មានចែងអំពីគោលបំណងរបស់WTO ដូចជា ការលើកកំពស់ជីវភាពរស់នៅ និងចំណូលនានា ការធានាឲ្យមានការងារធ្វើពេញលេញ ការពង្រីកផលិតកម្ម និងការធ្វើពាណិជ្ជកម្ម ដោយអនុវត្តន៍ឲ្យបានត្រឹមត្រូវក្នុងការប្រើប្រាស់ធនធានពិភពលោកប្រកបដោយប្រសិទ្ធិភាព និងអស់សក្តានុពល។

បុព្វកថាបានពង្រីកបន្ថែមគោលបំណងទៅលើវិស័យមួយចំនួនទៀតដូចខាងក្រោម[2]៖

☞ពាណិជ្ជកម្មលើសេវាកម្ម

☞សេចក្តីត្រូវការសម្រាប់ជំរុញនិរន្តរភាពនៃការអភិវឌ្ឍន៍ និងការពារបរិស្ថានតាមរបៀបមួយសមស្របទៅតាមកម្រិតនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិនីមួយៗ។

☞សេចក្តីត្រូវការចំពោះការខិតខំជាវិជ្ជមាន ដើម្បីធានាថាប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសក្រីក្រ មានការអភិវឌ្ឍ និងមានកំនើនសេដ្ឋកិច្ចផងដែរ ក្នុងការចូលរួមនៅក្នុងកិច្ចចរចាពាណិជ្ជកម្មអន្តរជាតិ។

គោលបំណងរបស់ WTO គឺស្រដៀងគ្នាទៅនឹង GATT ដោយគ្រាន់តែមានការពង្រីកកម្មវត្ថុដើម្បីផ្តល់អំណាចឲ្យអង្គការនេះដោះស្រាយកិច្ចការពាណិជ្ជកម្មលើសេវាកម្ម។

[2] កៅ សីហា, *WTO និងកម្ពុជា* (ភ្នំពេញ), ទំព័រ 7។

### ១.១.៣. មុខងាររបស់អង្គការ

យោងតាមខ្លឹមសារនៃកិច្ចព្រមព្រៀងបង្កើតអង្គការពាណិជ្ជកម្មពិភពលោក អង្គការនេះមានមុខនាទីដូចខាងក្រោម:

☞សម្រួលដល់ការអនុវត្ត ការគ្រប់គ្រងនិងប្រតិបត្តិការនៃកិច្ចព្រមព្រៀងបង្កើតអង្គការ WTO កិច្ចព្រមព្រៀងពាណិជ្ជកម្មពហុភាគីផ្សេងទៀត និងកិច្ចព្រមព្រៀងពាណិជ្ជកម្មច្រើនភាគី

☞បង្កើតវេទិកាសម្រាប់ការចរចារវាងសមាជិកអង្គការ ពាក់ព័ន្ធនិងទំនាក់ទំនងពាណិជ្ជកម្មពហុភាគីរបស់ពួកគេក្នុងបញ្ហាដែលត្រូវដោះស្រាយក្រោមកិច្ចព្រមព្រៀង ដែលមានកំណត់នៅក្នុងឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងបង្កើត WTO ព្រមទាំងផ្តល់នូវក្របខណ្ឌសម្រាប់ការអនុវត្តនូវលទ្ធផលនៃកិច្ចចរចាដែលត្រូវបានសម្រេចដោយសន្និសីទថ្នាក់រដ្ឋមន្ត្រី

☞គ្រប់គ្រងលើឧបសម្ព័ន្ធ 2 (Annex 2) ដែលកំណត់អំពីការស្វែងយល់អំពីវិធាន និងនីតិវិធីគ្រប់គ្រងលើការដោះស្រាយវិវាទ ដែលត្រូវបានហៅថា ការស្វែងយល់ពីការដោះស្រាយវិវាទ DSU ព្រមទាំងឧបសម្ព័ន្ធ3(Annex 3)ដែលកំណត់អំពីយន្តការត្រួតពិនិត្យនយោបាយពាណិជ្ជកម្មTPRM

☞សហការជាមួយនឹងមូលនិធិរូបិយវត្ថុអន្តរជាតិ IMF ធនាគារអន្តរជាតិ សម្រាប់ការស្តារឡើងវិញ ការអភិវឌ្ឍ និងរូបរួមភ្នាក់ងាររបស់ខ្លួន ក្នុងទស្សនៈនៃការសម្រេចឲ្យបានការទាក់ទងគ្នាកាន់តែខ្លាំងឡើងក្នុងការបង្កើតនយោបាយសេដ្ឋកិច្ចសកលលោក

☞ដើរតួនាទីជាស្ថាប័នរួមមួយ សម្រាប់ការប្រតិបត្តិនូវទំនាក់ទំនងពាណិជ្ជកម្មរវាងសមាជិករបស់អង្គការ ក្នុងបញ្ហាដែលទាក់ទងនឹងកិច្ចព្រមព្រៀង និងលិខិតុបករណ៍គតិយុត្តដែលពាក់ព័ន្ធនិងដែលត្រូវបានបញ្ចូលទៅក្នុងឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងបង្កើតអង្គការពាណិជ្ជកម្មពិភពលោក។[3]

☞ត្រូវផ្តល់ជាអាទិភាពសម្រាប់ការចរចាបន្តទៀត នៅក្នុងចំណោមប្រទេសជាសមាជិកនូវបញ្ហាផ្សេងៗដែលមានចែងក្នុងកិច្ចព្រមព្រៀង និងអំពីបញ្ហាថ្មីនានាដែលស្ថិតក្នុងអំណាចរបស់ខ្លួនព្រមទាំងអំពីការធ្វើសេរីភាវូបនីយកម្មផ្នែកពាណិជ្ជកម្មបន្ថែមទៀត។[4]

---

[3] កិច្ចព្រមព្រៀងបង្កើតអង្គការពាណិជ្ជកម្មពិភពលោក, 1995, មាត្រា 3។

[4] កៅ សីហា, *WTO និងកម្ពុជា* (ភ្នំពេញ), ទំព័រ 7។

☞ត្រូវជួយសម្រួលដល់ការអនុវត្ត ការគ្រប់គ្រង និងប្រតិបត្តិការនៃឯកសារគតិយុត្តនាកិច្ចប្រជុំចរចានៅអ៊ុយរ៉ាហ្គាយ និងរាល់កិច្ចព្រមព្រៀងទាំងឡាយដែលបានចរចា និងបានអនុម័តក្នុងកិច្ចចរចានាពេលអនាគត។[5]

☞ត្រូវទទួលខុសត្រូវលើការសម្របសម្រួលការខ្វែងគំនិតគ្នា និងវិវាទដែលកើតមាននៅក្នុងចំណោមប្រទេសជាសមាជិក

☞ត្រូវទទួលខុសត្រូវលើការត្រួតពិនិត្យជាប្រចាំ ចំពោះគោលនយោបាយពាណិជ្ជកម្មរបស់បណ្តាប្រទេសជាសមាជិក។[6]

### ១.១.៤. រចនាសម្ព័ន្ធរបស់អង្គការពាណិជ្ជកម្មពិភពលោក[7]

នៅក្នុងអង្គការពាណិជ្ជកម្មពិភពលោកមានអង្គភាពសំខាន់ៗជាច្រើន ដែលបំពេញមុខងាររបស់ខ្លួនទៅតាមអ្វីដែលមានកំណត់ក្នុងកិច្ចព្រមព្រៀងបង្កើតអង្គការពាណិជ្ជកម្មពិភពលោក ដែលអង្គភាពទាំងនោះមានដូចខាងក្រោម៖

#### ១.១.៤.១. សន្និសីទថ្នាក់រដ្ឋមន្ត្រី

អង្គភាពកំពូលរបស់អង្គការ WTO គឺសន្និសីទថ្នាក់រដ្ឋមន្ត្រី ដែលធ្វើការប្រជុំរវាងពីរឆ្នាំម្តងដើម្បីសម្រេចនូវរាល់នយោបាយពាណិជ្ជកម្ម និងការចរចាតាមវិស័យផ្សេងៗ ដែលលើកឡើងដោយអង្គភាពថ្នាក់ក្រោម។ សន្និសីទថ្នាក់រដ្ឋមន្ត្រីនេះ ទទួលបន្ទុកអនុវត្តមុខងាររបស់អង្គការ និងធ្វើសកម្មភាពចាំបាច់នានា។

#### ១.១.៤.២. អគ្គក្រុមប្រឹក្សា

អង្គភាពបន្ទាប់ពីសន្និសីទថ្នាក់រដ្ឋមន្ត្រីមកគឺ អគ្គក្រុមប្រឹក្សាដែលធ្វើការងារទូទៅដោយទទួលរបាយការណ៍ពីក្រុមប្រឹក្សាថ្នាក់បន្ទាប់ផ្សេងទៀត និងបើកកិច្ចប្រជុំដើម្បីដោះស្រាយវិវាទពាណិជ្ជកម្ម និងត្រួតពិនិត្យនយោបាយពាណិជ្ជកម្ម របស់បណ្តាប្រទេសជាសមាជិកនីមួយៗជាប្រចាំ។

អគ្គក្រុមប្រឹក្សា មានតំណាងនៃប្រទេសសមាជិកទាំងអស់ ហើយត្រូវប្រជុំតាមការសមគួរ។ អគ្គក្រុមប្រឹក្សាត្រូវបំពេញមុខងាររបស់សន្និសីទថ្នាក់រដ្ឋមន្ត្រី នៅចន្លោះកិច្ចប្រជុំសន្និសីទថ្នាក់រដ្ឋមន្ត្រីនីមួយៗ ព្រមទាំងបំពេញមុខងារផ្សេងទៀតដែលកំណត់ដោយកិច្ចព្រមព្រៀងបង្កើតអង្គការ WTO

[5] កៅ សីហា, *WTO និងកម្ពុជា* (ភ្នំពេញ), ទំព័រ ៧។
[6] កៅ សីហា, *WTO និងកម្ពុជា* (ភ្នំពេញ), ទំព័រ ៧។
[7] កៅ សីហា, *WTO និងកម្ពុជា* (ភ្នំពេញ), ទំព័រ ៨។

ដូចជា ធ្វើការកោះប្រជុំអង្គភាពដោះស្រាយវិវាទ អង្គភាពត្រួតពិនិត្យនយោបាយពាណិជ្ជកម្ម ដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ខ្លួន។

**១.១.៤.៣. ក្រុមប្រឹក្សាពាណិជ្ជកម្មលើទំនិញ**

ក្រុមប្រឹក្សាពាណិជ្ជកម្មលើទំនិញ ជាអ្នកឃ្លាំមើលការអនុវត្ត និងកិច្ចដំណើរការកិច្ចព្រមព្រៀង GATT និងកិច្ចព្រមព្រៀងពាក់ព័ន្ធនានា។[8]

**១.១.៤.៤. ក្រុមប្រឹក្សាពាណិជ្ជកម្មលើសេវាកម្ម**

ក្រុមប្រឹក្សាពាណិជ្ជកម្មលើសេវាកម្ម ជាអ្នកឃ្លាំមើលការអនុវត្តន៍ និងកិច្ចដំណើរការនៃកិច្ចព្រមព្រៀង GATS។[9]

**១.១.៤.៥. ក្រុមប្រឹក្សាផ្នែកកម្មសិទ្ធិបញ្ញា**

ក្រុមប្រឹក្សានេះ គឺជាអ្នកឃ្លាំមើលកិច្ចដំណើរការនៃកិច្ចព្រមព្រៀង TRIPS។[10] ក្រៅពីក្រុមប្រឹក្សាទាំង ៣ ខាងលើនេះ គេមានបង្កើតគណៈកម្មាធិការមួយចំនួនទៀតតាមការពាក់ព័ន្ធនៃកិច្ចព្រមព្រៀងនីមួយៗ ដើម្បីទទួលយកការងារមកពិនិត្យ និងដោះស្រាយទៅតាមកម្រិតនីមួយៗនៃការអនុវត្តរបស់កិច្ចព្រមព្រៀង។

**១.១.៤.៦. អង្គភាពដោះស្រាយវិវាទ**

កិច្ចព្រមព្រៀងអង្គការ WTO មានចែងពីប្រព័ន្ធវិធាន និងនីតិវិធីរួមមួយសម្រាប់អនុវត្តលើវិវាទដែលកើតឡើងនៅក្រោមលិខិតុបករណ៍ច្បាប់ណាមួយរបស់ខ្លួន។ ការទទួលខុសត្រូវសំខាន់សម្រាប់គ្រប់គ្រងវិធាន និងនីតិវិធីទាំងនេះស្ថិតនៅលើអគ្គក្រុមប្រឹក្សា ដែលត្រូវបានកត់សម្គាល់ថាមានតួនាទីជាអង្គភាពដោះស្រាយវិវាទ (DSB) ។ គោលការណ៍សំខាន់មួយចំនួនក្នុងចំណោមគោលការណ៍សំខាន់ដទៃទៀតដែលនីតិវិធីទាំងនេះបានកំណត់គឺថា រដ្ឋាភិបាលនៃប្រទេសជាសមាជិកគួរដាក់វិវាទជូនអង្គភាពដោះស្រាយវិវាទដើម្បីដោះស្រាយ បន្ទាប់ពីបរាជ័យក្នុងការប្រឹងប្រែងដោះស្រាយតាមរយៈការពិគ្រោះយោបល់។

**១.១.៤.៧. លេខាធិការដ្ឋាន** WTO

អង្គការ WTO មានលេខាធិការដ្ឋានមួយដែលមានទីតាំងនៅទីក្រុងហ្សឺណែវប្រទេសស្វីស។ លេខាធិការដ្ឋាននេះដឹកនាំដោយអគ្គនាយកមួយរូបដែលត្រូវបានជ្រើសរើសតាមការបោះឆ្នោត និង

[8] កិច្ចព្រមព្រៀងបង្កើតអង្គការពាណិជ្ជកម្មពិភពលោក, 1995, មាត្រា 4 ចំណុច 5។

[9] កិច្ចព្រមព្រៀងបង្កើតអង្គការពាណិជ្ជកម្មពិភពលោក, 1995, មាត្រា 4 ចំណុច 5។

[10] កិច្ចព្រមព្រៀងបង្កើតអង្គការពាណិជ្ជកម្មពិភពលោក, 1995, មាត្រា 4 ចំណុច 5។

មានអាណត្តិរយៈពេល៥ឆ្នាំ។ អគ្គនាយកអាចជ្រើសរើសអគ្គនាយករងចំនួន ៣ រូបទៀត ដើម្បីជួយធ្វើការដោយមានការពិគ្រោះពិភាក្សា និងយល់ព្រមពីបណ្តាប្រទេសជាសមាជិក។ មន្ត្រីចម្រុះជាតិសាសន៍ ដែលធ្វើការនៅលេខាធិការដ្ឋានមានចំនួនប្រហែល៧០០ នាក់ដែលភាគច្រើនចេះពីរ ឬបីភាសា ក្នុងចំណោមភាសាផ្លូវការទាំងបីរបស់អង្គការពាណិជ្ជកម្មពិភពលោក ដែលរួមមានភាសាអង់គ្លេស បារាំង និងអេស្ប៉ាញ។

### ១.១.៤.៨. អង្គភាពជំនាញរាយនផ្សេងៗទៀត

ក្រៅពីស្ថាប័នដែលបានរៀបរាប់ខាងលើ នៅមានស្ថាប័នផ្សេងៗទៀត ក្នុងនោះមានដូចជាគណៈកម្មាធិការពាណិជ្ជកម្មនិងអភិវឌ្ឍន៍ គណៈកម្មាធិការរឹតត្បិតតុល្យភាពចំណាយ គណៈកម្មាធិការថវិកា ហិរញ្ញវត្ថុ រដ្ឋបាល ដែលគណៈកម្មាធិការទាំងអស់នេះត្រូវបានបង្កើតឡើងដោយសន្និសីទថ្នាក់រដ្ឋមន្ត្រី។

### ១.១.៥. សមាជិកភាព និងការសម្រេចសេចក្តីនៅក្នុង WTO

ប្រទេសដែលមានបំណងចង់ចូលជាសមាជិកអង្គការ WTO ត្រូវដាក់ពាក្យសុំចូល និងធ្វើការចរចាជាលក្ខណៈទ្វេ និងពហុភាគីសម្រាប់បង្ហាញពីតម្លាភាព និងភាពស្របគ្នានៃបទបញ្ញត្តិច្បាប់របស់ជាតិទៅនឹងកិច្ចផ្សេងៗ ដូចជាកាត់បន្ថយពន្ធគយ ការធ្វើសេរីភាវូបនីយកម្មផ្នែកសេវាកម្មដែលប្រការនេះ គេហៅថា កម្រៃ ត្រូវបង់ដោយប្រទេសសុំចូល ជាថ្នូរនឹងការទទួលបានអត្ថប្រយោជន៍នានាពី WTO។ មកដល់បច្ចុប្បន្នថ្ងៃទី ២៦ ខែ មេសា ឆ្នាំ២០១៥ អង្គការមួយនេះមានសមាជិកសរុប ១៦១ប្រទេស រួមបញ្ចូលទាំងប្រទេសអតីតសមាជិករបស់ GATT ដែលក្នុងនោះ ១១៧ប្រទេស ជាប្រទេសកំពុងអភិវឌ្ឍន៍និងដែនដីរដ្ឋបាលពន្ធគយដាច់ដោយឡែក(Separate customs territories)។

សេចក្តីសម្រេចរបស់អង្គការពាណិជ្ជកម្មពិភពលោក ជាទូទៅធ្វើឡើងដោយកុងស៊ុងស៊ុសរវាងសមាជិកទាំងមូលរបស់អង្គការ។

## ១.២. អំពីប្រវត្តិ និងការវិវត្តន៍នៃប្រព័ន្ធដោះស្រាយវិវាទ

នៅក្នុងប្រព័ន្ធដោះស្រាយវិវាទរបស់ GATT 1947 ភាគីរួមគ្នាក្នុងការដោះស្រាយវិវាទរបស់ពួកគេ ដោយក្នុងនោះវិវាទនៅក្នុង GATT ត្រូវបានសម្រេចដោយការដឹកនាំរបស់ប្រធានក្រុមប្រឹក្សា GATT។ បន្ទាប់មកវិវាទទាំងនោះ ត្រូវបានដាក់ចូលទៅកាន់ក្រុមការងារមួយដែលមានសមាសភាពអ្នកតំណាងរបស់ប្រទេសភាគីដែលមានផលប្រយោជន៍ពាក់ព័ន្ធទាំងអស់ រួមទាំងភាគីវិវាទផងដែរ។ ក្រុមការងារនេះ អនុម័តសេចក្តីសម្រេចរបស់ខ្លួនដោយការសម្រេចជាកុងស៊ុងស៊ុស។ ក្រោយមក

ក្រុមការងារនេះត្រូវបានជំនួសដោយគណៈវិនិច្ឆ័យ ដែលមានសមាសភាពអ្នកជំនាញឯករាជ្យ ៣ ឬ ៥នាក់ ដែលមិនមានជាប់ពាក់ព័ន្ធនឹងភាគីវិវាទ។ គណៈវិនិច្ឆ័យនេះ ចេញនូវសេចក្តីសម្រេចឯករាជ្យ រួមជាមួយនឹងអនុសាសន៍ និងវិធានសម្រាប់ការដោះស្រាយវិវាទ រួចដាក់ជូនក្រុមប្រឹក្សា GATT។ លុះត្រាតែសេចក្តីសម្រេច អនុសាសន៍ និងវិធានទាំងនេះ ទទួលបានការអនុម័តយល់ព្រមពីក្រុមប្រឹក្សា GATT ទើបវាមានអានុភាពចាប់បង្ខំអោយភាគីអនុវត្តតាម។[11] ប៉ុន្តែប្រព័ន្ធនៃការដោះស្រាយវិវាទរបស់ GATT មាននូវចំណុចខ្សោយមួយចំនួនដូចជា ការតម្រូវឲ្យមានកុងស៊ុងស៊ុសនៅក្នុងក្រុមប្រឹក្សា GATT ដើម្បីអាចដាក់វិវាទចូលទៅគណៈវិនិច្ឆ័យ ដែលនេះមានន័យថា គ្មានភាគីណាមួយបដិសេធក្នុងការសម្រេចដាក់វិវាទនោះចូលទៅកាន់គណៈវិនិច្ឆ័យ។ បន្ថែមលើនេះទៀតការសម្រេចដោយកុងស៊ុងស៊ុសនេះ ក៏ត្រូវបានអនុវត្តចំពោះការអនុម័តនូវសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យ ការចាត់វិធានការតបតចំពោះការមិនអនុវត្តតាមសេចក្តីសម្រេច ដែលនាំឲ្យចុងចម្លើយអាចរារាំងនូវដំណើរការទាំងអស់នេះបាន។ ដូច្នេះហើយ នៅទសវត្សឆ្នាំ ១៩៨០ ប្រព័ន្ធដោះស្រាយវិវាទរបស់ GATT ត្រូវបានខូចខាតលែងត្រូវបានប្រើប្រាស់។[12] ជំនួសមកវិញមានការចរចានៅក្នុងកិច្ចប្រជុំនៅអ៊ុយរ៉ាហ្គាយ ដែលបាននាំមកនូវប្រព័ន្ធដោះស្រាយវិវាទថ្មីមួយ។

លទ្ធផលនៃការចរចា គេបង្កើតបានការស្វែងយល់អំពីវិធាន និងនីតិវិធីដែលគ្រប់គ្រងលើការដោះស្រាយវិវាទ ឬហៅថា ការស្វែងយល់ពីការដោះស្រាយវិវាទ Dispute Settlement Understanding (DSU)។ DSUនេះបានឆ្លុះបញ្ចាំងនូវកម្មវត្ថុនៃការចរចាដើម្បីបង្កើតនូវយន្តការមួយដែលមានលក្ខណៈយុត្តាធិការច្រើន ហើយមានការរំពឹងទុកថាវានឹងមានភាពយុត្តិធម៌ និងអនុវត្តបានច្រើនជាងប្រព័ន្ធនៃការចរចាជាលក្ខណៈការទូត។ DSU ត្រូវយកទៅអនុវត្តចំពោះបញ្ហាវិវាទទាំងអស់ដែលកើតឡើងក្រោមកិច្ចព្រមព្រៀង WTO ឬដែលអាចហៅថាកិច្ចព្រមព្រៀងពាក់ព័ន្ធដូចមានកំណត់នៅក្នុង DSU ដោយមានការខុសប្លែកគ្នាបន្តិចបន្តួចប៉ុណ្ណោះ។[13] ដូចនេះ DSU បានបង្ហាញនូវប្រព័ន្ធនៃការដោះស្រាយវិវាទដែលមានភាពរឹងមាំមួយគួរឲ្យកត់សម្គាល់ ដោយវាបាន

[11] កិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្ម និងពន្ធគយ GATT, 1947, មាត្រា 23 ។

[12] *Dispute Settlement System Training Module* [ មេរៀនបណ្តុះបណ្តាលស្តីពីប្រព័ន្ធដោះស្រាយវិវាទ], https://www.wto.org/english/tratop_e/dispu_e/disp_settlement_cbt_e/signin_e.htm (ចូលអាន និងទាញយក ថ្ងៃទី 5 ឧសភា 2015)។

[13] Daniel T. Shedd, Brandon J. Murrill, និងJane M. Smith, *Dispute settlement in the World Trade Organization: An overview* [ការដោះស្រាយវិវាទនៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក: ទិដ្ឋភាពទូទៅ] (USA: Congressional Research Service, 2012), ទំព័រ 1, https://www.fas.org/sgp/crs/misc/RS20088.pdf (ចូលអាន និងទាញក ថ្ងៃទី 15 ឧសភា 2015)។

បង្ហាញនូវនីតិវិធីយ៉ាងលំអិត សម្រាប់ដំណាក់កាលជាច្រើននៃការដោះស្រាយវិវាទ រួមទាំងថិរវេលាជាក់លាក់សម្រាប់ដំណាក់កាលទាំងនោះផងដែរ ដើម្បីធានានូវការដោះស្រាយមួយប្រកបដោយភាពត្រឹមត្រូវ។

អ្វីដែលមានលក្ខណៈថ្មីសម្រាប់ប្រព័ន្ធដោះស្រាយវិវាទនេះ គឺថា DSU បានលុបចោលនូវសិទ្ធិរបស់ភាគីក្នុងការរារាំងនូវការបង្កើតគណៈវិនិច្ឆ័យ និងការអនុម័តសេចក្ដីសម្រេច ជាពិសេសភាគីដែលជាម្ចាស់នៃវិធានដែលត្រូវបានគេប្ដឹងតវ៉ា ។ បច្ចុប្បន្ននេះ អង្គភាពដោះស្រាយវិវាទបង្កើតនូវគណៈវិនិច្ឆ័យ ព្រមទាំងអនុម័តនូវសេចក្ដីសម្រេចរបស់គណៈវិនិច្ឆ័យ និងអង្គភាពឧទ្ធរណ៍ដោយស្វ័យប្រវត្តិ លើកលែងតែមានកុងស៊ុងស៊ុសប្រឆាំង។ កុងស៊ុងស៊ុសបដិសេធនេះ គឺផ្ទុយទៅនឹងការអនុវត្តការដោះស្រាយវិវាទក្រោម GATT 1947 ពាក់ព័ន្ធនឹងការបង្កើតគណៈវិនិច្ឆ័យ ការអនុម័តសេចក្ដីសម្រេចរបស់គណៈវិនិច្ឆ័យ និងអង្គភាពឧទ្ធរណ៍ និងការចាត់វិធានការតបតប្រឆាំងនឹងភាគីដែលមិនអនុវត្តតាមសេចក្ដីសម្រេច។ ចំណុចសំខាន់មួយទៀតគឺ ការបង្កើតអោយមានយន្តការនៃការត្រួតពិនិត្យឧទ្ធរណ៍ទៅលើសេចក្ដីសម្រេចរបស់គណៈវិនិច្ឆ័យ ការអនុវត្តតាមសេចក្ដីសម្រេចរបស់គណៈវិនិច្ឆ័យ និងអង្គភាពឧទ្ធរណ៍បន្ទាប់ពីសេចក្ដីសម្រេចនោះត្រូវបានអនុម័តរួច។

ទោះបីជាប្រព័ន្ធដោះស្រាយវិវាទរបស់អង្គការពាណិជ្ជកម្មពិភពលោក ត្រូវបានគេឲ្យតម្លៃថាជាការបង្កើតថ្មីមួយដ៏មានសារៈសំខាន់នៅក្នុងកិច្ចប្រជុំនៅអ៊ុយរ៉ាហ្គាយក៏ដោយ ក៏គេមិនគួរមានការយល់ច្រឡំថា ប្រព័ន្ធដោះស្រាយវិវាទនេះ គឺជាការបង្កើតថ្មីទាំងស្រុងនោះទេ ត្បិតថាប្រព័ន្ធនៃការធ្វើពាណិជ្ជកម្មពហុភាគីពីមុនដែលផ្អែកលើ GATT ឆ្នាំ១៩៤៧ ក៏មានប្រព័ន្ធដោះស្រាយវិវាទដែរ។ ជាក់ស្ដែងមានគោលការណ៍ និងការអនុវត្តជាច្រើនដែលមាននៅក្នុងប្រព័ន្ធដោះស្រាយវិវាទរបស់ GATT ត្រូវបានយកមកធ្វើជាមូលដ្ឋាននៃការបង្កើតប្រព័ន្ធដោះស្រាយវិវាទរបស់អង្គការពាណិជ្ជកម្មពិភពលោកបច្ចុប្បន្ន ដូចជាមាត្រា ២២ និង២៣ នៃ GATT ឆ្នាំ១៩៤៧ដើម។ នៅក្នុងកិច្ចប្រជុំនៅអ៊ុយរ៉ាហ្គាយ បាននាំមកនូវការកែប្រែផ្លាស់ប្ដូរ និងការពន្យល់បកស្រាយបន្ថែមដ៏មានសារៈសំខាន់បន្ថែមលើប្រព័ន្ធដោះស្រាយវិវាទពីមុន។ អាចនិយាយផងដែរថា ប្រព័ន្ធដោះស្រាយវិវាទនេះ ជាលទ្ធផលនៃការវិវត្តន៍នៃវិធាន នីតិវិធី និងការអនុវត្តដែលត្រូវបានធ្វើការអភិវឌ្ឍជាងកន្លះសតវត្សក្រោមGATT ឆ្នាំ១៩៤៧។[14]

[14] Dispute Settlement System Training Module [ មេរៀនបណ្ដុះបណ្ដាលស្ដីពីប្រព័ន្ធដោះស្រាយវិវាទ], https://www.wto.org/english/tratop_e/dispu_e/disp_settlement_cbt_e/signin_e.htm (ចូលអាន និងទាញយក ថ្ងៃទី 5 ឧសភា 2015)។

ដូចនេះ ប្រព័ន្ធដោះស្រាយវិវាទរបស់អង្គការពាណិជ្ជកម្មពិភពលោកបច្ចុប្បន្ននេះ ត្រូវបានបង្កើតឡើងជាផ្នែកមួយនៃកិច្ចព្រមព្រៀង WTO នៅក្នុងកិច្ចប្រជុំនៅអ៊ុយរ៉ាហ្គាយ ដោយបានដាក់បញ្ចូលនៅក្នុងឧបសម្ព័ន្ធ ២ (Annex 2)នៃកិច្ចព្រមព្រៀង WTO ដែលDSU នេះមានកំណត់នូវនីតិវិធីវិធាន និងកំណត់ពីប្រព័ន្ធដោះស្រាយវិវាទសព្វថ្ងៃ។ ក្នុងនោះដែរបន្ទាប់ពីកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក បានចូលជាធរមាននៅក្នុងឆ្នាំ១៩៩៥ ភ្លាមៗនោះប្រព័ន្ធដោះស្រាយវិវាទនេះ បានទទួលការអនុវត្តគួរអោយកត់សម្គាល់ ដោយក្នុងនោះសមាជិកជាញឹកញាប់ពឹងផ្អែកលើប្រព័ន្ធនេះក្នុងការដោះស្រាយវិវាទពាណិជ្ជកម្មអន្តរជាតិរបស់ពួកគេ។

## ១.៣. អំពីមុខងារ គម្មវត្ថុ និងលក្ខណៈសំខាន់ៗរបស់ប្រព័ន្ធដោះស្រាយវិវាទ

ប្រព័ន្ធដោះស្រាយវិវាទនេះ ត្រូវបានបង្កើតឡើងដើម្បីបំពេញមុខងារ និងក្នុងគោលបំណងដូចខាងក្រោម។ ប្រព័ន្ធដោះស្រាយវិវាទនេះ មានលក្ខណៈសំខាន់ៗមួយចំនួន ដែលខុសប្លែកពីសំណាក់ប្រព័ន្ធដោះស្រាយវិវាទដទៃផងដែរ។

### ១.៣.១. មុខងាររបស់ប្រព័ន្ធដោះស្រាយវិវាទ

ក្នុងចំណោមមុខងារជាច្រើន ប្រព័ន្ធដោះស្រាយវិវាទនេះមានមុខងារសំខាន់ៗចំនួន ៣ ដូចខាងក្រោម៖

#### ១.៣.១.១. ផ្តល់សុវត្ថិភាព និងភាពអាចព្យាករណ៍បាន ដល់ប្រព័ន្ធនៃការធ្វើពាណិជ្ជកម្មពហុភាគី[15]

មុខងារចំបងរបស់ប្រព័ន្ធដោះស្រាយវិវាទពាណិជ្ជកម្មអន្តរជាតិរបស់អង្គការ WTO គឺផ្តល់នូវសុវត្ថិភាព និងភាពអាចព្យាករណ៍ទុកបាន ដល់ប្រព័ន្ធនៃការធ្វើពាណិជ្ជកម្មពហុភាគី។ ពាណិជ្ជកម្មអន្តរជាតិ ជាលំហូរនៃទំនិញ និងសេវារវាងប្រទេសជាសមាជិកអង្គការ ប៉ុន្តែជាទូទៅពាណិជ្ជកម្មនោះមិនត្រូវបានធ្វើឡើងដោយរដ្ឋឡើយ តែត្រូវបានធ្វើឡើងដោយពាណិជ្ជករឯកជនរបស់ប្រទេសទាំងនោះទៅវិញទេ។ ជាការពិត អ្នកចូលរួមក្នុងទីផ្សារពាណិជ្ជកម្មអន្តរជាតិទាំងនេះ តែងត្រូវការនូវស្ថេរភាព សុវត្ថិភាព និងភាពអាចព្យាករណ៍ទុកបានក្នុងវិធាន ច្បាប់ និងបទបញ្ញារបស់រដ្ឋាភិបាលដែលត្រូវយកទៅគ្រប់គ្រងលើសកម្មភាពនៃការធ្វើពាណិជ្ជកម្មរបស់ពួកគេ ជាពិសេសនៅពេលដែលពួកគេធ្វើប្រតិបត្តិការពាណិជ្ជកម្មរយៈពេលយូរ។ នៅក្នុងបរិបទនេះ DSU មានគោលបំណង

[15] Dispute Settlement System Training Module [ មេរៀនបណ្តុះបណ្តាលស្តីពីប្រព័ន្ធដោះស្រាយវិវាទ], https://www.wto.org/english/tratop_e/dispu_e/disp_settlement_cbt_e/signin_e.htm (ចូលអាន និងទាញយក ថ្ងៃទី 5 ឧសភា 2015)។

ផ្តល់នូវប្រព័ន្ធដោះស្រាយវិវាទមួយដែលមានភាពឆាប់រហ័ស ប្រសិទ្ធិភាព អាចទុកចិត្តបាន និងមាន វិធានច្បាប់ច្បាស់លាស់ ដើម្បីធ្វើការដោះស្រាយវិវាទអំពីការអនុវត្តនូវបទបញ្ញត្តិនៃកិច្ចព្រមព្រៀង អង្គការពាណិជ្ជកម្មពិភពលោក ហើយប្រព័ន្ធដោះស្រាយវិវាទនេះនឹងធ្វើឲ្យប្រព័ន្ធនៃការធ្វើពាណិជ្ជកម្ម អន្តរជាតិ កាន់តែមានសុវត្ថិភាព និងអាចព្យាករណ៍ទុកបាន។ ជាក់ស្តែងនៅពេលដែលមាន សមាជិកណាមួយរបស់អង្គការ មិនអនុវត្តស្របតាមកិច្ចព្រមព្រៀង WTO ប្រព័ន្ធដោះស្រាយវិវាទ នេះ ផ្តល់នូវដំណោះស្រាយតាមរយៈវិធានច្បាប់ឯករាជ្យ ដែលត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវ ហើយ សមាជិកដែលមិនអនុវត្តតាមអាចនឹងត្រូវប្រឈមនឹងទណ្ឌកម្មពាណិជ្ជកម្មជាដើមផងដែរ។

### ១.៣.១.២. ឆានាសិទ្ធិ និងភាតព្វកិច្ចរបស់សមាជិកអង្គការពាណិជ្ជកម្មពិភពលោក[16]

ជាទូទៅ វិវាទកើតមានឡើងនៅពេលដែលមានសមាជិកណាមួយ បានអនុម័តវិធានច្បាប់ ឬក៏គោលនយោបាយពាណិជ្ជកម្មណាមួយ ដែលសមាជិកដទៃផ្សេងទៀតចាត់ទុកថាមិនស្រប ជាមួយនឹងកាតព្វកិច្ចដែលបានកំណត់ក្នុងកិច្ចព្រមព្រៀងរបស់អង្គការ។ នៅក្នុងករណីនេះ សមាជិក ណាដែលមិនពេញចិត្តនឹងវិធានច្បាប់ដែលបានបង្កើតឡើងនោះ មានសិទ្ធិពឹងផ្អែកលើនីតិវិធី និង បទបញ្ញត្តិនៃប្រព័ន្ធដោះស្រាយវិវាទនេះ ដើម្បីធ្វើការតវ៉ាចំពោះវិធានច្បាប់នោះ។ ប្រសិនបើភាគី វិវាទ មិនអាចឈានទៅរកដំណោះស្រាយរួមគ្នាទេ ការតវ៉ារបស់ភាគីដើមបណ្តឹងទៅលើវិធាននោះ នឹងត្រូវបានដាក់ចូលទៅកាន់អង្គភាពឯករាជ្យគឺ គណៈវិនិច្ឆ័យនិងអង្គភាពឧទ្ធរណ៍ដើម្បីធ្វើការពិនិត្យ និងដោះស្រាយ ដែលនេះជាការធានានូវសិទ្ធិរបស់សមាជិក នៅក្នុងនីតិវិធីជាមូលដ្ឋានរបស់ប្រព័ន្ធ ដោះស្រាយវិវាទនេះ។ ករណីមួយទៀត ប្រសិនបើភាគីដើមបណ្តឹង ជាអ្នកឈ្នះក្តី នោះតម្រូវឲ្យមាន ការដកចេញនូវវិធានពាណិជ្ជកម្ម ដែលត្រូវបានរកឃើញថាមិនស្របទៅនឹងកិច្ចព្រមព្រៀង WTO នោះភាគីចាញ់ក្តីមានកាតព្វកិច្ចត្រូវដកចេញនូវវិធាននោះ ឧទាហរណ៍ នៅក្នុងករណីវិវាទលេខ DS406 រវាងប្រទេសឥណ្ឌូនេស៊ី និងសហរដ្ឋអាមេរិក ពាក់ព័ន្ធនឹងវិធានច្បាប់អាមេរិកដែលធ្វើការ ហាមឃាត់ការនាំចូល និងប្រើប្រាស់នូវបារី Clove របស់ឥណ្ឌូនេស៊ីនៅក្នុងទឹកដីសហរដ្ឋអាមេរិក អាមេរិកដែលជាភាគីចាញ់ក្តីយល់ព្រមធ្វើការកែប្រែនូវវិធានរបស់ខ្លួន ដើម្បីកុំអោយវិធានរបស់ខ្លួន មិនស្របទៅនឹងមាត្រា២នៃកិច្ចព្រមព្រៀងTBT ពាក់ព័ន្ធនឹងកាតព្វកិច្ចស្តីពីប្រព្រឹត្តកម្មចំពោះជាតិ ព្រោះថា វិធានច្បាប់របស់ខ្លួនបានផ្តល់ភាពអនុគ្រោះដល់បារីcloveតិចជាងបារីMenthol។ ជាមួយគ្នា នេះដែរ ក៏អាចមានផងដែរការផ្តល់នូវសំណងការខូចខាត ការដាក់ចេញនូវវិធានច្បាប់ថ្មីដែលផ្ទុយ

[16] Dispute Settlement System Training Module [ មេរៀនបណ្តុះបណ្តាលស្តីពីប្រព័ន្ធដោះស្រាយវិវាទ], https://www.wto.org/english/tratop_e/dispu_e/disp_settlement_cbt_e/signin_e.htm (ចូលអាន និងទាញយក ថ្ងៃទី 5 ឧសភា 2015)។

នឹងវិធានច្បាប់ដែលត្រូវបានដកចេញ ឬការព្យួរនូវសិទ្ធិ និងកាតព្វកិច្ចរបស់សមាជិកដែលបំពានលើកាតព្វកិច្ចដូចមានចែងក្នុងកិច្ចព្រមព្រៀង ដើម្បីជាការឆ្លើយតបចំពោះការរំលោភបំពានលើកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក។

ស្របជាមួយគ្នានេះ ប្រព័ន្ធនេះក៏មានសារៈសំខាន់ដូចគ្នាចំពោះភាគីដែលវិធានច្បាប់របស់ខ្លួនត្រូវបានគេតវ៉ាផងដែរ ដោយក្នុងនោះប្រព័ន្ធនេះបានផ្តល់នូវវេទិកាមួយសម្រាប់ឲ្យភាគីនោះ ឬហៅថា ចុងចម្លើយ ក្នុងការការពារខ្លួនក៏ដូចជាវិធានច្បាប់របស់ខ្លួន ប្រសិនបើបដិសេធចំពោះការលើកឡើងរបស់ភាគីដើមបណ្តឹង។ មួយវិញទៀត វិធានរបស់អង្គភាពដែលពាក់ព័ន្ធដូចជា អង្គភាពដោះស្រាយវិវាទ អង្គភាពឧទ្ធរណ៍ គណៈវិនិច្ឆ័យ និងមជ្ឈត្តករជាដើម ត្រូវតែឆ្លុះបញ្ចាំងព្រមទាំងអនុវត្តដោយត្រឹមត្រូវនូវសិទ្ធិ និងកាតព្វកិច្ចដែលមានកំណត់នៅក្នុងកិច្ចព្រមព្រៀង WTO។ អង្គភាពទាំងនេះ មិនត្រូវផ្លាស់ប្តូរច្បាប់របស់អង្គការដែលអនុវត្តរវាងភាគី បន្ថែម ឬលុបចោលនូវសិទ្ធិ និងកាតព្វកិច្ចដែលកំណត់នៅក្នុងកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោកឡើយ។

ដូច្នេះ ប្រព័ន្ធដោះស្រាយវិវាទនេះ ផ្តល់នូវយន្តការមួយ ដែលតាមរយៈនេះ សមាជិកអង្គការពាណិជ្ជកម្មពិភពលោកត្រូវបានធានាថា សិទ្ធិរបស់គេក្រោមកិច្ចព្រមព្រៀងអាចត្រូវបានធានា និងមិនត្រូវបានសមាជិកដទៃទៀតរំលោភបំពាន។

### **១.៣.១.៣. បកស្រាយបទបញ្ញត្តិនៅក្នុងកិច្ចព្រមព្រៀងនានា ដែលពាក់ព័ន្ធនឹងកិច្ចការពាណិជ្ជកម្មអន្តរជាតិក្នុង** WTO[17]

ជាការពិត វិសាលភាពនៃសិទ្ធិ និងកាតព្វកិច្ចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង WTO មិនមែនអាចកំណត់បានយ៉ាងច្បាស់ដោយគ្រាន់តែអាននូវអត្ថបទច្បាប់នោះទេ ពោលគឺត្រូវទាមទារនូវការបកស្រាយយ៉ាងច្បាស់លាស់។ ជាទូទៅ បទបញ្ញត្តិច្បាប់ត្រូវបានគេព្រាងឡើងនៅក្នុងន័យទូទៅ ដើម្បីអាចអនុវត្តបានជាទូទៅ និងគ្របដណ្តប់នូវពហុភាពនៃករណីនីមួយៗ ដោយវាមិនអាចត្រូវបានយកមកចែងជាវិធានពិសេសជាក់លាក់សម្រាប់គ្រប់ករណីទាំងអស់នោះទេ។ ដូចគ្នាដែរ បទបញ្ញត្តិច្បាប់នៅក្នុងកិច្ចព្រមព្រៀងអន្តរជាតិ ជាទូទៅមានការខ្វះខាតនូវភាពច្បាស់លាស់ ព្រោះថាវាកើតចេញពីការចរចាពហុភាគីដែលមានការសម្របសម្រួលគ្នាទៅវិញទៅមក។ អ្នកចូលរួមនៅក្នុងដំណើរការចរចា ជាញឹកញាប់ធ្វើការសម្រុះសម្រួលគ្នាទៅលើជំហរផ្សេងៗគ្នារបស់ពួកគេ ដើម្បីធ្វើ

[17] Dispute Settlement System Training Module [ មេរៀនបណ្តុះបណ្តាលស្តីពីប្រព័ន្ធដោះស្រាយវិវាទ], https://www.wto.org/english/tratop_e/dispu_e/disp_settlement_cbt_e/signin_e.htm (ចូលអាន និងទាញយក ថ្ងៃទី 5 ឧសភា 2015)។

ការយល់ព្រមទៅលើអត្ថបទច្បាប់មួយដែលអាចយល់បានច្រើនជាងមួយបែប និងដើម្បីបំពេញនូវតម្រូវការរបស់អ្នកដែលបានចូលរួមនៅក្នុងការចរចា។ ការណ៍នេះធ្វើឲ្យអ្នកចរចាយល់នូវបទបញ្ញត្តិពិសេសមួយក្នុងរបៀបផ្សេងៗគ្នា និងផ្ទុយគ្នាជាដើម។ ដូច្នេះហើយ នៅក្នុងករណីភាគច្រើន ដើម្បីដឹងថាសកម្មភាពមួយ មានការរំលោភបំពានលើបទបញ្ញត្តិនៃច្បាប់ឬអត់នោះ ទាល់តែមានការបកស្រាយនូវបទបញ្ញត្តិដែលចោទជាបញ្ហានោះ។

ទាក់ទងនឹងការបកស្រាយច្បាប់នេះ មានការយល់ថា ការបកស្រាយនោះមិនអាចកើតមានទេនៅក្នុងដំណើរការដោះស្រាយវិវាទរបស់អង្គការ WTO ពីព្រោះថាកិច្ចព្រមព្រៀងបង្កើតអង្គការពាណិជ្ជកម្មពិភពលោកបានកំណត់ថា មានតែសន្និសីទថ្នាក់រដ្ឋមន្ត្រី និងអគ្គក្រុមប្រឹក្សានៃអង្គការពាណិជ្ជកម្មពិភពលោក ដែលមានសមត្ថកិច្ចផ្តាច់មុខក្នុងការធ្វើការបកស្រាយកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ DSU បានបញ្ជាក់ថា ប្រព័ន្ធដោះស្រាយវិវាទនេះ មានគោលបំណងបញ្ជាក់ឲ្យច្បាស់លាស់នូវបទបញ្ញត្តិនៃកិច្ចព្រមព្រៀង WTO ស្របតាមវិធានទំនៀមទម្លាប់នៃការបកស្រាយច្បាប់អន្តរជាតិសាធារណៈ ទើប DSU បានទទួលស្គាល់នូវតម្រូវការនៃការបកស្រាយបញ្ជាក់ឲ្យច្បាស់អំពីវិធានរបស់អង្គការពាណិជ្ជកម្មពិភពលោក ស្របទៅតាមវិធានទំនៀមទម្លាប់នៃការបកស្រាយ ហើយបានកំណត់ថា គណៈវិនិច្ឆ័យអាចធ្វើការបកស្រាយច្បាប់បាន។[18] ដូចនេះ ការបកស្រាយច្បាប់នេះមានពីរ គឺការបកស្រាយច្បាប់ដែលធ្វើឡើងដោយសមត្ថកិច្ចផ្តាច់មុខរបស់ស្ថាប័នដែលមានសមត្ថកិច្ច ហើយដែលមានសុពលភាពជាទូទៅសម្រាប់សមាជិកអង្គការពាណិជ្ជកម្មពិភពលោក និងការបកស្រាយច្បាប់ដោយគណៈវិនិច្ឆ័យ និងអង្គភាពឧទ្ធរណ៍ ដែលអាចអនុវត្តបានចំពោះតែភាគី និងបញ្ហាប្រធានបទនៃវិវាទប៉ុណ្ណោះ។[19]

ចំពោះរបៀបនៃការបកស្រាយ ដូចដែលបានបញ្ជាក់ពីខាងលើ DSUកំណត់ថាការបកស្រាយត្រូវធ្វើតាមវិធានទំនៀមទម្លាប់នៃការបកស្រាយនៃច្បាប់អន្តរជាតិសាធារណៈ។ ប៉ុន្តែដោយសារតែវិធានទំនៀមទម្លាប់អន្តរជាតិជាធម្មតា មិនត្រូវបានគេសរសេរ ដូច្នេះហើយ មានអនុសញ្ញាអន្តរជាតិមួយ ដែលកំណត់អំពីវិធានទំនៀមទម្លាប់នៃការបកស្រាយសន្ធិសញ្ញាទាំងនេះ នោះគឺមាត្រា ៣១ ៣២ និង៣៣ នៃអនុសញ្ញាទីក្រុងវីយ៉ែនស្តីពីច្បាប់សន្ធិសញ្ញា។

[18] Understanding on rules and procedures governing the settlement of dispute or dispute settlement understanding (ពីពេលនេះទៅហៅថា DSU), 1995, មាត្រា 17 ចំណុច 6 ។

[19] កិច្ចព្រមព្រៀងបង្កើតអង្គការពាណិជ្ជកម្មពិភពលោក, 1995, មាត្រា 9 ចំណុច 2។

## ១.៣.២. កម្មវត្ថុនៃប្រព័ន្ធដោះស្រាយវិវាទ

### ១.៣.២.១. ស្វែងរកដំណោះស្រាយដែលមានការព្រមព្រៀងទទួលយកពីសំណាក់ភាគី[20]

ទោះបីជាប្រព័ន្ធដោះស្រាយវិវាទ មានគោលបំណងរក្សានូវសិទ្ធិរបស់សមាជិកដែលមានការមិនពេញចិត្តនឹងវិធានច្បាប់ណាមួយដែលត្រូវបានបង្កើតឡើង និងបញ្ជាក់បកស្រាយនូវវិសាលភាពនៃសិទ្ធិ និងកាតព្វកិច្ច ក្នុងគោលដៅសម្រេចឲ្យបាននូវសុវត្ថិភាព និងភាពអាចព្យាករណ៍ទុកបានកម្រិតខ្ពស់ក្នុងពាណិជ្ជកម្មអន្តរជាតិក៏ដោយ ក៏កម្មវត្ថុចំបងរបស់ប្រព័ន្ធនេះ គឺមិនបង្កើតនូវវិធាន ឬយុត្តាធិការដែលធ្វើការបង្ខំឲ្យភាគីទទួលយកនោះទេ ប៉ុន្តែមានគោលបំណងធ្វើការដោះស្រាយវិវាទ តាមរយៈការស្វែងរកនូវដំណោះស្រាយមួយ ដែលមានការព្រមព្រៀងទៅវិញទៅមករវាងគូភាគី ហើយស្របតាមកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោកផងដែរ។ ការជំនុំជម្រះកាត់សេចក្តីនឹងធ្វើឡើង នៅពេលដែលភាគីមិនអាចពិភាក្សាគ្នាស្វែងរកនូវដំណោះស្រាយមួយដែលអាចទទួលយកបានទាំងសងខាងតែប៉ុណ្ណោះ។ តាមរយៈកម្មវត្ថុនេះហើយ ទើបមានការតម្រូវឲ្យមាននូវការប្រឹក្សា ដែលជាដំណាក់កាលដំបូងនៃការដោះស្រាយវិវាទ ហើយ DSU បានកំណត់ថាភាគីវិវាទ យ៉ាងហោចណាស់ត្រូវព្យាយាមចរចាដោះស្រាយជាមុនសិន។ ម្យ៉ាងទៀត សូម្បីតែនៅពេលដែលរឿងក្តីឈានចូលដល់ដំណាក់កាលនៃការជំនុំជម្រះក៏ដោយ ក៏ការដោះស្រាយទ្វេភាគីនៅតែអាចធ្វើទៅបាន ហើយភាគីនៅតែត្រូវបានលើកទឹកចិត្តអោយប្រឹងប្រែងធ្វើការដោះស្រាយតាមរយៈការចរចាដដែល។

### ១.៣.២.២. ការដោះស្រាយវិវាទប្រកបដោយភាពត្រឹមត្រូវ[21]

DSU បានបញ្ជាក់ថា ការដោះស្រាយវិវាទដោយត្រឹមត្រូវ គឺមានសារៈសំខាន់ណាស់ ដើម្បីឲ្យអង្គការពាណិជ្ជកម្មពិភពលោកបំពេញតួនាទីប្រកបដោយប្រសិទ្ធិភាព ហើយធានានូវតុល្យភាពរវាងសិទ្ធិ និងកាតព្វកិច្ចរវាងសមាជិករបស់អង្គការ ដោយមិនមានការលំអៀងថា ប្រទេសជាភាគីវិវាទជាប្រទេសអភិវឌ្ឍន៍ ប្រទេសកំពុងអភិវឌ្ឍន៍ ប្រទេសអភិវឌ្ឍន៍តិចតួច ប្រទេសមហាអំណាច ឬប្រទេសតូចតាចឡើយ។ ជាក់ស្តែង បញ្ហាវិវាទលេខ DS406 ដែលចាប់ផ្តើមថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១០ រវាងប្រទេសឥណ្ឌូនេស៊ីដែលជាដើមបណ្តឹង និងសហរដ្ឋអាមេរិកដែលជាចុងចម្លើយ លើបញ្ហាពាក់ព័ន្ធនិងបារី clove របស់ឥណ្ឌូនេស៊ីដែលនាំចូលក្នុងសហរដ្ឋអាមេរិក។ ប្រទេសឥណ្ឌូនេស៊ី

---

[20] Dispute Settlement System Training Module [ មេរៀនបណ្តុះបណ្តាលស្តីពីប្រព័ន្ធដោះស្រាយវិវាទ], https://www.wto.org/english/tratop_e/dispu_e/disp_settlement_cbt_e/signin_e.htm (ចូលអាន និងទាញយក ថ្ងៃទី 5 ឧសភា 2015)។

[21] ដូច 20។

បានធ្វើការប្តឹងតវ៉ាទៅលើបទបញ្ញត្តិច្បាប់ស្តីពីការគ្រប់គ្រងថ្នាំជក់ ដើម្បីបង្ការការជក់បារីក្នុងគ្រួសារ ឆ្នាំ២០០៩របស់សហរដ្ឋអាមេរិក ដែលធ្វើការហាមឃាត់បារី clove របស់ឥណ្ឌូនេស៊ី។ ឥណ្ឌូនេស៊ី បានលើកឡើងថា នៅក្នុងផ្នែក៩០៧នៃច្បាប់នេះ បានធ្វើការហាមខាត់នូវការផលិត ឬលក់នូវបារី ដែលមានសារធាតុញៀនដូចជា បារី clove ប៉ុន្តែអនុញ្ញាតចំពោះបារីផ្សេងទៀតរួមទាំងបារីដែលមាន ជាតិម៉ង់តុល (Menthol)។ ការណ៍នេះធ្វើអោយឥណ្ឌូនេស៊ីអះអាងថា បទបញ្ញត្តិផ្នែក៩០៧នេះ មិន ស្របទៅនឹងមាត្រា៣ ចំណុច ៤ នៃ GATT១៩៤៧ មាត្រា២ នៃកិច្ចព្រមព្រៀង TBT និងបទបញ្ញតិ ជាច្រើនទៀតនៃកិច្ចព្រមព្រៀង SPS។ ទីបំផុតទៅការដោះស្រាយវិវាទនៅក្នុងអង្គការ WTO បានរក ឃើញថា ការហាមឃាត់របស់អាមេរិកនោះគឺពិតជាមិនស្របទៅនឹងមាត្រា ២ នៃកិច្ចព្រមព្រៀង TBT ពាក់ព័ន្ធនឹងកាតព្វកិច្ចស្តីពីប្រព្រឹត្តកម្មចំពោះជាតិ ព្រោះថា វាផ្តល់ភាពអនុគ្រោះដល់បារី clove តិចជាងបារី Menthol។ ដូចនេះ ប្រទេសឥណ្ឌូនេស៊ីគឺជាភាគីឈ្នះក្តីក្នុងរឿងក្តីនេះ ដែលវាសបញ្ជាក់ ឲ្យការឃើញថា ប្រព័ន្ធដោះស្រាយវិវាទនេះបំពេញបានកម្មវត្ថុនៃការដោះស្រាយវិវាទប្រកបដោយ ភាពត្រឹមត្រូវ ដោយមិនមានភាពលំអៀងរវាងប្រទេសមហាអំណាចដូចជាសហរដ្ឋអាមេរិក និង ប្រទេសផ្សេងទៀតដូចជាឥណ្ឌូនេស៊ីឡើយ។

ដើម្បីធានាបាននូវការដោះស្រាយវិវាទប្រកបដោយភាពត្រឹមត្រូវនេះដែរ DSU បានដាក់ ចេញនូវធាតុលំអិតសំខាន់ៗដែលនីតិវិធីនៃការដោះស្រាយវិវាទត្រូវគោរពតាម ដែលនីតិវិធីលំអិត នេះត្រូវបានបង្កើតដើម្បីសម្រេចបានប្រសិទ្ធិភាពនៃការដោះស្រាយ និងរួមបញ្ចូលនូវសិទ្ធិរបស់ដើម បណ្តឹង ក្នុងការឈានទៅមុខជាមួយនឹងការតវ៉ារបស់ខ្លួន បើទោះបីជាគ្មានការយល់ព្រម ឬឆ្លើយតប ពីចុងចម្លើយក៏ដោយ។ ជាមួយគ្នានេះដែរ DSU ក៏បានធ្វើការកំណត់ផងដែរនៅក្នុងឧបសម្ព័ន្ធ ៣ ស្តី ពីនីតិវិធីការងារ នូវរយៈពេលសមស្របសម្រាប់ដំណាក់កាលនៃការដោះស្រាយនីមួយៗ ជៀសវាង ការអូសបន្លាយពេលវេលាដោយមិនសមហេតុផល។ ជាក់ស្តែង ប្រសិនបើរឿងក្តីឈានទៅដល់ ដំណាក់កាលនៃការជំនុំជម្រះ ជាធម្មតាវាត្រូវការពេលមិនលើសពី១ឆ្នាំទេ សម្រាប់គណៈវិនិច្ឆ័យ ដឹកនាំនីតិវិធី និងមិនលើសពី១៦ខែប្រសិនបើរឿងក្តីត្រូវបានប្តឹងឧទ្ធរណ៍។ បន្ថែមលើនេះទៀត ប្រសិនបើដើមបណ្តឹងចង់ឲ្យរឿងក្តីដំណើរការលឿន ការពិចារណាលើរឿងក្តីគួរចំណាយពេលវេលា ឲ្យតិចជាងនេះទៀត។

ទាក់ទងនឹងពេលវេលានេះផងដែរ អំឡុងពេលទាំងនេះអាចនឹងបន្តវែងឆ្ងាយទៀត ព្រោះថា គេត្រូវការពេលវេលាសម្រាប់អនុវត្តទៀត បន្ទាប់ពីដំណើរការរឿងក្តីបានបញ្ចប់។ មួយវិញទៀត យើងដឹងហើយថា ជាទូទៅភាគីត្រូវដាក់នូវទិន្នន័យ និងឯកសារសំខាន់ៗដែលទាក់ទងទៅនឹងរឿង

ក្តី ព្រមទាំងការអះអាងផ្លូវច្បាប់ ដូចនេះភាគីត្រូវការពេលវេលាដើម្បីរៀបចំនូវការអះអាងអង្គហេតុ និងអង្គច្បាប់ទាំងនោះ ព្រមទាំងរៀបចំសេចក្តីឆ្លើយតបទៅនឹងភាគីម្ខាងទៀត។ បន្ថែមលើនេះទៀត គណៈវិនិច្ឆ័យ និងអង្គភាពឧទ្ធរណ៍ ក៏ត្រូវធ្វើការពិនិត្យពិចារណាលើភស្តុតាង និងសេចក្តីអះអាង ទាំងអស់របស់ភាគី ហើយប្រសិនបើអាចទៅរួចត្រូវស្តាប់យោបល់របស់អ្នកជំនាញ ហើយធ្វើការ ទាញរកហេតុផលលំអិតដើម្បីគាំទ្រនូវសេចក្តីសន្និដ្ឋានរបស់ខ្លួន ដែលកិច្ចការទាំងអស់នេះសុទ្ធតែ ត្រូវការពេលវេលា ក៏ប៉ុន្តែវាបានធានានូវភាពត្រឹមត្រូវនៃការដោះស្រាយវិវាទ។ ដោយពិចារណាលើ ចំណុចទាំងអស់នេះ ប្រព័ន្ធដោះស្រាយវិវាទរបស់អង្គការពាណិជ្ជកម្មពិភពលោក បំពេញនូវតួនាទី បានឆាប់រហ័សជាងប្រព័ន្ធយុត្តាធិការក្នុងស្រុកជាច្រើន ឬក៏ប្រព័ន្ធដោះស្រាយវិវាទជាអន្តរជាតិផ្សេង ទៀត។

**១.៣.២.៣. ហាមឃាត់ការសម្រេចសេចក្តីដោយឯកតោភាគី**[22]

សមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក បានព្រមព្រៀងគ្នាប្រើប្រាស់ប្រព័ន្ធពហុភាគី សម្រាប់ការដោះស្រាយវិវាទពាណិជ្ជកម្មរបស់ពួកគេនៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក ជាជាង ការប្រើប្រាស់សកម្មភាពឯកតោភាគីក្នុងការដោះស្រាយវិវាទ នេះមានន័យថាការដោះស្រាយវិវាទ ត្រូវតែប្រកាន់ភ្ជាប់នូវនីតិវិធី និងគោរពវិធានដែលមានការព្រមព្រៀងគ្នា។

ប្រសិនបើសមាជិកអង្គការធ្វើសកម្មភាពឯកតោភាគីក្នុងការដោះស្រាយនូវបញ្ហានោះ វានឹង នាំមកនូវគុណវិបត្តិយ៉ាងជាក់ស្តែង។ ឧទាហរណ៍ប្រសិនបើសមាជិកមួយបានចោទប្រកាន់សមាជិក មួយទៀតពីការបំពានវិធានរបស់អង្គការពាណិជ្ជកម្មពិភពលោក ហើយប្រសិនបើភាគីជ្រើសរើស យកសកម្មភាពឯកតោភាគីដោះស្រាយបញ្ហា នោះសមាជិកដើមចោទដែលធ្វើការតវ៉ាអាចធ្វើការ ឆ្លើយតបជាឯកតោភាគីដោយសម្រេចបង្កើតនូវវិធានច្បាប់មួយថ្មី ផ្ទុយទៅនឹងវិធានច្បាប់ដែលខ្លួន បានធ្វើការតវ៉ានោះ។ នៅក្រោមច្បាប់ទំនៀមទំលាប់អន្តរជាតិ សមាជិកដើមចោទអាចអះអាងថា គេធ្វើសកម្មភាពដោយស្របច្បាប់ពីព្រោះសកម្មភាពរបស់គេ គឺឆ្លើយតបទៅនឹងការរំលោភបំពាន ច្បាប់របស់សមាជិកផ្សេងទៀតដែលបានកើតឡើងមុន។ បន្ថែមលើនេះ ប្រសិនបើសមាជិកដែល ត្រូវបានគេចោទប្រកាន់ប្រកែកថា វិធានរបស់គេមិនល្មើសនឹងកាតព្វកិច្ចក្នុងអង្គការពាណិជ្ជកម្ម ពិភពលោក គេនឹងមិនទទួលស្គាល់នូវវិធានផ្ទុយដែលកើតឡើងក្រោយនោះឡើយ។ ផ្ទុយមកវិញ គេអាចធ្វើការអះអាងថា វិធានច្បាប់ដែលផ្ទុយនឹងវិធានច្បាប់របស់គេ ហើយដែលកើតឡើងក្រោយ

[22] Dispute Settlement System Training Module [ មេរៀនបណ្តុះបណ្តាលស្តីពីប្រព័ន្ធដោះស្រាយវិវាទ], https://www.wto.org/english/tratop_e/dispu_e/disp_settlement_cbt_e/signin_e.htm (ចូលអាន និងទាញយក ថ្ងៃទី 5 ឧសភា 2015)។

នោះជាវិធានដែលខុសច្បាប់ និងកាតព្វកិច្ចជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក ហើយដោយឈរលើមូលដ្ឋាននេះដដែល គេនឹងយល់ថាត្រឹមត្រូវក្នុងការយកវិធានផ្ទុយមួយទៀតប្រឆាំងនឹងវិធានផ្ទុយទីមួយ។ អ្នកដែលធ្វើការតវ៉ាពីដំបូង ដោយផ្អែកលើទស្សនៈផ្លូវច្បាប់របស់គេលើបញ្ហាដែលកើតឡើង អាចនឹងប្រកែកនឹងវិធានផ្ទុយទីពីរនោះ ហើយចាត់ទុកវិធានផ្ទុយទីពីរនេះថាខុសច្បាប់។ ជាការឆ្លើយតបមកវិញ គេអាចនឹងបង្កើតនូវវិធានផ្ទុយបន្ថែមទៀត។ នេះសបង្ហាញឲ្យឃើញថា ប្រសិនបើមានទស្សនៈយល់ឃើញខុសគ្នាហើយនោះ សកម្មភាពឯកតោភាគីពិតជាមិនអាចដោះស្រាយវិវាទដោយសន្តិភាពបានទេ។ បន្ថែមលើនេះទៀត រឿងរ៉ាវនឹងមិនអាចគ្រប់គ្រងបាន ប្រសិនបើគ្មានភាគីណាមួយព្រមដកថយ នោះមហន្តរាយក្នុងការធ្វើពាណិជ្ជកម្មទ្វេភាគីនឹងកើតមាន និងដែលអាចនឹងនាំឲ្យមានសង្គ្រាមពាណិជ្ជកម្ម។ អាស្រ័យហេតុនេះហើយ ទើបគេបង្កើតនូវប្រព័ន្ធដោះស្រាយវិវាទនេះឡើង ក្នុងគោលបំណងធ្វើការហាមឃាត់នូវការសម្រេចសេចក្តីដោយឯកតោភាគីរបស់ភាគីនៃវិវាទ។ ដូចនេះ សមាជិកមិនអាចធ្វើសកម្មភាពដោយផ្អែកលើការសម្រេចសេចក្តីជាឯកតោភាគីឡើយ ប៉ុន្តែគេអាចត្រឹមធ្វើសកម្មភាពពឹងផ្អែកលើការដោះស្រាយវិវាទក្រោមវិធាន និងនីតិវិធីនៃ DSU។

### ១.៣.៣. លក្ខណៈសម្គាល់នៃប្រព័ន្ធដោះស្រាយវិវាទ

#### ១.៣.៣.១. យុត្តាធិការផ្តាច់មុខ

ដោយពឹងផ្អែកលើប្រព័ន្ធពហុភាពនៃការដោះស្រាយវិវាទរបស់ WTO ប្រព័ន្ធនេះមិនត្រឹមតែបានដកចេញនូវសកម្មភាពឯកតោភាគីនោះទេ វាថែមទាំងច្រានចោលជាមុនផងដែរនូវការប្រើប្រាស់ទម្រង់ផ្សេងៗ សម្រាប់ការដោះស្រាយដែលទាក់ទងនឹងអង្គការ WTO ដោយតម្រូវឲ្យប្រទេសជាសមាជិករបស់ WTO ទាំងអស់ត្រូវពឹងផ្អែកលើវិធាន និងនីតិវិធីដូចមានកំណត់ក្នុង DSU នៅក្នុងការតវ៉ាចំពោះការរំលោភបំពានលើកាតព្វកិច្ច ការធ្វើឲ្យខូចខាតនូវផលប្រយោជន៍ ដូចមានកំណត់នៅក្នុងកិច្ចព្រមព្រៀងដែលពាក់ព័ន្ធ ឬការរារាំងចំពោះការសម្រេចឲ្យបាននូវកម្មវត្ថុនៃកិច្ចព្រមព្រៀងទាំងអស់នោះ។[23]

#### ១.៣.៣.២. លក្ខណៈចាប់បង្ខំ

ប្រព័ន្ធដោះស្រាយវិវាទនេះគឺមានលក្ខណៈចាប់បង្ខំ។ សមាជិករបស់អង្គការ WTO ទាំងអស់ត្រូវទទួលយកវា ព្រោះតែប្រទេសទាំងនោះបានចុះហត្ថលេខា និងបានផ្តល់សច្ចាប័នលើកិច្ចព្រម

[23] DSU, 1995, មាត្រា 23 ។

ព្រៀងអង្គការពាណិជ្ជកម្មពិភពលោកដែលក្នុងនោះ DSU ក៏ជាផ្នែកមួយផងដែរ។ DSU ដាក់សមាជិកអង្គការ WTO ទាំងអស់នៅក្រោមប្រព័ន្ធដោះស្រាយវិវាទនេះ សម្រាប់រាល់វិវាទទាំងអស់ដែលកើតឡើងក្រោមកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក។ ដូច្នេះ ផ្ទុយពីប្រព័ន្ធដោះស្រាយវិវាទអន្តរជាតិផ្សេងទៀត វាមិនចាំបាច់ឲ្យភាគីវិវាទទទួលយកយុត្តាធិការនៃប្រព័ន្ធដោះស្រាយវិវាទរបស់អង្គការពាណិជ្ជកម្មពិភពលោក នៅក្នុងសេចក្តីប្រកាសទទួលស្គាល់ ឬកិច្ចព្រមព្រៀងដាច់ដោយឡែកណាមួយនោះទេ។ ការយល់ព្រមទទួលនូវយុត្តាធិការនៃប្រព័ន្ធដោះស្រាយវិវាទរបស់អង្គការពាណិជ្ជកម្មពិភពលោក គឺមានហើយជាស្រេចនៅពេលដែលចូលរួមជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក។ ជាលទ្ធផល រាល់សមាជិកអាចប្រើប្រាស់ប្រព័ន្ធដោះស្រាយវិវាទនេះ ហើយគ្មានសមាជិកដែលជាចុងចម្លើយណាមួយ អាចគេចពីយុត្តាធិការនេះឡើយ។

### ១.៣.៣.៣. លក្ខខណ្ឌបណ្តឹងដែលស្ថិតក្នុងសមត្ថកិច្ចរបស់ប្រព័ន្ធដោះស្រាយវិវាទ

ជាទូទៅ វិវាទកើតមានឡើងនៅពេលដែលប្រទេសមួយដាក់ចេញនូវវិធានពាណិជ្ជកម្ម ឬធ្វើសកម្មភាពអ្វីមួយ ដែលសមាជិកដទៃទៀតរបស់អង្គការពាណិជ្ជកម្មពិភពលោកចាត់ទុកថា ជាការរំលោភបំពានទៅលើកិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោក ឬជាការខកខានមិនបានបំពេញនូវកាតព្វកិច្ចរបស់ខ្លួន។[24] តាមរយៈនេះ គេអាចកំណត់បានថា មានតែវិវាទដែលកើតមានរវាងសមាជិកអង្គការពាណិជ្ជកម្មពិភពលោក និងដែលពាក់ព័ន្ធទៅនឹងកិច្ចព្រមព្រៀងនានាទាក់ទងនិងការធ្វើពាណិជ្ជកម្មក្នុងក្របខណ្ឌអង្គការWTOប៉ុណ្ណោះ ដែលអាចដាក់ចូលទៅក្នុងប្រព័ន្ធដោះស្រាយវិវាទនេះ ដើម្បីធ្វើការដោះស្រាយជូនភាគីវិវាទបាន។

ដូចនេះ គេអាចកំណត់បានអំពីលក្ខខណ្ឌបណ្តឹង ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ប្រព័ន្ធដោះស្រាយវិវាទនេះដូចខាងក្រោម៖

**លក្ខខណ្ឌភាគីបណ្តឹង៖** យោងតាម DSU បុគ្គលដែលមានសមត្ថភាពក្លាយជាភាគីនៃបណ្តឹង និងធ្វើសកម្មភាពបណ្តឹងដាក់ចូលអង្គការ WTO គឺមានតែរដ្ឋជាសមាជិករបស់អង្គការតែប៉ុណ្ណោះ ពោលគឺទាំងដើមចោទនិងចុងចម្លើយត្រូវតែជារដ្ឋសមាជិកអង្គការពាណិជ្ជកម្មពិភពលោក។ ចំណែករដ្ឋដែលមិនមែនជាសមាជិក នីតិបុគ្គលសាធារណៈ និងឯកជនផ្សេងទៀត រូបវន្តបុគ្គលជាដើមមិន

[24] *Understanding The WTO: Settling Disputes, A unique contribution* [ការស្វែងយល់ពីអង្គការ WTO : ការដោះស្រាយវិវាទ, ការរួមចំណែកពិសេស], https://www.wto.org/english/thewto_e/whatis_e/tif_e/disp1_e.htm (ចូលអាន និងទាញយក ថ្ងៃទី 15 ឧសភា 2015។

មានសមត្ថភាពជាភាគីនៃបណ្តឹង និងមិនមានសមត្ថភាពធ្វើសកម្មភាពបណ្តឹងទៅកាន់អង្គការ WTO នោះទេ។

**លក្ខខណ្ឌកម្មវត្ថុបណ្តឹង៖** កម្មវត្ថុនៃបណ្តឹងដែលដាក់ចូលទៅក្នុងអង្គការ WTO ត្រូវតែមានជាប់ទាក់ទងនឹងកិច្ចព្រមព្រៀងដែលស្ថិតក្រោមការគ្រប់គ្រងរបស់អង្គការ ហើយធ្វើឡើងរវាងរដ្ឋជាសមាជិករបស់អង្គការ។ ក្នុងនោះវាអាចជាការតវ៉ារបស់រដ្ឋមួយចំពោះការរំលោភបំពានលើកិច្ចព្រមព្រៀងណាមួយរបស់រដ្ឋមួយទៀត ដែលធ្វើអោយខូចខាតដល់ផលប្រយោជន៍របស់រដ្ឋដែលតវ៉ា ហើយដាក់ពាក្យបណ្តឹងទាមទារអោយរដ្ឋដែលបំពានកិច្ចព្រមព្រៀងនោះ វិលមកអនុវត្តតាមកិច្ចព្រមព្រៀងវិញ។ ករណីមួយទៀត គឺកម្មវត្ថុនៃបណ្តឹងមិនមែនជាការតវ៉ាចំពោះការរំលោភបំពានទេ តែជាការតវ៉ាចំពោះការខូចខាតនូវផលប្រយោជន៍ណាមួយ ដែលកើតឡើងដោយសារសកម្មភាពរបស់រដ្ឋមួយ ទោះបីជាវាមិនផ្ទុយទៅនឹងកិច្ចព្រមព្រៀងណាមួយក៏ដោយ។

## ១.៤. តួអង្គពាក់ព័ន្ធនៅក្នុងប្រព័ន្ធដោះស្រាយវិវាទ

នៅក្នុងប្រព័ន្ធដោះស្រាយវិវាទពាណិជ្ជកម្មអន្តរជាតិរបស់អង្គការ WTO មានតួអង្គជាច្រើនដែលពាក់ព័ន្ធដូចជា ភាគីនៃវិវាទ អង្គភាពមួយចំនួនរបស់អង្គការពាណិជ្ជកម្មពិភពលោករួមមានអង្គភាពដោះស្រាយវិវាទ គណៈវិនិច្ឆ័យ អង្គភាពឧទ្ធរណ៍ និងលេខាធិការដ្ឋានអង្គការ WTO។ ក្រៅពីនេះក៏នៅមានបុគ្គលមួយចំនួនទៀតដូចជា អ្នកជំនាញ និងស្ថាប័នជំនាញផ្សេងទៀតដែរ។

### ១.៤.១. ភាគី

ភាគីដែលចូលរួមក្នុងប្រព័ន្ធដោះស្រាយវិវាទនេះ គឺរដ្ឋាភិបាលដែលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក ដែលអាចដើរតួក្នុងនាមជាភាគីនៃវិវាទ ឬជាភាគីទីបី។ លេខាធិការនៃអង្គការ WTO ប្រទេសជាសមាជិកអង្កេតការណ៍របស់អង្គការ WTO អង្គការអន្តរជាតិផ្សេងៗ រដ្ឋាភិបាលតំបន់ ឬរដ្ឋាភិបាលក្នុងស្រុក មិនមានសិទ្ធិចូលរួមក្នុងដំណើរការដោះស្រាយវិវាទក្នុង WTO ឡើយ។ DSU ហៅ សមាជិកដែលនាំវិវាទអោយដោះស្រាយថា ដើមបណ្តឹង ហើយសមាជិកដែលត្រូវគេប្តឹងតវ៉ាលើវិធានរបស់ខ្លួនថា ចុងចម្លើយ។

ដោយហេតុថា មានតែរដ្ឋាភិបាលដែលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក ដែលអាចដាក់វិវាទពាណិជ្ជកម្មអន្តរជាតិនេះអោយដោះស្រាយ ដូចនេះហើយ បុគ្គលឯកជន ឬក្រុមហ៊ុនឯកជន មិនអាចប្រើប្រាស់ប្រព័ន្ធដោះស្រាយវិវាទនេះដោយផ្ទាល់នោះទេ បើទោះបីជាបុគ្គល ឬក្រុមហ៊ុនឯកជនទាំងនោះ ជាក់ស្តែងជាអ្នកនាំចេញ ឬអ្នកនាំចូល ឬជាអ្នកដែលរងផលប៉ះពាល់ដោយ

ផ្ទាល់ពីវិធានដែលរំលោភបំពានលើកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោកក៏ដោយ។ ដូចគ្នាផងដែរ ចំពោះអង្គការក្រៅរដ្ឋាភិបាលផ្សេងៗទៀត ដែលមានផលប្រយោជន៍ទូទៅនៅក្នុងបញ្ហាដែលដាក់ចូលក្នុងប្រព័ន្ធដោះស្រាយវិវាទនោះ។ អង្គការក្រៅរដ្ឋាភិបាលទាំងនោះ មិនអាចចូលរួមនៅក្នុងដំណើរការដោះស្រាយវិវាទរបស់អង្គការពាណិជ្ជកម្មពិភពលោកបានឡើយ បើទោះបីការពិតទៅអង្គការទាំងនេះជាញឹកញាប់មានឥទ្ធិពល ឬអាចដាក់សម្ពាធដល់រដ្ឋាភិបាលដែលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក អោយដាក់វិវាទនោះដំណើរការនៅក្រោមប្រព័ន្ធដោះស្រាយវិវាទនេះក៏ដោយ។ ជាការចាំបាច់ឆ្លើយតបនឹងបញ្ហាលក្ខខណ្ឌភាគីនៃប្រព័ន្ធដោះស្រាយវិវាទនេះ សមាជិកអង្គការពាណិជ្ជកម្មពិភពលោកជាច្រើន បានអនុម័តជាផ្លូវការនូវច្បាប់ផ្ទៃក្នុង ដែលក្នុងនោះអនុញ្ញាតឲ្យភាគីឯកជន អាចដាក់លិខិតស្នើសុំឲ្យរដ្ឋាភិបាលរបស់ពួកគេ ដាក់វិវាទពាណិជ្ជកម្មអន្តរជាតិនោះចូលទៅអង្គការពាណិជ្ជកម្មពិភពលោកតំណាងអោយខ្លួន។

## ១.៤.២.អង្គភាពដោះស្រាយវិវាទ

### ១.៤.២.១. សមាសភាព

អង្គភាពដោះស្រាយវិវាទមានសមាសភាពជាតំណាងនៃប្រទេសទាំងអស់ ដែលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក។ អ្នកតំណាងរដ្ឋាភិបាលទាំងនេះ ភាគច្រើនគឺជាប្រតិភូការទូតដែលជាមន្ត្រីនៃក្រសួងពាណិជ្ជកម្ម ឬក្រសួងការបរទេសនៃប្រទេសសមាជិកដែលខ្លួនតំណាង ហើយដែលមាននិវេសនដ្ឋាននៅក្នុងទីក្រុងហ្សឺណែវ ដែលជាទីតាំងនៃទីស្នាក់ការកណ្តាលរបស់អង្គការពាណិជ្ជកម្មពិភពលោក។ អ្នកតំណាងទាំងនេះទទួលការណែនាំពីស្ថាប័នកណ្តាលរបស់គេរាល់ការប្រកាន់ជំហរ ឬធ្វើសេចក្តីថ្លែងការណ៍ណាមួយនៅក្នុងអង្គភាពដោះស្រាយវិវាទ។ ដូច្នេះហើយទើបអង្គភាពដោះស្រាយវិវាទជាអង្គភាពនយោបាយ។

### ១.៤.២.២. អំពីប្រធានអង្គភាពដោះស្រាយវិវាទ

អង្គភាពដោះស្រាយវិវាទ មានប្រធានផ្ទាល់របស់អង្គភាពដែលជាធម្មតាគឺជ្រើសចេញពីក្នុងចំណោមឯកអគ្គរដ្ឋទូតរបស់ប្រទេសជាសមាជិកអង្គការ WTO នៅក្នុងទីក្រុងហ្សឺណែវ។ ប្រធានត្រូវបានជ្រើសតាំងដោយការសម្រេចជាកុងស៊ុងស៊ុសពីសមាជិកអង្គការ។ ប្រធានមានតួនាទីសំខាន់ៗដូចជា ការផ្តល់ព័ត៌មានទៅកាន់សមាជិក ការដឹកនាំកិច្ចប្រជុំ ការធ្វើការកោះហៅ និងដាក់ចូលនូវចំណុចផ្សេងៗក្នុងរបៀបវារៈរបស់អង្គភាព ការផ្តល់ឱកាសអោយប្រតិភូដែលមានបំណងនិយាយនិងស្នើអ្វីមួយ និងការប្រកាសនូវសេចក្តីសម្រេចដែលស្នើឡើង ប្រសិនបើសេចក្តីសម្រេចនោះត្រូវបានទទួលយកដោយសមាជិកដែលមានវត្តមាននៅក្នុងអង្គប្រជុំ។

បន្ថែមពីលើនេះទៀត ប្រធានអង្គភាពនេះ មានការទទួលខុសត្រូវជាច្រើនទៀត ឧទាហរណ៍ ដោយមានសំណើរបស់ភាគី និងដោយមានការពិភាក្សាជាមួយភាគីវិវាទ ប្រធានធ្វើការកំណត់ពីវិធាន និងនីតិវិធីចំពោះវិវាទដែលមានជាប់ទាក់ទងនឹងកិច្ចព្រមព្រៀងច្រើន ដែលយើងអាចហៅថា វិធាន និងនីតិវិធីពិសេស ឬនីតិវិធីបន្ថែម ប្រសិនបើភាគីមិនអាចព្រមព្រៀងគ្នាអំពីនីតិវិធីនៅក្នុងរយៈពេល២០ថ្ងៃ។ មួយវិញទៀត ប្រសិនបើភាគីមិនយល់ព្រមបញ្ចប់នូវការប្រឹក្សាទេ បន្ទាប់ពីមានការពិភាក្សាជាមួយភាគី ប្រធានអង្គភាពនេះមានសិទ្ធិពន្យារយៈពេលនៃការប្រឹក្សាពាក់ព័ន្ធនឹងវិធានដែលត្រូវបានតវ៉ាថាតើបំពាននឹងកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោកឬទេ ប៉ុន្តែវិធានដែលត្រូវបានតវ៉ានោះត្រូវតែជាវិធានដែលធ្វើឡើងដោយប្រទេសកំពុងអភិវឌ្ឍន៍។ ក្នុងការដោះស្រាយវិវាទដែលពាក់ព័ន្ធនឹងសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច ប្រទេសអភិវឌ្ឍន៍តិចតួចនោះអាចស្នើសុំទៅប្រធានអង្គភាពដោះស្រាយវិវាទឲ្យផ្តល់នូវ Good office ការសម្រុះសម្រួល សន្ធានកម្ម ដល់ខ្លួន មុនពេលដែលរឿងក្តីរបស់ខ្លួនត្រូវបានបញ្ជូនទៅកាន់គណៈវិនិច្ឆ័យ។ សិទ្ធិអំណាចមួយទៀតរបស់ប្រធានអង្គភាពដោះស្រាយវិវាទនោះគឺ អគ្គនាយកអង្គការពាណិជ្ជកម្មពិភពលោកត្រូវប្រឹក្សាជាមួយនឹងប្រធានអង្គភាពនេះជាមុនសិន មុននឹងធ្វើការកំណត់អំពីសមាសភាពរបស់គណៈវិនិច្ឆ័យ ហើយអង្គភាពឧទ្ធរណ៍ត្រូវប្រឹក្សាជាមួយនឹងប្រធានអង្គភាពនេះផងដែរ មុននឹងធ្វើការអនុម័ត ឬវិសោធនកម្មទៅលើនីតិវិធីធ្វើការរបស់ខ្លួន។

### ១.៤.២.៣. តួនាទី និងសិទ្ធិអំណាចរបស់អង្គភាព

អង្គភាពដោះស្រាយវិវាទ មានតួនាទី និងអំណាចដូចខាងក្រោម[25] ៖

-ការបង្កើតនូវគណៈវិនិច្ឆ័យ

-ការអនុម័តនូវសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យ និងអង្គភាពឧទ្ធរណ៍ ព្រមទាំងតាមដានពិនិត្យការអនុវត្តនូវសេចក្តីសម្រេច និងអនុសាសន៍របស់អង្គភាពទាំងនេះ

-មានអំណាចព្យួរសម្បទាន និងកាតព្វកិច្ចដទៃទៀត ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងពាក់ព័ន្ធនឹងកិច្ចការពាណិជ្ជកម្ម។

នៅក្នុងន័យសាមញ្ញ អង្គភាពដោះស្រាយវិវាទ ទទួលខុសត្រូវក្នុងការដាក់វិវាទចូលទៅក្នុងការជំនុំជម្រះ (ការបង្កើតគណៈវិនិច្ឆ័យ) ទទួលខុសត្រូវបង្កើតនូវសេចក្តីសម្រេចដែលមានអានុភាពចាប់បង្ខំ (ការអនុម័តនូវសេចក្តីសម្រេច) ទទួលខុសត្រូវណែនាំអំពីការអនុវត្តនូវសេចក្តីសម្រេចនោះ

[25] DSU, 1995, មាត្រា 2 ចំណុច 1។

ព្រមទាំងមានអំណាចចេញវិធានការតប ក្នុងករណីដែលមានសមាជិកណាមួយមិនអនុវត្តតាមសេចក្តីសម្រេច។

ដើម្បីសម្រេចនូវកិច្ចការ និងបំពេញនូវតួនាទីរបស់ខ្លួន អង្គភាពដោះស្រាយវិវាទធ្វើការប្រជុំញឹកញាប់តាមការចាំបាច់ ដើម្បីឲ្យស្របតាមអំឡុងពេលដែលផ្តល់ឲ្យអង្គភាពសម្រាប់ដំណើរការរឿងក្តី ដូចមានកំណត់ក្នុង DSU។[26] ក្នុងការអនុវត្តជាក់ស្តែង អង្គភាពដោះស្រាយវិវាទមានការប្រជុំទៀតទាត់មួយដងក្នុងមួយខែ ប៉ុន្តែនៅពេលដែលមានសមាជិកណាមួយស្នើសុំ ប្រធានអង្គភាពដោះស្រាយវិវាទអាចកោះហៅប្រជុំពិសេសបន្ថែម។ បុគ្គលិកនៃលេខាធិការដ្ឋានអង្គការ WTO ត្រូវផ្តល់នូវជំនួយរដ្ឋបាលដល់អង្គភាពដោះស្រាយវិវាទ។

### ១.៤.២.៤. ដំណើរការសម្រេចសេចក្តីក្នុងអង្គភាព

វិធានទូទៅក្នុងការសម្រេចសេចក្តីនានាក្នុងអង្គភាពដោះស្រាយវិវាទ គឺត្រូវធ្វើការសម្រេចសេចក្តីដោយកុងស៊ុងស៊ុស។[27] DSU បានកំណត់ថា កុងស៊ុងស៊ុស ត្រូវបានសម្រេចដោយគ្មានសមាជិកណាមួយដែលមានវត្តមាននៅក្នុងកិច្ចប្រជុំធ្វើការជំទាស់ជាផ្លូវការ ចំពោះសេចក្តីសម្រេចដែលបានស្នើឡើង។ នេះមានន័យថា ប្រធានដឹកនាំការប្រជុំមិនចាំបាច់សួរប្រតិភូដែលចូលរួមនីមួយៗថា ពួកគេយល់ស្របទៅនឹងសេចក្តីសម្រេចដែលបានស្នើឡើង ឬអត់នោះឡើយ ហើយក៏មិនមានការបោះឆ្នោតដែរ។ ផ្ទុយទៅវិញ ប្រធានដឹកនាំអង្គប្រជុំគ្រាន់តែសួរថា សេចក្តីសម្រេចនេះអាចអនុម័តបាន ឬទេ ។ ប្រសិនបើគ្មានសមាជិកណាម្នាក់លើកសម្លេងប្រឆាំងនោះ ប្រធានអង្គប្រជុំនឹងប្រកាសថា សេចក្តីសម្រេចនេះត្រូវបានអនុម័ត។ និយាយមួយបែបទៀត ប្រសិនបើសមាជិកណាមួយចង់រារាំងនូវសេចក្តីសម្រេច សមាជិកនោះមានកាតព្វកិច្ចត្រូវមានវត្តមាននៅក្នុងអង្គប្រជុំហើយផ្តល់សញ្ញាប្រឆាំងដល់អង្គប្រជុំ ដោយនៅពេលដែលប្រធានអង្គប្រជុំធ្វើការសួរអំពីការយល់ព្រម សមាជិកនោះត្រូវលើកទង់ជាតិ និងសម្លេងប្រឆាំងរបស់គេ។ សមាជិកណាក៏ដោយ ដែលធ្វើបែបនេះ ទោះបីជាម្នាក់ឯងក៏ដោយក៏អាចរារាំងនូវសេចក្តីសម្រេចដែរ។

ប៉ុន្តែនៅពេលដែលអង្គភាពដោះស្រាយវិវាទ អនុម័តសម្រេចបង្កើតនូវគណៈវិនិច្ឆ័យ ធ្វើការអនុម័តលើសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យ និងអង្គភាពឧទ្ធរណ៍ និងអនុម័តដាក់ចេញនូវវិធានការតបតចំពោះការមិនអនុវត្តតាមសេចក្តីសម្រេច អង្គភាពដោះស្រាយវិវាទនេះធ្វើការអនុម័តដោយមិនទាមទារឲ្យមានកុងស៊ុងស៊ុសពីសំណាក់សមាជិកដែលមានវត្តមានទាំងអស់ឡើយ។ ក៏ប៉ុន្តែ

[26] DSU, 1995, មាត្រា 2 ចំណុច 3។

[27] DSU, 1995, មាត្រា 2 ចំណុច 4។

ប្រសិនបើមានកុងស៊ុងស៊ុសពីសំណាក់សមាជិកទាំងអស់ប្រឆាំងនឹងការអនុម័តនោះ ឬហៅថា កុងស៊ុងស៊ុសបដិសេធ អង្គភាពដោះស្រាយវិវាទមិនអាចធ្វើការអនុម័តបានឡើយ។ ដូចនេះ ជាទូទៅការអនុម័តរបស់អង្គភាពដោះស្រាយវិវាទដូចបានលើកឡើងខាងលើ គឺអាចធ្វើទៅបានដោយស្វ័យប្រវត្តិពីព្រោះថា សមាជិកតែម្នាក់ក៏អាចរារាំងមិនអោយមានកុងស៊ុងស៊ុសបដិសេធបានដែរ ដោយគ្រាន់តែទទូចឲ្យមានការអនុម័តរបស់អង្គភាពដោះស្រាយវិវាទ។

គួរបញ្ជាក់ថា គ្មានសមាជិកណាមួយរួមទាំងភាគីដែលរងផលប៉ះពាល់ និងភាគីមានផលប្រយោជន៍ពាក់ព័ន្ធក្នុងវិវាទ ត្រូវបានដកចេញពីដំណើរការនៅក្នុងការសម្រេចសេចក្តីឡើយ។ ជាក់ស្តែង សមាជិកទាំងនោះអាចស្នើបង្កើតគណៈវិនិច្ឆ័យ ស្នើឲ្យមានការអនុម័តនូវសេចក្តីសម្រេច និងស្នើឲ្យមានចាត់វិធានការតបត ដោយដាក់នូវសំណើនោះនៅក្នុងរបៀបវារៈនៃកិច្ចប្រជុំរបស់អង្គភាពដោះស្រាយវិវាទ ហើយដែលជាទូទៅការស្នើសុំរបស់ពួកគេទទួលបានជោគជ័យ លើកលែងតែមានកុងស៊ុងស៊ុសបដិសេធ។ ផ្ទុយទៅវិញ ប្រសិនបើភាគីណាដែលចង់រារាំងនូវការអនុម័តនានារបស់អង្គភាពដោះស្រាយវិវាទ ភាគីនោះត្រូវបញ្ចុះបញ្ចូលអោយសមាជិកដទៃទៀតចូលរួមប្រឆាំងជាមួយខ្លួន ឬយ៉ាងហោចណាស់នៅស្ងៀមនៅពេលដែលខ្លួនធ្វើការប្រឆាំងនឹងការអនុម័តនោះ។ តាមរយៈនេះ យើងឃើញថា កុងស៊ុងស៊ុសបដិសេធអាចធ្វើទៅបានតាមទ្រឹស្តី ក៏ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែងមិនដែលកើតមានទេមកដល់បច្ចុប្បន្ននេះព្រោះថា DSU មិនផ្តល់ឱកាសដល់សមាជិកធ្វើការរារាំងនូវការសម្រេចសេចក្តីលើបញ្ហាសំខាន់ៗតែម្នាក់ឯងឡើយ។ ដោយសារមូលហេតុនេះហើយទើបគេនិយាយថា សេចក្តីសម្រេចនៅក្នុងអង្គភាពដោះស្រាយវិវាទគឺពាក់កណ្តាលអាចធ្វើទៅបានដោយស្វ័យប្រវត្តិ។ ប៉ុន្តែគួរបញ្ជាក់ថា កុងស៊ុងស៊ុសបដិសេធនេះ ត្រូវបានប្រើតែក្នុងបរិបទនៃការសម្រេចសេចក្តីនៅក្នុងប្រព័ន្ធដោះស្រាយវិវាទ ដូចបានលើកឡើងពីខាងលើតែប៉ុណ្ណោះ ចំណែកការសម្រេចសេចក្តីផ្សេងទៀតរបស់អង្គភាពដោះស្រាយវិវាទ មិនមានលើកឡើងពីកុងស៊ុងស៊ុសបដិសេធទេ ត្បិតថាការសម្រេចសេចក្តីត្រូវធ្វើឡើងដោយកុងស៊ុងស៊ុសដូចបានលើកឡើងពីវិធានទូទៅនៃការសម្រេចសេចក្តីពីខាងដើម។

## ១.៤.៣. គណៈវិនិច្ឆ័យ

### ១.៤.៣.១. សមាសភាព

គណៈវិនិច្ឆ័យ គឺជាអង្គភាពពាក់កណ្តាលតុលាការ ដោយហេតុថាក្នុងរបៀបខ្លះគេមើលឃើញគណៈវិនិច្ឆ័យ ដូចជាសាលាជម្រះក្តី ដែលទទួលបន្ទុកនៅក្នុងការកាត់សេចក្តីលើវិវាទរវាងសមាជិកនៅជំណាក់កាលជំនុំជម្រះលើកទីមួយ ដូចសាលាដំបូងផងដែរ។ ជាធម្មតាគណៈវិនិច្ឆ័យ

មានសមាសភាព ៣រូប ប៉ុន្តែមានករណីលើកលែងខ្លះមានសមាសភាពរហូតដល់ ៥រូប ប្រសិនបើមានការព្រមព្រៀងគ្នាពីសំណាក់ភាគីក្នុងអំឡុងពេល១០ថ្ងៃ បន្ទាប់ពីបង្កើតគណៈវិនិច្ឆ័យហើយ បើមិនដូច្នោះទេ អង្គភាពដោះស្រាយវិវាទនឹងធ្វើការកំណត់សមាសភាពតែ៣រូបប៉ុណ្ណោះ។ សមាសភាពទាំងនេះសុទ្ធសឹងតែជាអ្នកជំនាញ ដែលត្រូវបានជ្រើសរើសឡើងសម្រាប់រឿងក្តីនីមួយៗ ក៏ប៉ុន្តែសមាសភាពនេះមាន លក្ខណៈបណ្តោះអាសន្នសម្រាប់រឿងក្តីនីមួយៗប៉ុណ្ណោះ ពោលគឺមានន័យថាគ្មានសមាជិកគណៈវិនិច្ឆ័យអចិន្ត្រៃយ៍នៅអង្គការពាណិជ្ជកម្មពិភពលោកនោះទេ។

អ្នកដែលអាចធ្វើជាសមាជិកគណៈវិនិច្ឆ័យបាន ទាល់តែមានគុណសម្បត្តិគ្រប់គ្រាន់ និងមានភាពឯករាជ្យ អាចបំពេញមុខងារជាគណៈវិនិច្ឆ័យបាន។ បុគ្គលដែលមានលក្ខណៈសម្បត្តិល្អគ្រប់គ្រាន់ទាំងនោះ អាចជាបុគ្គលក្នុងរដ្ឋាភិបាល ឬមិនមែនរដ្ឋាភិបាល ដែលរួមមាន អ្នកដែលធ្លាប់ដាក់រឿងក្តីប្តឹងចូលមកគណៈវិនិច្ឆ័យ អ្នកដែលធ្លាប់ធ្វើជាតំណាងអោយសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ឬភាគីនៃ GATT 1947 ឬធ្លាប់ជាតំណាងរបស់ក្រុមប្រឹក្សា ឬគណៈកម្មាការនៃកិច្ចព្រមព្រៀងនានាដែលពាក់ព័ន្ធនឹងកិច្ចការពាណិជ្ជកម្ម ឬកិច្ចព្រមព្រៀងពីមុនរបស់កិច្ចព្រមព្រៀងទាំងនោះ អ្នកដែលធ្លាប់បម្រើការងារនៅក្នុងលេខាធិការដ្ឋាន អ្នកដែលធ្លាប់បង្រៀន ឬបោះពុម្ពផ្សាយច្បាប់ ឬគោលនយោបាយពាណិជ្ជកម្មអន្តរជាតិ ឬក៏ធ្លាប់បម្រើការងារជាមន្ត្រីជាន់ខ្ពស់ខាងគោលនយោបាយពាណិជ្ជកម្មរបស់រដ្ឋជាសមាជិក។[28]

ពាក់ព័ន្ធនឹងសមាសភាពរបស់គណៈវិនិច្ឆ័យនេះដែរ ប្រជាពលរដ្ឋនៃរដ្ឋជាភាគីវិវាទ ឬរដ្ឋជាភាគីទីបីមិនអាចក្លាយជាសមាជិកនៃគណៈវិនិច្ឆ័យនោះទេ ប្រសិនបើគ្មានការព្រមព្រៀងពីសំណាក់ភាគីវិវាទ។ ប្រសិនបើវិវាទកើតមានរវាងភាគីដែលជាប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍នោះសមាជិកគណៈវិនិច្ឆ័យ ត្រូវតែមានបញ្ចូលយ៉ាងហោចណាស់សមាជិកគណៈវិនិច្ឆ័យម្នាក់ដែលមកពីប្រទេសដែលកំពុងអភិវឌ្ឍន៍នោះ តាមសំណើរបស់ប្រទេសកំពុងអភិវឌ្ឍន៍ដែលជាភាគីវិវាទនោះ។ ជាធម្មតាសមាជិកគណៈវិនិច្ឆ័យ គឺជាប្រតិភូពាណិជ្ជកម្មរបស់ប្រទេសជាសមាជិករបស់អង្គការWTO ឬមន្ត្រីទទួលបន្ទុកកិច្ចការពាណិជ្ជកម្មនៅក្នុងរដ្ឋធានីនៃប្រទេសជាសមាជិក ក៏ប៉ុន្តែអតីតមន្ត្រីរបស់លេខាធិការដ្ឋាន មន្ត្រីរដ្ឋាភិបាលដែលចូលនិវត្តន៍ និងបណ្ឌិតសភាចារ្យ ក៏អាចបម្រើការងារនៅក្នុងគណៈវិនិច្ឆ័យបានដែរ។ បុគ្គលទាំងនេះបម្រើការងារជាសមាជិកគណៈវិនិច្ឆ័យក្រៅម៉ោង បន្ថែមពីលើសកម្មភាពវិជ្ជាជីវៈជាធម្មតារបស់គេ។

[28] DSU, 1995, មាត្រា 8 ចំណុច 1។

លេខាធិការដ្ឋានអង្គការពាណិជ្ជកម្មពិភពលោក រក្សាទុកនូវបញ្ជីឈ្មោះបុគ្គលដែលដាក់ពាក្យស្នើសុំធ្វើជាគណៈវិនិច្ឆ័យ ទាំងបុគ្គលរដ្ឋាភិបាល និងបុគ្គលមិនមែនរដ្ឋាភិបាល ដើម្បីទុកជ្រើសរើសនូវសមាសភាពរបស់គណៈវិនិច្ឆ័យចេញពីបញ្ជីនេះ ហើយលេខាធិការដ្ឋានក៏ជាអ្នកស្នើនូវបេក្ខភាពគណៈវិនិច្ឆ័យដល់ភាគីដែរ។ សមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក តែងតែស្នើនូវឈ្មោះដើម្បីដាក់បញ្ចូលនៅក្នុងបញ្ជីនោះ ហើយជាការអនុវត្តជាក់ស្តែងគឺ អង្គភាពដោះស្រាយវិវាទ គឺជាអ្នកសម្រេចយល់ព្រមដាក់បញ្ចូលឈ្មោះទាំងនោះក្នុងបញ្ជីដោយមិនមានការជជែកដេញដោលឡើយ។ ទោះជាយ៉ាងណាក៏ដោយ មិនមែនចាំបាច់ត្រូវតែមានឈ្មោះនៅក្នុងបញ្ជីទើបអាចត្រូវបានស្នើធ្វើជាគណៈវិនិច្ឆ័យប្រកបដោយសក្កានុពលក្នុងវិវាទជាក់លាក់ណាមួយនោះទេ ពោលគឺអ្នកដែលមិនមានឈ្មោះក្នុងបញ្ជីក៏អាចត្រូវបានជ្រើសរើសបានផងដែរ។ លេខាធិការដ្ឋានត្រូវធ្វើការពិនិត្យឡើងវិញជាប្រចាំនូវបញ្ជីឈ្មោះនោះ ស្របទៅតាមការកែប្រែផ្លាស់ប្តូរ ឬបន្ថែមដោយសមាជិករបស់អង្គការ ។

នៅពេលដែលលេខាធិការដ្ឋាន WTO ស្នើបុគ្គលដែលមានគុណសម្បត្តិដើម្បីធ្វើជាសមាជិកគណៈវិនិច្ឆ័យ សមាជិកដែលជាភាគីវិវាទមិនត្រូវប្រឆាំងនឹងការស្នើឡើងនោះទេ លើកលែងតែមានមូលហេតុនៃការបង្ខិតបង្ខំ។ នៅក្នុងការអនុវត្ត សមាជិកជាច្រើនប្រើប្រាស់នូវខលើកលែងនេះ ដើម្បីធ្វើការប្រឆាំងនឹងការស្នើឡើងរបស់លេខាធិការដ្ឋាននូវបេក្ខភាពជាញឹកញាប់។ នៅក្នុងករណីដូចនេះ គ្មានការពិនិត្យឡើងវិញថាតើមូលហេតុនោះពិតជាមានការបង្ខិតបង្ខំពិតប្រាកដមែនឬទេឡើយ ដូចនេះ លេខាធិការដ្ឋាន ត្រូវធ្វើការស្នើនូវឈ្មោះបេក្ខភាពផ្សេងវិញ។ យោងតាមវិធីនេះ ប្រសិនបើគ្មានការព្រមព្រៀងគ្នារវាងភាគីវិវាទ លើសមាសភាពរបស់គណៈវិនិច្ឆ័យនៅក្នុងអំឡុងពេល២០ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទនៃការបង្កើតគណៈវិនិច្ឆ័យដោយអង្គភាពដោះស្រាយវិវាទទេ ភាគីណាមួយអាចស្នើទៅកាន់អគ្គនាយកអង្គកា រWTO អោយធ្វើការកំណត់សមាសភាពគណៈវិនិច្ឆ័យបាន។ ក្នុងអំឡុងពេល១០ថ្ងៃបន្ទាប់ពីបញ្ជូនសំណើនេះទៅកាន់ប្រធានអង្គភាពដោះស្រាយវិវាទ អគ្គនាយកធ្វើការចាត់តាំងនូវសមាជិកគណៈវិនិច្ឆ័យ ដោយមានការពិគ្រោះយោបល់ជាមួយនឹងប្រធានអង្គភាពដោះស្រាយវិវាទ និងប្រធានក្រុមប្រឹក្សា និងគណៈកម្មាធិការដែលពាក់ព័ន្ធ បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយភាគី។ ការបង្កើតឲ្យមាននូវនីតិវិធីបែបនេះ ពិតជាមានសារៈសំខាន់ណាស់ ព្រោះថាវាបង្ការមិនឲ្យចុងចម្លើយធ្វើការរារាំងនូវនីតិវិធីរបស់គណៈវិនិច្ឆ័យទាំងមូល ដោយធ្វើការពន្យារហួតនូវការកំណត់សមាសភាពរបស់គណៈវិនិច្ឆ័យ ដែលនេះជាអ្វីដែលពេលខ្លះបានកើតមានឡើងនៅក្នុងប្រព័ន្ធដោះស្រាយវិវាទជាអន្តរជាតិផ្សេងទៀត។ ទោះជាមានការកំណត់ដូចខាងលើក៏ដោយ

ក៏ភាគីមានសេរីភាពនៅក្នុងការប្រើប្រាស់នូវពេលវេលាច្រើនជាង២០ថ្ងៃ ក្នុងគោលបំណងដើម្បីព្រមព្រៀងទៅលើការកំណត់នូវសមាសភាពរបស់គណៈវិនិច្ឆ័យ បើគ្មានភាគីណាស្នើសុំឲ្យអគ្គនាយកអង្គការ WTO ចូលអន្តរាគមន៍ក្នុងការកំណត់សមាសភាពរបស់គណៈវិនិច្ឆ័យនោះទេ។

គណៈវិនិច្ឆ័យដែលត្រូវបានជ្រើសរើស ត្រូវបំពេញការងាររបស់ខ្លួនដោយឯករាជ្យពេញលេញ និងមិនមែនជាអ្នកតំណាងរបស់រដ្ឋាភិបាល និងអង្គការអន្តរជាតិដទៃទៀត ដែលគេធ្វើការងារអោយឡើយ។ សមាជិកត្រូវបាន ហាមឃាត់មិនអោយផ្តល់នូវការណែនាំដល់គណៈវិនិច្ឆ័យ ឬស្វែងរកនូវឥទ្ធិពលលើគណៈវិនិច្ឆ័យឡើយ ពាក់ព័ន្ធនឹងបញ្ហាដែលត្រូវបានដាក់ជូនគណៈវិនិច្ឆ័យធ្វើការដោះស្រាយ។

### ១.៤.៣.២. មុខងាររបស់គណៈវិនិច្ឆ័យ

គណៈវិនិច្ឆ័យដែលត្រូវបានបង្កើតឡើងសម្រាប់វិវាទណាមួយ ត្រូវតែពិនិត្យមើលនូវចំណុចអង្គហេតុ និងអង្គច្បាប់នៃរឿងក្តី និងធ្វើការដាក់ជូនរបាយការណ៍ទៅអង្គភាពដោះស្រាយវិវាទ ដែលបង្ហាញនូវសេចក្តីសន្និដ្ឋានថាតើការអះអាងរបស់អ្នកដែលធ្វើការតវ៉ាពិតជាត្រឹមត្រូវឬទេ ហើយវិធានច្បាប់ ឬសកម្មភាពដែលត្រូវបានគេតវ៉ា ពិតជាមិនស្របនឹងកិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោកមែនឬទេ។ ប្រសិនបើគណៈវិនិច្ឆ័យរកឃើញថា ការអះអាងលើការតវ៉ា ពិតជាត្រឹមត្រូវហើយពិតជាមានការរំលោភបំពានដោយសមាជិកនៃអង្គការមែននោះ គណៈវិនិច្ឆ័យនឹងចេញនូវអនុសាសន៍ ដែលតម្រូវអោយមានការអនុវត្តដោយចុងចម្លើយ ឬអ្នកដែលបំពាននូវកាតព្វកិច្ច។

ដើម្បីបំពេញមុខងាររបស់ខ្លួន គណៈវិនិច្ឆ័យត្រូវការជំនួយពីលេខាធិការដ្ឋានអង្គការ WTO ដែលទទួលខុសត្រូវផ្តល់ជំនួយរដ្ឋបាល និងផ្នែកច្បាប់នៅក្នុងនីតិវិធីនៃការដោះស្រាយវិវាទ។ មួយវិញទៀត លេខាធិការដ្ឋានធ្វើកិច្ចការពាក់ព័ន្ធនឹងការរៀបចំផ្សេងៗទៀតសម្រាប់គណៈវិនិច្ឆ័យដូចជាការរៀបចំនូវការធ្វើដំណើររបស់គណៈវិនិច្ឆ័យទៅទីក្រុងហ្សឺណែវដែលជាទីប្រជុំជំនុំជម្រះ រៀបចំនូវលិខិតអញ្ជើញភាគីឲ្យចូលរួមប្រជុំជាមួយគណៈវិនិច្ឆ័យ ទទួលនូវលិខិតផ្សេងៗ និងបញ្ជូនបន្តទៅគណៈវិនិច្ឆ័យ។ ការផ្តល់ជំនួយផ្នែកច្បាប់អាចស្តែងឡើងក្នុងរូបភាពនៃការផ្តល់យោបល់លើបញ្ហាផ្នែកច្បាប់ដែលលេចឡើងនៅក្នុងវិវាទ និងយុត្តិសាស្ត្ររបស់អតីតគណៈវិនិច្ឆ័យនិងអង្គភាពឧទ្ធរណ៍ផងដែរ។ ដោយសារតែគណៈវិនិច្ឆ័យមិនមែនជាអង្គភាពអចិន្ត្រៃយ៍ លេខាធិការដ្ឋានបំពេញតួនាទីជាស្ថាប័នមួយដែលធានានូវនិរន្តរភាពការងាររវាងគណៈវិនិច្ឆ័យនានា ដែលចាំបាច់ដើម្បីសម្រេចនូវកម្មវត្ថុរបស់ DSU ក្នុងការផ្តល់នូវសុវត្ថិភាព និងភាពអាចព្យាករណ៍ទុកបានដល់ប្រព័ន្ធនៃការធ្វើពាណិជ្ជកម្មពហុភាគី។ លេខាធិការដ្ឋានតែងផ្តល់នូវបុគ្គលិកចាំជួយដល់គណៈវិនិច្ឆ័យ ដែលយ៉ាង

ហោចណាស់ក៏មានលេខាម្នាក់ និងមន្ត្រីច្បាប់ម្នាក់។ ក្នុងនោះម្នាក់ទទួលខុសត្រូវលើកិច្ចព្រមព្រៀង ដែលភាគីយកធ្វើជាសំអាង និងម្នាក់ទៀតទទួលខុសត្រូវផ្នែកកិច្ចការច្បាប់។

### ១.៤.៤. អង្គភាពឧទ្ធរណ៍

#### ១.៤.៤.១. ប្រវត្តិ និងមូលហេតុនៃការបង្កើតអង្គភាពឧទ្ធរណ៍

នៅក្នុងប្រព័ន្ធដោះស្រាយវិវាទចាស់ក្រោម GATT 1947 មិនមានអង្គភាពឧទ្ធរណ៍នេះទេ ដូច្នេះហើយ ការបន្ថែមនូវអង្គភាពឧទ្ធរណ៍ក្នុងការជំនុំជម្រះនេះ គឺជាការបង្កើតថ្មីមួយដ៏សំខាន់នៅក្នុងកិច្ចប្រជុំអ៊ុយរ៉ាហ្គាយស្តីពីការចរចាពាណិជ្ជកម្មពហុភាគី។ ដូច្នេះអង្គភាពឧទ្ធរណ៍ គឺជាដំណាក់កាលទី២ និងជាដំណាក់កាលចុងក្រោយក្នុងការជំនុំជម្រះក្នុងប្រព័ន្ធដោះស្រាយវិវាទរបស់អង្គការពាណិជ្ជកម្មពិភពលោក។

មូលហេតុដ៏សំខាន់មួយក្នុងការបង្កើតនូវអង្គភាពឧទ្ធរណ៍នេះ គឺភាពស្វ័យប្រវត្តិកាន់តែច្រើនឡើងនៃការអនុម័តនូវសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យ ចាប់តាំងពីចាប់ផ្តើមមាននូវ DSU។ នៅក្នុងប្រព័ន្ធដោះស្រាយវិវាទបច្ចុប្បន្ន សមាជិកនីមួយៗរបស់អង្គការពាណិជ្ជកម្មពិភពលោកមិនអាចរារាំងការអនុម័តសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យទេ ប្រសិនបើពួកគេគ្មានការចូលរួមពីសំណាក់សមាជិកដទៃទៀតដែលតំណាងនៅក្នុងអង្គភាពដោះស្រាយវិវាទ ដើម្បីរារាំង ឬប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គភាពដោះស្រាយវិវាទ។ ភាពស្វ័យប្រវត្តិនៃការអនុម័តលើសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យបានដកចេញនូវលទ្ធភាពពីមុន ដែលភាគីចាញ់ក្តីអាចរារាំងការអនុម័តសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យ ហើយវាក៏ដកចេញផងដែរនូវលទ្ធភាពដែលភាគី និងសមាជិកដទៃទៀត ធ្វើការបដិសេធនូវសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យ។ ផ្ទុយពីប្រព័ន្ធដោះស្រាយវិវាទបច្ចុប្បន្ន នៅក្រោមប្រព័ន្ធដោះស្រាយវិវាទចាស់របស់ GATT 1947 របាយការណ៍គណៈវិនិច្ឆ័យខ្លះមិនត្រូវបានអនុម័ត ព្រោះការបកស្រាយនូវបទបញ្ញត្តិច្បាប់ពិសេសៗមួយចំនួន មិនអាចទទួលយកបានដោយភាគី។ ដោយសារតែលទ្ធភាពដូចបានលើកឡើងខាងលើ មិនអាចទៅរួចទៀតទេនៅក្នុងប្រព័ន្ធដោះស្រាយវិវាទបច្ចុប្បន្ន ទើបប្រព័ន្ធនេះបង្កើតឲ្យមានការត្រួតពិនិត្យឧទ្ធរណ៍ដោយអង្គភាពឧទ្ធរណ៍ ដែលមានមុខងារក្នុងការកែតម្រូវនូវបញ្ហាខុសឆ្គង ផ្នែកច្បាប់ដែលអាចកើតឡើងដោយការប្រព្រឹត្តរបស់គណៈវិនិច្ឆ័យ។

### ១.៤.៤.២. សមាសភាពរបស់អង្គភាពឧទ្ធរណ៍

អង្គភាពដោះស្រាយវិវាទបានបង្កើតអង្គភាពឧទ្ធរណ៍នៅឆ្នាំ១៩៩៥ ដែលនៅក្នុងពេលនោះ សមាជិក៧នាក់ដំបូងរបស់អង្គភាពឧទ្ធរណ៍ត្រូវបានជ្រើសតាំងឡើង។ អង្គភាពដោះស្រាយវិវាទធ្វើការជ្រើសតាំងសមាជិកអង្គភាពឧទ្ធរណ៍ដោយកុងស៊ិងស៊ុស សម្រាប់បម្រើការងារក្នុងអាណត្តិ៤ឆ្នាំ ប៉ុន្តែអាចត្រូវបានជ្រើសតាំងសាជាថ្មីបានមួយលើកទៀត។ ដូច្នេះ សមាជិករបស់អង្គភាពឧទ្ធរណ៍ អាចបម្រើការងារអតិបរមារយៈពេល៨ឆ្នាំ ប៉ុន្តែជាមធ្យមរៀងរាល់២ឆ្នាំម្តង មួយផ្នែកនៃសមាសភាពរបស់អង្គភាពឧទ្ធរណ៍ត្រូវផ្លាស់ប្តូរ។

សមាជិកទាំង៧របស់អង្គភាពឧទ្ធរណ៍ ត្រូវតែជាតំណាងរួមរបស់សមាជិកនៃអង្គការ WTO ទាំងមូល ដោយមិនមែនជាតំណាងរបស់ប្រទេសរបស់ពួកគេតែប៉ុណ្ណោះទេ។ សមាជិកទាំង៧ដំបូងមានជនជាតិ អេហ្ស៊ីប ជប៉ុន ញ៉ូវហ្ស៊ីឡែន ហ្វីលីពីន អាមេរិក និងអ៊ុយរ៉ាហ្គាយ។ សមាជិក ៣ ឬ ៤ នាក់របស់អង្គភាពឧទ្ធរណ៍ ជាធម្មតាតែងតែជាប្រជាជននៃប្រទេសសមាជិកកំពុងអភិវឌ្ឍន៍។ យោងតាមនីតិវិធីធ្វើការនៃការត្រួតពិនិត្យឧទ្ធរណ៍ សមាជិកទាំង៧របស់អង្គភាពឧទ្ធរណ៍ ជ្រើសរើសសមាជិកម្នាក់ក្នុងចំណោមពួកគេ ធ្វើជាប្រធានសម្រាប់អាណត្តិ១ឆ្នាំ ឬច្រើនបំផុត២ឆ្នាំ។ ប្រធានធ្វើការដឹកនាំទូទៅលើកិច្ចការរបស់អង្គភាពឧទ្ធរណ៍ ជាពិសេសពាក់ព័ន្ធនឹងមុខងារ និងកិច្ចការផ្ទៃក្នុង។

សមាជិករបស់អង្គភាពឧទ្ធរណ៍ ត្រូវតែជាបុគ្គលដែលត្រូវបានគេទទួលស្គាល់នូវសមត្ថភាពជំនាញផ្នែកច្បាប់ពាណិជ្ជកម្មអន្តរជាតិ ព្រមទាំងមុខវិជ្ជាពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងពាណិជ្ជកម្មអន្តរជាតិ ហើយត្រូវតែមិនមានជាប់ពាក់ព័ន្ធនឹងរដ្ឋាភិបាលណាមួយ។ សមាជិកនៃអង្គភាពឧទ្ធរណ៍ភាគច្រើន គឺជាសាស្ត្រាចារ្យសាកលវិទ្យាល័យ មេធាវីដែលកំពុងបំពេញការងារ អតីតមន្ត្រីរដ្ឋាភិបាល ឬចៅក្រមដែលមានវ័យចំណាស់។ ក្នុងនាមជាសមាជិករបស់អង្គភាពឧទ្ធរណ៍ ជាទ្រឹស្តីគឺគ្រាន់តែជាអាជីពក្រៅម៉ោង ប៉ុន្តែត្រូវតែអាចធ្វើការងារបានគ្រប់ពេលវេលា ទោះបីជាមានការជូនដំណឹងជាមុនអំពីការងារក្នុងរយៈពេលខ្លីក៏ដោយ។

### ១.៤.៤.៣. លេខាធិការដ្ឋានអង្គភាពឧទ្ធរណ៍

លេខាធិការដ្ឋានអង្គភាពឧទ្ធរណ៍ផ្តល់នូវជំនួយផ្នែកច្បាប់ និងការគាំទ្រផ្នែករដ្ឋបាលដល់អង្គភាពឧទ្ធរណ៍។ ដើម្បីធានានូវឯករាជ្យភាពរបស់អង្គភាពឧទ្ធរណ៍ លេខាធិការដ្ឋាននេះភ្ជាប់ទំនាក់ទំនងជាមួយលេខាធិការដ្ឋានអង្គការ WTO តែលើផ្នែកកិច្ចការរដ្ឋបាលប៉ុណ្ណោះ ហើយត្រូវបែងចែកដាច់ដោយឡែកពីគ្នារវាងលេខាធិការដ្ឋានទាំងពីរ។ លេខាធិការដ្ឋានអង្គភាពឧទ្ធរណ៍ បម្រើការងារនូវទីស្នាក់ការកណ្តាលទីក្រុងហ្សឺណែវជាមួយនិងលេខាធិការដ្ឋានរបស់អង្គការ WTO ដែរ។

#### ១.៤.៤.៤. មុខងាររបស់អង្គភាពឧទ្ធរណ៍

ខុសពីគណៈវិនិច្ឆ័យដែលជាអង្គភាពបណ្តោះអាសន្ន អង្គភាពឧទ្ធរណ៍ជាអង្គភាពអចិន្ត្រៃយ៍ ដែលមានសមាជិក៧រូប ដែលត្រូវបានប្រគល់ភារកិច្ចអោយពិនិត្យមើលនូវចំណុចច្បាប់ក្នុងសេចក្តីសម្រេចដែលចេញដោយគណៈវិនិច្ឆ័យ។ ប្រសិនបើភាគីប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យ អង្គភាពឧទ្ធរណ៍ធ្វើការពិនិត្យលើបញ្ហាច្បាប់ដែលចោទឡើង ហើយចេញនូវសេចក្តីសម្រេច ដែលក្នុងនោះអាចជាការរក្សាទុកជាបានការនូវសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យ ឬក៏ជាការចេញសេចក្តីសម្រេចផ្ទុយពីសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យ ឬក៏ធ្វើការកែប្រែនូវសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យជាដើម។

### ១.៤.៥. អគ្គនាយក និងលេខាធិការដ្ឋានអង្គការពាណិជ្ជកម្មពិភពលោក

#### ១.៤.៥.១. អគ្គនាយក

ក្នុងប្រព័ន្ធដោះស្រាយវិវាទរបស់អង្គការពាណិជ្ជកម្មពិភពលោក អគ្គនាយកអង្គការ WTO មានភារកិច្ចជាប់ពាក់ព័ន្ធមួយចំនួនគួរឲ្យកត់សម្គាល់នៅក្នុងនីតិវិធីដោះស្រាយវិវាទ ក្នុងនោះមានដូចជា ៖

☞អគ្គនាយក អាចដើរតួនាទីក្នុងនាមជាអ្នកមានសមត្ថភាពដែលផ្តល់អោយតាមរយៈតួនាទីរបស់ខ្លួន (ex officio capacity) ដើម្បីផ្តល់នូវ Good Office ការសម្រុះសម្រួល សន្ធានកម្ម និងការយល់ឃើញរបស់ខ្លួន ដើម្បីជួយភាគីក្នុងការដោះស្រាយវិវាទ។ ក្នុងន័យនេះ នៅក្នុងបញ្ហាវិវាទដែលជាប់ទាក់ទងនឹងសមាជិកជាប្រទេសអភិវឌ្ឍន៍តិចតួច បើមានសំណើពីប្រទេសនោះ អគ្គនាយកអាចផ្តល់នូវ Good Office ការសម្រុះសម្រួល សន្ធានកម្ម ដើម្បីជួយភាគីនៅក្នុងការដោះស្រាយវិវាទ បន្ទាប់ពីមិនមានដំណោះស្រាយដែលអាចទទួលយកបានដោយភាគី ក្នុងអំឡុងពេលនៃការប្រឹក្សាមុននឹងឈានទៅដល់ការជំនុំជម្រះនៅគណៈវិនិច្ឆ័យ។

☞អគ្គនាយកដឹកនាំកិច្ចប្រជុំរបស់អង្គភាពដោះស្រាយវិវាទ ហើយក្នុងករណីដែលភាគីមិនយល់ព្រមលើសមាសភាពគណៈវិនិច្ឆ័យ ដែលស្នើឡើងដោយអង្គភាពដោះស្រាយវិវាទក្នុងអំឡុងពេល២០ថ្ងៃ អគ្គនាយកធ្វើការតែងតាំងនូវសមាសភាពរបស់គណៈវិនិច្ឆ័យ តបតាមការស្នើសុំរបស់ភាគី និងដោយមានការប្រឹក្សាជាមួយនឹងប្រធានអង្គភាពដោះស្រាយវិវាទ ប្រធានក្រុមប្រឹក្សា និងគណៈកម្មាការដែលពាក់ព័ន្ធ ។

☞អគ្គនាយកតែងតាំងមជ្ឈត្តករ ដើម្បីកំណត់រយៈពេលសមហេតុផលសម្រាប់ភាគីក្នុងការអនុវត្តតាមសេចក្ដីសម្រេចដែលអនុម័តដោយអង្គភាពដោះស្រាយវិវាទ បើភាគីមិនអាចកំណត់បានពីរយៈពេលនោះ ឬមិនពេញចិត្តនឹងមជ្ឈត្តករដែលមានស្រាប់។ ការតែងតាំងមជ្ឈត្តករនេះ ក៏អាចធ្វើឡើងដើម្បីជួយក្នុងការពិនិត្យឡើងវិញលើសំណើព្យួរកាតព្វកិច្ច ដោយហេតុផលមិនមានការអនុវត្តតាមសេចក្ដីសម្រេចដែលអនុម័តដោយអង្គភាពដោះស្រាយវិវាទផងដែរ។ ក៏ប៉ុន្តែគួរបញ្ជាក់ថា ការតែងតាំងមជ្ឈត្តករដោយអគ្គនាយក គឺបន្ថែមទៅលើគណៈវិនិច្ឆ័យដែលមានស្រាប់ ក្នុងករណីដែលគណៈវិនិច្ឆ័យដែលមានស្រាប់នោះជាប់រវល់ប៉ុណ្ណោះ ។

**១.៤.៥.២. លេខាធិការដ្ឋាន**

ចំពោះលេខាធិការដ្ឋានអង្គការ WTO វិញក៏មានការជាប់ពាក់ព័ន្ធមួយចំនួននឹងដំណើរការដោះស្រាយវិវាទក្នុងប្រព័ន្ធដោះស្រាយវិវាទនេះដែរ។ ក្នុងនោះមានដូចជា ៖

☞លេខាធិការដ្ឋានជួយដល់ភាគីវិវាទដែលស្នើសុំឲ្យខ្លួនជួយ ដូចជា ការបង្កើតវគ្គបណ្ដុះបណ្ដាលពិសេស (special training courses) ព្រមទាំងផ្ដល់នូវជំនួយ និងដំបូន្មានផ្នែកច្បាប់ក្នុងបញ្ហាពាក់ព័ន្ធនឹងវិវាទជាដើម ជាពិសេសចំពោះភាគីវិវាទជាប្រទេសកំពុងអភិវឌ្ឍន៍។ ត្រង់ចំណុចនេះ លេខាធិការដ្ឋានត្រូវផ្ដល់ជូននូវអ្នកជំនាញផ្នែកច្បាប់មកពីផ្នែកសេវាផ្ដល់កិច្ចសហប្រតិបត្តិការបច្ចេកទេសរបស់អង្គការ WTO (the WTO Technical cooperation services) ទៅដល់ប្រទេសកំពុងអភិវឌ្ឍន៍ដែលស្នើសុំនោះ។ អ្នកជំនាញនោះត្រូវជួយដល់ប្រទេសនោះ ក្នុងអាកប្បកិរិយាដែលធានានូវភាពមិនលំអៀងរបស់លេខាធិការដ្ឋាន។

☞លេខាធិការដ្ឋាន ក៏ជួយភាគីនៅក្នុងការរៀបចំនូវសមាសភាពរបស់គណៈវិនិច្ឆ័យ ដោយធ្វើការស្នើនូវគណៈវិនិច្ឆ័យដែលមានសក្កានុពល ដើម្បីដោះស្រាយរឿងក្ដី ជួយដល់គណៈវិនិច្ឆ័យនៅពេលដែលគណៈវិនិច្ឆ័យនោះត្រូវបានតែងតាំងឡើង ព្រមទាំងផ្ដល់ជំនួយរដ្ឋបាលដល់អង្គភាពដោះស្រាយវិវាទផងដែរ។

**១.៤.៦. មជ្ឈត្តករ**

បន្ថែមពីលើគណៈវិនិច្ឆ័យ និងអង្គភាពឧទ្ធរណ៍ មជ្ឈត្តករអាចត្រូវបានកោះហៅអោយទៅចូលរួមពិភាក្សា ឬកាត់សេចក្ដីលើវិវាទណាមួយ នៅគ្រប់ដំណាក់កាលនៃដំណើរការដោះស្រាយវិវាទពាណិជ្ជកម្មអន្តរជាតិ ក្នុងនោះអាចជាមជ្ឈត្តករម្នាក់ ឬជាក្រុមមជ្ឈត្តករ។ ដូចនេះ មជ្ឈត្តកម្មគឺគ្រាន់តែជាជម្រើសបន្ថែមលើគណៈវិនិច្ឆ័យ ឬអង្គភាពឧទ្ធរណ៍ ដែលអាចត្រូវបានយកមកប្រើនៅ

ក្នុងដំណោះស្រាយវិវាទប៉ុណ្ណោះត្បិតថាកន្លងមកវាកម្រត្រូវបានយកមកប្រើប្រាស់ណាស់។[29] លទ្ធផលដែលកើតចេញពីមជ្ឈត្តកម្មមិនអាចប្ដឹងឧទ្ធរណ៍បានទេប៉ុន្តែអាចបង្ខំឲ្យអនុវត្តតាមរយៈDSU។[30]

គេឃើញមានទម្រង់នៃមជ្ឈត្តកម្មនៅក្នុង DSU ចំនួនពីរទម្រង់ ទីមួយគឺ មជ្ឈត្តកម្មសម្រាប់ស្ថានភាពពិសេស និងទីពីរគឺមជ្ឈត្តកម្មសម្រាប់បញ្ហាចោទឡើងនៅក្នុងដំណើរការនៃការអនុវត្តសេចក្ដីសម្រេច។ ឧទាហរណ៍ចំពោះស្ថានភាពទី១ គឺបន្ទាប់ពីអង្គភាពដោះស្រាយវិវាទបានអនុម័តនូវសេចក្ដីសម្រេចរបស់គណៈវិនិច្ឆ័យ ឬសេចក្ដីសម្រេចរបស់អង្គភាពឧទ្ធរណ៍រួចហើយ ភាគីចាញ់ក្ដីមានកាតព្វកិច្ចត្រូវអនុវត្តតាមវិធាន ការសម្រេច និងអនុសាសន៍របស់អង្គភាពដោះស្រាយវិវាទ។ នៅក្នុងស្ថានភាពនេះ គឺត្រូវកំណត់អំពីអំឡុងពេលសមរម្យសម្រាប់អោយភាគីចាញ់ក្ដី ឬចុងចម្លើយធ្វើការអនុវត្តតាមសេចក្ដីសម្រេចរបស់អង្គភាពដោះស្រាយវិវាទ ដូចនេះ មជ្ឈត្តករម្នាក់អាចត្រូវបានកោះហៅដើម្បីមកធ្វើការកំណត់អំពីអំឡុងពេលសមរម្យនេះ។[31] ស្ថានភាពទីពីរ គឺភាគីដែលត្រូវបានគេចាត់វិធានការតបមកលើខ្លួន អាចស្នើសុំឲ្យមាននូវមជ្ឈត្តកម្ម ប្រសិនបើគេបដិសេធទៅនឹងកម្រិត ឬលក្ខណៈនៃការព្យួរកាតព្វកិច្ចដែលបានស្នើឡើងដោយភាគីម្ខាងទៀតនោះ។[32] ដូចនេះ ទម្រង់ទាំងពីរនៃមជ្ឈត្តកម្មនេះ ត្រូវបានកម្រិតដោយធ្វើការបំភ្លឺបញ្ជាក់តែលើសំណួរពិសេសជាក់លាក់នៅក្នុងដំណាក់កាលនៃការអនុវត្តតាមសេចក្ដីសម្រេចរបស់ភាគីតែប៉ុណ្ណោះ ហើយសេចក្ដីសម្រេចរបស់មជ្ឈត្តករនេះមានអានុភាពចាប់បង្ខំអោយភាគីអនុវត្ត។

គួរបញ្ជាក់ថា ភាគីត្រូវយល់ព្រមលើមជ្ឈត្តកម្ម ព្រមទាំងនីតិវិធីដែលត្រូវអនុវត្ត។ ដូច្នេះភាគីវិវាទមានសេរីភាពក្នុងការមិនប្រើប្រាស់នីតិវិធីស្តង់ដាររបស់ DSU ហើយយល់ព្រមលើវិធាន និងនីតិវិធីដែលពួកគេយល់ថាសមស្របសម្រាប់មជ្ឈត្តកម្ម រួមបញ្ចូលទាំងការជ្រើសរើសមជ្ឈត្តករ។ មុនពេលចាប់ផ្ដើមមជ្ឈត្តកម្ម ភាគីត្រូវជូនដំណឹងពីការព្រមព្រៀងរបស់ខ្លួនក្នុងការពឹងផ្អែកលើមជ្ឈត្តកម្មទៅកាន់សមាជិកទាំងអស់របស់អង្គការ WTO។ សមាជិកដទៃទៀត អាចក្លាយជាភាគីនៃមជ្ឈត្តកម្មលុះត្រាតែមានការព្រមព្រៀងពីភាគីដែលមានជាប់ពាក់ព័ន្ធក្នុងមជ្ឈត្តកម្ម។ ភាគីនៃមជ្ឈត្តកម្មត្រូវយល់ព្រមគោរពតាមការសម្រេចរបស់មជ្ឈត្តកម្មដែលបានចេញ ហើយដែលការសម្រេចមជ្ឈត្តកម្មនេះត្រូវជូនដំណឹងទៅកាន់អង្គភាពដោះស្រាយវិវាទ ព្រមទាំងក្រុមប្រឹក្សា និងគណៈកម្មាការពាក់ព័ន្ធដែលគ្រប់គ្រងលើកិច្ចព្រមព្រៀងដែលចោទជាបញ្ហា។

[29] DSU,1995, មាត្រា 25។

[30] DSU, 1995, មាត្រា 21 និង 22។

[31] DSU, 1995, មាត្រា 23 ចំណុច 3(C)។

[32] DSU, 1995, មាត្រា 22 ចំណុច 6។

មកដល់បច្ចុប្បន្ន ជាការអនុវត្ត នីតិវិធីនៃមជ្ឈត្តកម្មមិនត្រូវបានប្រើប្រាស់ជាជម្រើសបន្ថែមលើនីតិវិធីរបស់គណៈវិនិច្ឆ័យ និងអង្គភាពដោះស្រាយវិវាទនោះទេ ប៉ុន្តែត្រូវបានអនុវត្តនៅក្នុងដំណាក់កាលនៃការអនុវត្ត ពេលដែលសេចក្ដីសម្រេចរបស់គណៈវិនិច្ឆ័យត្រូវបានអនុម័តរួចរាល់។ ភាគីស្នើសុំមជ្ឈត្តករអោយធ្វើការកំណត់អំពីកម្រិតនៃការខូចខាត និងការប៉ះពាល់ផលប្រយោជន៍ដែលបណ្ដាលមកពីការបំពាន ដូចមានកំណត់នៅក្នុងរបាយការណ៍របស់គណៈវិនិច្ឆ័យ។

### ១.៤.៧. អ្នកជំនាញ

វិវាទជាញឹកញាប់មានការជាប់ទាក់ទងទៅនឹងបញ្ហា ដែលមានលក្ខណៈស្មុគស្មាញដោយពេលខ្លះវាមានលក្ខណៈបច្ចេកទេស ឬវិទ្យាសាស្ត្រ។ ឧទាហរណ៍ ពេលមានការលេចឡើងនូវហានិភ័យសុខភាពដែលទាក់ទងនឹងផលិតផលមួយ ដែលជាកម្មវត្ថុនៃវិវាទរវាងភាគី វាទាមទារឲ្យមានអ្នកជំនាញក្នុងផ្នែកវិទ្យាសាស្ត្រ និងបច្ចេកទេសក្នុងផ្នែកសុខាភិបាល ប៉ុន្តែគណៈវិនិច្ឆ័យគឺជាអ្នកជំនាញក្នុងផ្នែកពាណិជ្ជកម្មមិនមែនក្នុងផ្នែកវិទ្យាសាស្ត្រនោះទេ ដូច្នេះហើយទើបDSU អនុញ្ញាតឲ្យគណៈវិនិច្ឆ័យស្វែងរកនូវព័ត៌មាន និងដំបូន្មានពីអ្នកបច្ចេកទេស ឬអ្នកជំនាញទាំងអស់នោះ។ ប៉ុន្តែក្នុងករណីគណៈវិនិច្ឆ័យសាកសួររកព័ត៌មានពីបុគ្គល ឬក្រុមណាមួយដែលស្ថិតក្នុងយុត្តាធិការរបស់សមាជិកណាមួយ គណៈវិនិច្ឆ័យត្រូវតែជូនដំណឹងដល់សមាជិកនោះជាមុនសិន។[33]

នៅពេលដែលគណៈវិនិច្ឆ័យយល់ឃើញថាចាំបាច់ក្នុងការប្រឹក្សាជាមួយនឹងអ្នកជំនាញដើម្បីជួយសម្រួលកាតព្វកិច្ចរបស់ខ្លួនក្នុងការស្វែងរកនូវការពិត គណៈវិនិច្ឆ័យអាចធ្វើការប្រឹក្សាជាមួយនឹងអ្នកជំនាញម្នាក់ ឬចាត់តាំងនូវក្រុមអ្នកជំនាញមួយដើម្បីរៀបចំនូវរបាយការណ៍ផ្ដល់យោបល់។[34] ក្រុមអ្នកជំនាញត្រួតពិនិត្យដែលត្រូវបានតែងតាំងនេះ អនុវត្តកិច្ចការរបស់ខ្លួនក្រោមអំណាចរបស់គណៈវិនិច្ឆ័យ ហើយត្រូវធ្វើរបាយការណ៍ទៅកាន់គណៈវិនិច្ឆ័យ។ គណៈវិនិច្ឆ័យ ធ្វើការកំណត់អំពីលក្ខខណ្ឌ និងអំពីនីតិវិធីធ្វើការងារលំអិតសម្រាប់ក្រុមអ្នកជំនាញនេះ។ នៅពេលដែលក្រុមអ្នកជំនាញដាក់របាយការណ៍ចុងក្រោយជូនគណៈវិនិច្ឆ័យ ក្រុមអ្នកជំនាញនេះក៏ត្រូវជូនព័ត៌មាននេះទៅកាន់ភាគីផងដែរ។ ក្រុមអ្នកជំនាញ មានតួនាទីត្រឹមជាអ្នកផ្ដល់ដំបូន្មាន ឬប្រឹក្សាប៉ុណ្ណោះ ព្រោះថាសេចក្ដីសម្រេចចុងក្រោយលើសំណួរផ្នែកច្បាប់ និងការរកឃើញការពិតផ្សេងៗ ដោយឈរលើមូលដ្ឋាននៃមតិយោបល់របស់អ្នកជំនាញ គឺនៅតែជាសិទ្ធិរបស់គណៈវិនិច្ឆ័យ។

[33] DSU, 1995, មាត្រា 13 ចំណុច 1។

[34] DSU, 1995, មាត្រា 13 ចំណុច 2។

ចំពោះសមាសភាពរបស់ក្រុមអ្នកជំនាញវិញ គឺត្រូវបានរឹតត្បិត ដោយកំណត់ចំពោះតែអ្នកដែលមានវិជ្ជាជីវៈ និងបទពិសោធន៍ក្នុងវិស័យដែលពាក់ព័ន្ធនឹងសំណួរនោះប៉ុណ្ណោះ។ ប្រជាពលរដ្ឋនៃរដ្ឋដែលជាភាគីវិវាទ មិនអាចចូលនៅក្នុងក្រុមអ្នកជំនាញនោះទេប្រសិនបើគ្មានការព្រមព្រៀងរួមមួយរវាងភាគីវិវាទ លើកលែងតែកាលៈទេសៈពិសេស ដែលគណៈវិនិច្ឆ័យមិនអាចស្វែងរកអ្នកជំនាញបាន។ គួរបញ្ជាក់ថា មន្ត្រីរដ្ឋាភិបាលនៃភាគីវិវាទ មិនអាចបំពេញការងារក្នុងក្រុមអ្នកជំនាញនោះទេ ហើយសមាជិកនៃក្រុមអ្នកជំនាញ បម្រើការងារដោយក្នុងនាមខ្លួនផ្ទាល់ មិនមែនក្នុងនាមជាតំណាងរបស់រដ្ឋាភិបាល ឬក៏តំណាងរបស់អង្គការនានានោះឡើយ។ រដ្ឋាភិបាល និងអង្គការទាំងនោះ មិនត្រូវផ្តល់នូវការណែនាំដល់ក្រុមអ្នកជំនាញពាក់ព័ន្ធនឹងបញ្ហា ដែលដាក់ចូលទៅក្រុមអ្នកជំនាញឡើយ។

កត់សម្គាល់ឃើញថា ការពឹងពាក់របស់គណៈវិនិច្ឆ័យលើអ្នកជំនាញកន្លងមក គណៈវិនិច្ឆ័យមិនបានបង្កើតក្រុមអ្នកជំនាញទេ ប៉ុន្តែគណៈវិនិច្ឆ័យធ្វើការប្រឹក្សាជាមួយអ្នកជំនាញជាលក្ខណៈបុគ្គល។ គណៈវិនិច្ឆ័យជ្រើសរើសអ្នកជំនាញអោយធ្វើការប្រឹក្សាជាមួយនឹងភាគី បង្កើតជាបញ្ជីសំណួរដាក់ជូនអ្នកជំនាញម្នាក់ៗ ហើយដែលអ្នកជំនាញម្នាក់ៗនោះត្រូវធ្វើការឆ្លើយតបជាលាយលក្ខណ៍អក្សរ។ ក្នុងនោះដែរ គណៈវិនិច្ឆ័យហៅប្រជុំជាមួយនិងអ្នកជំនាញ និងភាគីវិវាទ ដើម្បីធ្វើការពិភាក្សាអំពីសំណួរទាំងនេះនិងសំណួរដទៃទៀត។ ជាធម្មតាសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យតែងតែឆ្លុះបញ្ចាំងនូវការឆ្លើយតបជាលាយលក្ខណ៍អក្សររបស់អ្នកជំនាញ ចំពោះសំណួររបស់គណៈវិនិច្ឆ័យ និងកិច្ចពិភាក្សានៅក្នុងការប្រជុំរវាងគណៈវិនិច្ឆ័យ អ្នកជំនាញ និងភាគីវិវាទ។

## ១.៥. បទដ្ឋានគតិយុត្តសម្រាប់ការដោះស្រាយវិវាទ

នៅក្នុងការដោះស្រាយវិវាទដែលកើតមានរវាងសមាជិកអង្គការ WTO ត្រូវធ្វើឡើងដោយអនុលោមទៅតាមលិខិតបទដ្ឋានគតិយុត្តរបស់អង្គការ WTO ឬលិខិតបទដ្ឋានគតិយុត្តដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អង្គការ WTO ដែលកំណត់អំពីរបៀបនៃការដោះស្រាយវិវាទ និងដែលត្រូវយកមកធ្វើជាសំអាងច្បាប់សម្រាប់ដំណោះស្រាយនានាដែលរកឃើញ ដើម្បីអោយភាគីវិវាទអាចទទួលយកបាននូវដំណោះស្រាយទាំងនោះ។ ក្នុងចំណោមលិខិតបទដ្ឋានគតិយុត្តជាច្រើន លិខិតបទដ្ឋានគតិយុត្តសំខាន់ៗដែលត្រូវបានប្រើដើម្បីដោះស្រាយវិវាទនោះមានដូចជា៖

### ១.៥.១. កិច្ចព្រមព្រៀងទីក្រុង Marrakesh ស្តីពីការបង្កើតអង្គការពាណិជ្ជកម្មពិភពលោក

កិច្ចព្រមព្រៀងនេះ ត្រូវបានបង្កើតឡើងនៅក្នុងកិច្ចប្រជុំនៅអ៊ុយរ៉ាហ្គាយ ដែលគេអាចហៅម្យ៉ាងទៀតថា Uruguay Round Agreement។ កិច្ចព្រមព្រៀងនេះ សម្រេចឡើងដើម្បីបង្កើតអង្គការ

ពាណិជ្ជកម្មពិភពលោក នៅថ្ងៃទី ០១ ខែមករា ឆ្នាំ ១៩៩៥ ដែលរួមមាន ១៦ មាត្រា កំណត់អំពីការបង្កើតអង្គការនេះឡើង ដែនកំណត់ មុខងារ និងរចនាសម្ព័ន្ធរបស់អង្គការ ទំនាក់ទំនងរបស់អង្គការជាមួយនឹងស្ថាប័នដទៃទៀត ថវិការបស់អង្គការ និងវិភាគទានរបស់សមាជិកអង្គការ សមាជិកភាព ការសម្រេចសេចក្តីនៅក្នុងអង្គការ និងចំណុចផ្សេងៗជាច្រើនទៀត។ ជាពិសេស កិច្ចព្រមព្រៀងមានភ្ជាប់ជាមួយនូវឧបសម្ព័ន្ធ(Annex)មួយចំនួន ដែលក្នុងនោះមានឧបសម្ព័ន្ធ 2 កំណត់អំពីប្រព័ន្ធដោះស្រាយវិវាទរបស់អង្គការ WTO។ នៅក្នុងកិច្ចព្រមព្រៀងអង្គការ WTO ក៏មានកំណត់នូវសិទ្ធិ និងកាតព្វកិច្ចសំខាន់ៗរបស់សមាជិកអង្គការ ដែលភាគីអាចយកមកធ្វើជាអំណះអំណាងនៅក្នុងបញ្ហាវិវាទរបស់ខ្លួន។

### ១.៥.២. ឧបសម្ព័ន្ធ 2 ស្តីពីការស្វែងយល់អំពីវិធាន និងនីតិវិធីគ្រប់គ្រងលើការដោះស្រាយវិវាទ

ឧបសម្ព័ន្ធ2 ឬ DSU មានកំណត់យ៉ាងលំអិតអំពីវិធាន និងនីតិវិធីនៃការដោះស្រាយវិវាទពាណិជ្ជកម្មនៅក្នុងអង្គការ WTO ដែលនៅក្នុងនោះមានកំណត់អំពី វិសាលភាព និងការអនុវត្តនូវវិធាន និងនីតិវិធីទាំងអស់នេះ អង្គភាពដែលពាក់ព័ន្ធនឹងការដោះស្រាយវិវាទ ព្រមទាំងនីតិវិធីនៃការដោះស្រាយវិវាទ។

វិធាន និងនីតិវិធីនៃ DSU ត្រូវយកមកអនុវត្តចំពោះវិវាទដែលត្រូវបានដាក់ចូលអោយដោះស្រាយ ស្របតាមបទបញ្ញត្តិស្តីពីការប្រឹក្សា និងការដោះស្រាយវិវាទនៅក្នុងកិច្ចព្រមព្រៀងដែលបានដាក់ក្នុងឧបសម្ព័ន្ធ១នៃ DSU។ វិធាន និងនីតិវិធីនៃDSU ត្រូវអនុវត្តចំពោះការប្រឹក្សា និងការដោះស្រាយវិវាទរវាងសមាជិកដែលមានជាប់ពាក់ព័ន្ធលើសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនក្រោមបទបញ្ញត្តិនៃកិច្ចព្រមព្រៀងបង្កើតអង្គការពាណិជ្ជកម្មពិភពលោក និងក្រោម DSU ដាច់ដោយឡែក ឬដោយរួមផ្សំជាមួយនឹងកិច្ចព្រមព្រៀងពាក់ព័ន្ធផ្សេងទៀត។

ក្រៅពីនេះ ឧបសម្ព័ន្ធ2 ក៏មានកំណត់អំពីនីតិវិធីពិសេសចំពោះករណីដែលមានការតវ៉ាច្រើនលើបញ្ហាតែមួយ និងចំពោះបញ្ហាវិវាទដែលដែលជាប់ទាក់ទងនឹងប្រទេសអភិវឌ្ឍន៍តិចតួច និងប្រទេសកំពុងអភិវឌ្ឍន៍ នីតិវិធីចំពោះការចូលរួមរបស់ភាគីទីបី សិទ្ធិផ្សេងៗរបស់សមាជិក ការអនុវត្តស្របតាមវិធាន និងអនុសាសន៍ដែលទទួលបានពីការដោះស្រាយ ព្រមទាំងវិធានការណ៍នានាចំពោះករណីមិនអនុវត្តស្របតាមវិធាន និងអនុសាសន៍ទាំងនោះផងដែរ។ បន្ថែមលើនេះទៀត នៅក្នុងឧបសម្ព័ន្ធ2 នេះមានភ្ជាប់នូវឧបសម្ព័ន្ធមួយចំនួន ដើម្បីធ្វើការបញ្ជាក់លំអិតបន្ថែមទៀតលើ

ប្រព័ន្ធដោះស្រាយវិវាទនេះដូចជា ឧបសម្ព័ន្ធស្តីពីរយៈពេលសម្រាប់ការដោះស្រាយវិវាទ និង ឧបសម្ព័ន្ធស្តីពីនីតិវិធីការងារជាដើម។

### ១.៥.៣. កិច្ចព្រមព្រៀងពាណិជ្ជកម្មពហុភាគី និងកិច្ចព្រមព្រៀងពាណិជ្ជកម្មច្រើនភាគី

នៅក្នុងការដោះស្រាយវិវាទពាណិជ្ជកម្ម ក្រៅពីពឹងផ្អែកទៅលើបទដ្ឋានគតិយុត្តខាងលើ អង្គភាពទទួលបន្ទុកដោះស្រាយវិវាទ ក៏ត្រូវពឹងផ្អែកលើបទដ្ឋានគតិយុត្តផ្សេងទៀត ដើម្បីធ្វើជាសំអាងច្បាប់នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ដោយលើកយកបទដ្ឋានគតិយុត្តណាពាក់ព័ន្ធនឹងបញ្ហាវិវាទដែលដាក់ចូលក្នុងអង្គការដើម្បីធ្វើការដោះស្រាយ ក្នុងនោះវាអាចជាកិច្ចព្រមព្រៀងពាណិជ្ជកម្មពហុភាគី ឬកិច្ចព្រមព្រៀងពាណិជ្ជកម្មច្រើនភាគី។ ចំពោះកិច្ចព្រមព្រៀងពាណិជ្ជកម្មពហុភាគី អាចមានកិច្ចព្រមព្រៀងពហុភាគីស្តីពីពាណិជ្ជកម្មលើទំនិញ កិច្ចព្រមព្រៀងពហុភាគីស្តីពីពាណិជ្ជកម្មលើសេវាកម្ម និងកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា។ ចំណែកឯកិច្ចព្រមព្រៀងពាណិជ្ជកម្មច្រើនភាគី អាចមានកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មអាកាសចរណ៍ស៊ីវិល កិច្ចព្រមព្រៀងស្តីពីសម្បទានរបស់រដ្ឋាភិបាល កិច្ចព្រមព្រៀងអន្តរជាតិស្តីពីផលិតផលទឹកដោះគោ កិច្ចព្រមព្រៀងអន្តរជាតិស្តីពីផលិតផលសាច់គោជាដើម។

### ១.៥.៤. កិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្ម និងពន្ធគយ GATT

កិច្ចព្រមព្រៀងនេះ ជាកិច្ចព្រមព្រៀងពហុភាគីដែលធ្វើការកំណត់អំពីការធ្វើពាណិជ្ជកម្មអន្តរជាតិ ដែលមានគោលបំណងធានានូវស្ថេរភាពនៃការកាត់បន្ថយពន្ធ និងរបាំងពាណិជ្ជកម្ម ព្រមទាំងលុបបំបាត់នូវភាពលំអៀងនៅក្នុងការធ្វើពាណិជ្ជកម្ម ដោយឈរលើមូលដ្ឋានផលប្រយោជន៍ទៅវិញទៅមក និងផលប្រយោជន៍ពហុភាគី។ វាត្រូវបានបង្កើតឡើងនៅក្នុងសន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និងការងារ នៅទីក្រុងហាវ៉ាណា ថ្ងៃទី ៣០ ខែតុលា ឆ្នាំ ១៩៤៧ ហើយចូលជាធរមាននៅថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៤៨។ ប៉ុន្តែកិច្ចព្រមព្រៀងនេះ ត្រូវបានជំនួសមកវិញកិច្ចព្រមព្រៀងនៅទីក្រុង Marrakesh បង្កើតនូវអង្គការពាណិជ្ជកម្មពិភពលោក WTO នៅថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៥។

### ១.៥.៥. កិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មលើសេវាកម្ម

កិច្ចព្រមព្រៀងនេះ គឺជាសន្ធិសញ្ញាមួយរបស់អង្គការពាណិជ្ជកម្មពិភពលោក ដែលចូលជាធរមាននៅខែ មករា ឆ្នាំ១៩៩៥ តាមរយៈការចរចានៅកិច្ចប្រជុំ Uruguay Round ដើម្បីពង្រីកប្រព័ន្ធនៃការធ្វើពាណិជ្ជកម្មទៅលើវិស័យសេវាកម្ម។

### ១.៥.៦. កិច្ចព្រមព្រៀងផ្សេងៗទៀត

នៅក្នុងការដោះស្រាយវិវាទពាណិជ្ជកម្មនៅក្នុងអង្គការ WTO អាចត្រូវប្រើប្រាស់នូវបទដ្ឋានគតិយុត្តផ្សេងៗជាច្រើនទៀតដែលស្ថិតក្រោមការគ្រប់គ្រងរបស់អង្គការ ឬកិច្ចព្រមព្រៀងទ្វេភាគីដែលត្រូវបានធ្វើឡើងដោយសមាជិករបស់អង្គការ  វាអាស្រ័យទៅលើវិវាទដែលកើតមានឡើងនោះមានជាប់ពាក់ព័ន្ធនឹងលិខិតបទដ្ឋានគតិយុត្តមួយណាប៉ុណ្ណោះ។

## ជំពូកទី២ ដំណើរការដោះស្រាយវិវាទរបស់អង្គការពាណិជ្ជកម្មពិភពលោក

នៅក្នុងដំណើរការនៃការដោះស្រាយវិវាទពាណិជ្ជកម្មអន្តរជាតិ នៅក្នុងអង្គការ WTO មានដំណាក់កាលជាច្រើន ដើម្បីធានាថាសមាជិកអង្គការបានប្រើប្រាស់សិទ្ធិរបស់ខ្លួនយ៉ាងពេញលេញ ក្នុងករណីដែលគេមិនពេញចិត្តនឹងដំណោះស្រាយនៅក្នុងដំណាក់កាលណាមួយ។ ក៏ប៉ុន្តែ ភាគីសុទ្ធតែអាចបញ្ចប់វិវាទរបស់ខ្លួន នៅក្នុងដំណាក់កាលណាមួយបានជានិច្ច ប្រសិនបើពួកគេមិនចង់អោយបញ្ហាវិវាទរបស់ខ្លួនត្រូវឆ្លងកាត់ការដោះស្រាយវែងឆ្ងាយ។

### ២.១. ការប្រឹក្សារវាងភាគី

ការប្រឹក្សារវាងភាគី គឺជាដំណាក់កាលដំបូងនៃការដោះស្រាយវិវាទរបស់អង្គការពាណិជ្ជកម្មពិភពលោក ដែលតម្រូវអោយភាគីទាំងសងខាងនៃវិវាទចូលខ្លួនមកធ្វើការចរចា ប្រឹក្សាជាមួយគ្នាដើម្បីស្វែងរកនូវដំណោះស្រាយចំពោះបញ្ហាវិវាទរបស់ខ្លួន។

#### ២.១.១. កម្មវត្ថុនៃការប្រឹក្សា

កម្មវត្ថុដែល DSU ចង់បានគឺ សមាជិកដែលជាភាគីវិវាទធ្វើការដោះស្រាយវិវាទដោយខ្លួនឯងក្នុងអាកប្បកិរិយាដែលស្របទៅនឹងកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក។ យោងតាមនេះ ការប្រឹក្សាទ្វេភាគីរវាងភាគីវិវាទ គឺជាដំណាក់កាលដំបូងនៃការដោះស្រាយវិវាទជាផ្លូវការ។ ភាគីមានឱកាសក្នុងការពិភាក្សាគ្នាអំពីបញ្ហា និងស្វែងរកនូវដំណោះស្រាយជាទីពេញចិត្តមួយដោយមិនចាំបាច់ដាក់រឿងក្តីរបស់ខ្លួនក្នុងពាក្យបណ្តឹងបន្តដើម្បីជំនុំជម្រះ។ ទាល់តែការប្រឹក្សានោះមិនអាចស្វែងរកនូវដំណោះស្រាយជាទីពេញចិត្តនៅក្នុងអំឡុងពេល៦០ថ្ងៃ ទើបដើមបណ្តឹងអាចស្នើឲ្យមានការជំនុំជម្រះដោយគណៈវិនិច្ឆ័យ។ ទោះបីជាការប្រឹក្សាបរាជ័យក្នុងការដោះស្រាយបញ្ហាក៏វានៅតែអាចធ្វើទៅបានសម្រាប់ភាគីស្វែងរកនូវដំណោះស្រាយ ដែលមានការព្រមព្រៀងគ្នាទៅវិញទៅមក នៅដំណាក់កាលក្រោយៗទៀតនៃដំណើរការដោះស្រាយវិវាទផងដែរ។

វិវាទភាគច្រើនកន្លងមកក្នុងអង្គការ WTO ត្រូវបានបញ្ចប់នៅក្នុងដំណាក់កាលនៃការប្រឹក្សានេះក៏ព្រោះថា ដំណោះស្រាយជាទីពេញចិត្តត្រូវបានរកឃើញ ឬក៏ព្រោះតែភាគីដែលជាដើមបណ្តឹងសម្រេចមិនបន្តការប្តឹងបន្តទៅទៀត។ នេះបង្ហាញឲ្យឃើញថា ការប្រឹក្សាជាញឹកញាប់ជាមធ្យោបាយមានប្រសិទ្ធិភាពសម្រាប់ការដោះស្រាយវិវាទក្នុងអង្គការ ហើយក៏បង្ហាញឲ្យឃើញថា មធ្យោបាយនៃការកាត់សេចក្តី និងការបង្ខំអនុវត្តនៅក្នុងប្រព័ន្ធដោះស្រាយវិវាទ មិនមែនតែងតែចាំបាច់នោះទេ។

ជាមួយនឹង Good Office ការសម្រុះសម្រួល និងសន្ធានកម្ម ការប្រឹក្សាគឺជាគន្លឹះនៃការដោះស្រាយវិវាទនៅក្នុងប្រព័ន្ធដោះស្រាយវិវាទរបស់ WTO ដែលមិនមានលក្ខណៈជាសាលជម្រះក្តី តែមានលក្ខណៈជាការចរចាការទូតច្រើនជាង។ ការប្រឹក្សាក៏អនុញ្ញាតឲ្យភាគីធ្វើការស្រាយបញ្ជាក់នូវការពិតនៃបញ្ហា និងការអះអាងរបស់ដើមបណ្តឹងផងដែរ ហើយក៏អាចលុបចោលនូវការយល់ច្រឡំលើលក្ខណៈពិតប្រាកដរបស់វិធានដែលចោទជាបញ្ហានោះ។ ក្នុងន័យនេះ ការប្រឹក្សាគឺជាមូលដ្ឋានសម្រាប់ការដោះស្រាយ និងសម្រាប់ដំណើរការបន្តទៅទៀតរបស់ DSU ។

### ២.១.២. មូលដ្ឋានច្បាប់ និងលក្ខខណ្ឌដើម្បីស្នើសុំការប្រឹក្សា

សំណើសុំការប្រឹក្សាពីសំណាក់សមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក គឺជាសញ្ញាបង្ហាញឲ្យឃើញពីការចាប់ផ្តើមកកើតមាននូវវិវាទរវាងសមាជិកនៅក្នុងអង្គការ និងការប្រើប្រាស់នូវ DSUពីសំណាក់សមាជិករបស់អង្គការ។ ក៏ប៉ុន្តែមុននឹងឈានដល់មានការស្នើសុំការប្រឹក្សា ជាញឹកញាប់គឺមាននូវកិច្ចពិភាក្សាក្រៅផ្លូវការលើបញ្ហាដែលកើតឡើងរវាងសមាជិករបស់អង្គការ តាមរយៈមន្ត្រី ឬប្រតិភូប្រចាំនៅទីក្រុងហ្សឺណែវរបស់សមាជិកដែលមានជាប់ពាក់ព័ន្ធទៅនឹងបញ្ហានោះ នៅមុនពេលមានការប្រឹក្សាជាផ្លូវនៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក។[35] គួរបញ្ជាក់ថា ទោះបីជាមាននូវការប្រឹក្សារវាងភាគីពីមុនហើយក៏ដោយ ក៏ដើមបណ្តឹងចាំបាច់ត្រូវឆ្លងកាត់នីតិវិធីនៃការប្រឹក្សាដូចមានកំណត់នៅក្នុងDSUជាមុនសិន មុននឹងអាចឈានទៅដល់ដំណើរការបន្តបន្ទាប់ទៀតនៅក្នុងប្រព័ន្ធដោះស្រាយវិវាទនេះ។

សមាជិកដែលជាដើមបណ្តឹង ត្រូវលើកសំណើសុំការប្រឹក្សាទៅកាន់សមាជិកដែលជាចុងចម្លើយ ប៉ុន្តែក៏ត្រូវជូនដំណឹងអំពីសំណើនោះទៅកាន់អង្គភាពដោះស្រាយវិវាទ និងទៅកាន់ក្រុមប្រឹក្សា និងគណៈកម្មាការដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវលើកិច្ចព្រមព្រៀងដែលចោទជាបញ្ហាឡើងនោះផងដែរ។ សមាជិកដែលជាដើមបណ្តឹង ត្រូវផ្ញើរនូវលិខិតជូនដំណឹងអំពីសំណើសុំការប្រឹក្សាដូចខាងលើតែមួយច្បាប់ប៉ុណ្ណោះទៅកាន់លេខាធិការដ្ឋាន ដោយគ្រាន់តែបញ្ជាក់អំពីក្រុមប្រឹក្សា និងគណៈកម្មាការដែលពាក់ព័ន្ធដើម្បីឲ្យលេខាធិការដ្ឋានធ្វើការជូនដំណឹងបន្ត។ ដើមបណ្តឹងត្រូវធ្វើសំណើដោយស្របទៅតាមកិច្ចព្រមព្រៀងមួយ ឬច្រើនដែលគ្រប់គ្រងលើបញ្ហាដែលខ្លួនប្តឹងតវ៉ា ជាពិសេសស្របតាមបទបញ្ញត្តិស្តីពីការប្រឹក្សាដែលមានចែងក្នុងកិច្ចព្រមព្រៀងនោះ។ ដូច្នេះ

[35] Dispute Settlement System Training Module [ មេរៀនបណ្តុះបណ្តាលស្តីពីប្រព័ន្ធដោះស្រាយវិវាទ], https://www.wto.org/english/tratop_e/dispu_e/disp_settlement_cbt_e/signin_e.htm (ចូលអាន និងទាញយក ថ្ងៃទី 5 ឧសភា 2015)។

ការប្រឹក្សាគឺយោងតាមបទបញ្ញត្តិនៃមាត្រា៤នៃDSU និងកិច្ចព្រមព្រៀងដាច់ដោយឡែកផ្សេងទៀតរបស់សមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក។

សំណើសុំការប្រឹក្សាត្រូវតែដាក់ជូនជាឯកសារលាយលក្ខណ៍អក្សរ និងត្រូវតែផ្តល់មូលហេតុសម្រាប់ការស្នើសុំ។ ជាមួយគ្នានេះដែរ នៅក្នុងពាក្យស្នើសុំនោះត្រូវមានការកំណត់អំពីវិធានដែលចោទជាបញ្ហាឡើង និងធ្វើការចង្អុលបង្ហាញពីមូលដ្ឋានច្បាប់សម្រាប់ការតវ៉ាទាមទារ និងការអះអាងរបស់ខ្លួន។[36] នៅក្នុងការអនុវត្ត ពាក្យស្នើសុំការប្រឹក្សានេះគឺត្រូវធ្វើដោយសង្ខេបបំផុត ជាទូទៅមិនលើសពីមួយ ឬពីរទំព័រទេ ប៉ុន្តែវាត្រូវតែមានភាពច្បាស់លាស់គ្រប់គ្រាន់។ ដោយសារថា ពាក្យស្នើសុំការប្រឹក្សា គឺជាឯកសារផ្លូវការដំបូងរបស់អង្គការពាណិជ្ជកម្មពិភពលោកដែលបញ្ជាក់អំពីការលេចឡើងនូវវិវាទជាក់លាក់មួយ ដូច្នេះហើយបញ្ហាវិវាទនីមួយៗត្រូវមាននូវWT/DS number របស់វា។ មុនពេលចាប់ផ្តើមការប្រឹក្សា សមាជិកមានកាតព្វកិច្ចត្រូវប្រើនូវការវិនិច្ឆ័យផ្ទាល់ខ្លួន ថាតើសកម្មភាពក្រោមប្រព័ន្ធដោះស្រាយវិវាទអាចផ្តល់នូវលទ្ធផលផ្លែផ្កាដែរឬទេ។ គោលបំណងរបស់យន្តការនៃការដោះស្រាយវិវាទនេះគឺធានានូវដំណោះស្រាយជាវិជ្ជមានសម្រាប់វិវាទពាណិជ្ជកម្ម។[37] តាមការបង្ហាញន័យនៃមាត្រា៣ ចំណុច ៧ នៃDSU មាត្រានេះផ្តុកផ្ទាក់ឲ្យសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក នូវការទទួលខុសត្រូវក្នុងការមានវិធានផ្ទាល់ខ្លួនក្នុងការវិនិច្ឆ័យការសម្រេចថាតើពួកគេអាចទទួលបានលទ្ធផលជាផ្លែផ្កាទេ បើដាក់រឿងក្តីចូលទៅក្នុងយន្តការដោះស្រាយវិវាទនេះ។

### ២.១.៣. នីតិវិធីនៃការប្រឹក្សា

ចុងចម្លើយ មានកាតព្វកិច្ចត្រូវស្របទៅតាមការប្រឹក្សា និងត្រូវបានផ្តល់នូវឱកាសសមរម្យសម្រាប់ការចូលរួមនៅក្នុងការប្រឹក្សា។ ការប្រឹក្សាធ្វើឡើងនៅក្នុងទីក្រុងហ្សឺណែវ និងត្រូវបានរក្សាការសម្ងាត់ ហើយលេខាធិការដ្ឋានអង្គការពាណិជ្ជកម្មពិភពលោក មិនមានជាប់ពាក់ព័ន្ធនឹងការប្រឹក្សានេះទេ។ ម្យ៉ាងទៀត ការណ៍ដែលការប្រឹក្សាធ្វើឡើងនៅក្នុងបន្ទប់បិទទ្វារជិត ក៏មានន័យថាខ្លឹមសារនៃការប្រឹក្សា គឺមិនត្រូវបានបើកបង្ហាញដល់គណៈវិនិច្ឆ័យណាមួយ ដែលអាចនឹងត្រូវបានចាត់តាំងអោយធ្វើការដោះស្រាយនូវវិវាទនេះនាពេលបន្ទាប់ឡើយ។

ចុងចម្លើយត្រូវធ្វើការឆ្លើយតបទៅនឹងសំណើសុំការប្រឹក្សាក្នុងអំឡុងពេល១០ថ្ងៃ និងត្រូវចូលរួមនៅក្នុងការប្រឹក្សាដោយឆន្ទៈស្មោះត្រង់ នៅក្នុងអំឡុងពេលមិនលើសពី៣០ថ្ងៃ បន្ទាប់ពីកាល

[36] DSU, 1995, មាត្រា 4 ចំណុច 4។

[37] DSU, 1995, មាត្រា 3 ចំណុច 7។

បរិច្ឆេទទទួលបាននូវសំណើសុំការប្រឹក្សា។[38] ប្រសិនបើចុងចម្លើយមិនបានគោរពតាមអំឡុងពេលទាំងនេះទេ ដើមបណ្តឹងអាចដាក់ដំណើរការរឿងក្តីចូលទៅដំណាក់កាលនៃការជំនុំជម្រះនៃការដោះស្រាយវិវាទភ្លាមៗតែម្តង ហើយស្នើសុំបង្កើតគណៈវិនិច្ឆ័យ។[39] ប្រសិនបើចុងចម្លើយចូលរួមក្នុងដំណាក់កាលនៃការប្រឹក្សា ដើមបណ្តឹងអាចស្នើសុំបង្កើតគណៈវិនិច្ឆ័យមួយយ៉ាងលឿនបំផុត ៦០ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទនៃការទទួលនូវសំណើសុំការប្រឹក្សា ក្នុងករណីដែលមិនមានដំណោះស្រាយជាទីពេញចិត្តណាមួយត្រូវបានរកឃើញក្នុងពេលនៃការប្រឹក្សា។[40] ទោះជាយ៉ាងណាក៏ដោយដំណាក់កាលនៃការប្រឹក្សាអាចត្រូវបានបញ្ចប់មុនពេលកំណត់ ប្រសិនបើភាគីមានការយល់ឃើញរួមគ្នាថា ការប្រឹក្សានឹងមិនអាចដោះស្រាយវិវាទរបស់ពួកគេបានទេ។[41] នៅក្នុងអនុវត្តភាគីវិវាទជាញឹកញាប់ទុកពេលវេលាឲ្យខ្លួនឯងច្រើនជាងអប្បបរមា៦០ថ្ងៃសម្រាប់ដំណាក់កាលនៃការប្រឹក្សា។

គួរបញ្ជាក់ថា នៅក្នុងករណីបន្ទាន់ ឬករណីមានការព្រួយបារម្ភចំពោះការខូចខាតផលិតផលភាគីត្រូវចូលរួមនៅក្នុងការប្រឹក្សា ក្នុងអំឡុងពេលដែលមិនលើសពី១០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទទទួលបាននូវសំណើសុំការប្រឹក្សា។ ប្រសិនបើការប្រឹក្សាបរាជ័យក្នុងការស្វែងរកនូវដំណោះស្រាយក្នុងអំឡុងពេល២០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលបានសំណើសុំការប្រឹក្សាភាគីដើមបណ្តឹងអាចស្នើសុំបង្កើតនូវគណៈវិនិច្ឆ័យបាន។[42]

### ២.១.៤. ភាគីទីបីនៅក្នុងការប្រឹក្សា

សមាជិកអង្គការពាណិជ្ជកម្មពិភពលោកដែលមិនមែនជាដើមបណ្តឹង និងចុងចម្លើយអាចចាប់អារម្មណ៍នៅក្នុងបញ្ហាដែលភាគីវិវាទកំពុងធ្វើការពិភាក្សានៅក្នុងការប្រឹក្សារបស់ពួកគេ។ មានមូលហេតុជាច្រើននៃការចាប់អារម្មណ៍នោះដូចជា សមាជិកដទៃទៀតអាចមានផលប្រយោជន៍នៅក្នុងកិច្ចការពាណិជ្ជកម្ម ឬយល់ស្រដៀងគ្នាថារងនូវផលប៉ះពាល់ដោយសារវិធានដែលត្រូវបានគេតវ៉ា ឬក៏ផ្ទុយមកវិញអាចមានផលប្រយោជន៍ពីវិធានដែលត្រូវបានតវ៉ានោះ ឬមានការព្រួយបារម្ភចំពោះការតវ៉ា ដោយហេតុថាខ្លួនមានវិធានច្បាប់ដែលស្រដៀងនឹងវិធានរបស់ចុងចម្លើយដែលត្រូវ

---

[38] Daniel T. Shedd, Brandon J. Murrill, និងJane M. Smith, *Dispute settlement in the World Trade Organization: An overview* [ការដោះស្រាយវិវាទនៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក: ទិដ្ឋភាពទូទៅ] (USA: Congressional Research Service, 2012), 5, https://www.fas.org/sgp/crs/misc/RS20088.pdf ( ចូលអាន និងទាញយក ថ្ងៃទី 15 ឧសភា 2015)។

[39] DSU, 1995, មាត្រា 4 ចំណុច 3។

[40] ដូច 38 ។

[41] DSU, 1995, មាត្រា 4 ចំណុច 7។

[42] DSU, 1995, មាត្រា 4 ចំណុច 8។

បានគេតវ៉ាដែរ។ សមាជិកដូចដែលបានលើកឡើងខាងលើ អាចមានចំណាប់អារម្មណ៍នៅក្នុងការមានវត្តមាននៅក្នុងការពិភាក្សារកដំណោះស្រាយដែលមានការយល់ព្រមទ្វេភាគី ដោយសារតែដំណោះស្រាយទាំងនោះអាចប៉ះពាល់ដល់ផលប្រយោជន៍របស់ខ្លួន។

សមាជិកដទៃទៀតដូចបានរៀបរាប់ខាងលើនេះ អាចធ្វើការស្នើសុំចូលរួមនៅក្នុងការប្រឹក្សា បើពួកគេមានផលប្រយោជន៍សំខាន់ផ្នែកពាណិជ្ជកម្មក្នុងបញ្ហាដែលកំពុងត្រូវបានពិភាក្សា និងបើការប្រឹក្សាត្រូវបានស្នើសុំតាមមាត្រា ២២ចំណុច ១ នៃ GATT មាត្រា ២២ ចំណុច ១ នៃ GATS និងបទបញ្ញត្តិដែលពាក់ព័ន្ធនៅក្នុងកិច្ចព្រមព្រៀងផ្សេងទៀត ដែលអនុញ្ញាតឲ្យមានការចូលរួមរបស់ភាគីទីបី។ ការស្នើសុំត្រូវតែជូនដំណឹងទៅកាន់សមាជិកនៃការប្រឹក្សា(ដើមបណ្តឹង និងចុងចម្លើយ) និងអង្គភាពដោះស្រាយវិវាទ ក្នុងអំឡុងពេល១០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការផ្សព្វផ្សាយនូវសំណើសុំការប្រឹក្សារបស់ដើមបណ្តឹង។ សមាជិកដែលជាចុងចម្លើយ ត្រូវយល់ព្រមថា ការអះអាងលើផលប្រយោជន៍សំខាន់នៅក្នុងពាណិជ្ជកម្មពិតជាមានពិតមែន។ ប្រសិនបើចុងចម្លើយបដិសេធអំពីអត្ថិភាពនៃផលប្រយោជន៍ផ្នែកពាណិជ្ជកម្ម ដែលលើកឡើងដោយភាគីទីបីនោះ នឹងមិនអនុញ្ញាតឲ្យមានការប្តឹងឧទ្ធរណ៍ពីសំណាក់ភាគីទីបី ដើម្បីទាមទារឲ្យមានវត្តមានរបស់ខ្លួននៅក្នុងការប្រឹក្សាឡើយ មិនថាផលប្រយោជន៍ផ្នែកពាណិជ្ជកម្មដែលលើកឡើងមានភាពស្របច្បាប់យ៉ាងណានោះទេ។

## ២.២. ការដោះស្រាយវិវាទនៅក្នុងគណៈវិនិច្ឆ័យ

ប្រសិនបើការប្រឹក្សាមិនអាចស្វែងរកនូវដំណោះស្រាយវិវាទទេ ការដោះស្រាយវិវាទនេះនឹងឈានទៅកាន់ដំណាក់កាលបន្ទាប់គឺ ការដោះស្រាយវិវាទនៅក្នុងគណៈវិនិច្ឆ័យ ដោយក្នុងនោះដើមបណ្តឹងស្នើសុំឲ្យមានការបង្កើតនូវគណៈវិនិច្ឆ័យ ដើម្បីជំនុំជម្រះលើបណ្តឹងរបស់ខ្លួន។ ការស្នើសុំនេះ អាចធ្វើពេលណាក៏បានក្នុងអំឡុងពេល៦០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទដែលចុងចម្លើយទទួលបាននូវសំណើសុំការប្រឹក្សា។ ប៉ុន្តែដើមបណ្តឹងក៏អាចសុំបង្កើតគណៈវិនិច្ឆ័យមុនពេលដែលបានកំណត់ខាងលើបានដែរ ក្នុងករណីដែលភាគីចុងចម្លើយនៅតែមិនធ្វើការឆ្លើយតបលើសំណើសុំការប្រឹក្សា បន្ទាប់ពីផុតអំឡុងពេលដែលបានកំណត់សម្រាប់ឲ្យភាគីចុងចម្លើយ ធ្វើការឆ្លើយតបចំពោះសំណើនោះ ឬករណីមួយទៀតគឺ ភាគីទាំងពីរយល់ឃើញដូចគ្នាថា ការប្រឹក្សានឹងមិនអាចស្វែងរកនូវដំណោះស្រាយសម្រាប់វិវាទរបស់ខ្លួនបាន។[43] ករណីដែលដើមបណ្តឹងមានការមិនពេញចិត្តនឹងលទ្ធផលនៃការប្រឹក្សា ការបើកផ្លូវឲ្យដើមបណ្តឹងចាប់ផ្តើមដំណើរការដោះស្រាយក្នុងគណៈវិនិច្ឆ័យ

[43] DSU, 1995, មាត្រា 4 ចំណុច 7។

គឺជាការផ្តល់ឲ្យដើមបណ្តឹងនូវសិទ្ធិក្នុងការរក្សានូវសិទ្ធិ ឬធានានូវផលប្រយោជន៍របស់ខ្លួនក្នុងកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក។ នីតិវិធីនេះក៏មានភាពសំខាន់ដូចគ្នាចំពោះចុងចម្លើយផងដែរ ព្រោះវាក៏ជាឱកាសរបស់ចុងចម្លើយក្នុងការការពារខ្លួន ដោយសារថាចុងចម្លើយអាចមានការមិនយល់ស្របនឹងដើមបណ្តឹងលើអង្គហេតុ ការបកស្រាយអំពីកាតព្វកិច្ចនិងផលប្រយោជន៍ក្រោមកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក។ ដំណាក់កាលនៃការជំនុំជម្រះក្នុងការដោះស្រាយវិវាទ មានគោលបំណងនៅក្នុងការដោះស្រាយវិវាទផ្នែកច្បាប់ ហើយភាគីទាំងពីរត្រូវទទួលយកនូវវិធានបង្ខំនានា ដែលត្រូវបានដាក់ចេញក្នុងដំណាក់កាលនៃការជំនុំជម្រះនេះ។

### ២.២.១. ការចាប់ផ្តើម (ការបង្កើតនូវគណៈវិនិច្ឆ័យ)

ការស្នើសុំបង្កើតគណៈវិនិច្ឆ័យ គឺជាការចាប់ផ្តើមនូវដំណាក់កាលនៃការជំនុំជម្រះនៅក្នុងប្រព័ន្ធដោះស្រាយវិវាទរបស់អង្គការពាណិជ្ជកម្មពិភពលោក។ ការស្នើសុំបង្កើតគណៈវិនិច្ឆ័យត្រូវតែធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវជូនដំណឹងទៅកាន់ប្រធានអង្គភាពដោះស្រាយវិវាទ។ ការស្នើសុំនេះ នឹងក្លាយជាឯកសារផ្លូវការមួយនៅក្នុងការដោះស្រាយបញ្ហាវិវាទ និងដែលត្រូវផ្សព្វផ្សាយទៅកាន់សមាជិកទាំងអស់របស់អង្គការពាណិជ្ជកម្មពិភពលោក។ ដើម្បីឲ្យពាក្យស្នើសុំបង្កើតគណៈវិនិច្ឆ័យនេះ អាចត្រូវបានដាក់បញ្ចូលទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំរបស់អង្គភាពដោះស្រាយវិវាទ ការស្នើសុំនេះ ត្រូវធ្វើឡើងយ៉ាងហោចណាស់១១ថ្ងៃមុនកិច្ចប្រជុំរបស់អង្គភាពដោះស្រាយវិវាទ។ ពាក្យស្នើសុំនេះត្រូវបង្ហាញថាតើ ការប្រឹក្សាត្រូវបានធ្វើឡើងដែរឬទេ ធ្វើការបង្ហាញនូវវិធានដែលចោទជាបញ្ហាឡើង ព្រមទាំងធ្វើការលើកឡើងដោយសង្ខេប និងច្បាស់លាស់នូវមូលដ្ឋានច្បាប់នៃការប្តឹងតវ៉ានោះ។[44]

ខ្លឹមសារនៃសំណើសុំបង្កើតគណៈវិនិច្ឆ័យមានសារៈសំខាន់ ព្រោះថា សំណើសុំនោះធ្វើការកំណត់នូវលក្ខខណ្ឌសម្រាប់ការត្រួតពិនិត្យរបស់គណៈវិនិច្ឆ័យទៅលើបញ្ហាវិវាទ។ និយាយមួយបែបទៀត សំណើសុំបង្កើតនូវគណៈវិនិច្ឆ័យធ្វើការកំណត់និងកម្រិតនូវវិសាលភាពនៃវិវាទដែលតាមរយៈនេះធ្វើការកំណត់នូវយុត្តាធិការរបស់គណៈវិនិច្ឆ័យទៅលើបញ្ហាវិវាទ។ មានតែបញ្ហាដែលកំណត់នៅក្នុងពាក្យស្នើសុំទេដែលក្លាយជាកម្មវត្ថុនៃការត្រួតពិនិត្យរបស់គណៈវិនិច្ឆ័យ ហើយគណៈវិនិច្ឆ័យនឹងធ្វើការពិនិត្យនៅក្នុងទំហំនៃបទបញ្ញត្តិ ដែលលើកឡើងក្នុងពាក្យស្នើសុំរបស់ដើមបណ្តឹងតែ

[44] DSU, 1995, មាត្រា 6 ចំណុច 2។

ប៉ុណ្ណោះ។ បន្ថែមពីលើនេះទៀត ពាក្យសុំនេះក៏ជាឧបករណ៍មួយដែលអាចអោយភាគីចុងចម្លើយ និងភាគីទី៣អាចដឹងអំពីមូលដ្ឋាននៃការតវ៉ារបស់ដើមបណ្តឹងផងដែរ។[45]

ដូច្នេះ វាមានសារៈសំខាន់ណាស់ក្នុងការព្រាងនូវពាក្យស្នើសុំបង្កើតគណៈវិនិច្ឆ័យនោះជាមុនអោយមានភាពច្បាស់លាស់គ្រប់គ្រាន់ ដើម្បីជៀសវាងកុំឲ្យចុងចម្លើយធ្វើការលើកឡើងនូវការបដិសេធប្រឆាំងនឹងការអះអាងក្នុងពាក្យស្នើសុំនោះ និងដើម្បីជៀសវាងកុំឲ្យគណៈវិនិច្ឆ័យបដិសេធមិនធ្វើការដឹកនាំត្រួតពិនិត្យលើចំណុចណាមួយនៃការអះអាងតវ៉ានោះ។ ដើមបណ្តឹងត្រូវផ្តល់នូវសេចក្តីសង្ខេបអំពីមូលដ្ឋានច្បាប់នៃការតវ៉ានៅក្នុងពាក្យស្នើសុំ ដើម្បីធ្វើឲ្យមានភាពគ្រប់គ្រាន់ក្នុងការបង្ហាញនូវបញ្ហាអោយច្បាស់លាស់។ ប្រសិនបើសំណើសុំដំបូងមិនបញ្ជាក់អំពីការទាមទារឲ្យច្បាស់លាស់ទេ នោះដើមបណ្តឹងមិនអាចដាក់នូវការទាមទារនោះនៅក្នុងសំណើសុំនោះ នាពេលបន្ទាប់នៅក្នុងឯកសារជាលាយលក្ខណ៍អក្សរ និងសេចក្តីថ្លែងការណ៍ផ្ទាល់មាត់របស់ខ្លួនទៅកាន់គណៈវិនិច្ឆ័យឡើយ។ នៅក្នុងកាលៈទេសៈពិសេសនៃរឿងក្តីមួយចំនួន ការដាក់បញ្ជាក់នូវបញ្ជីនៃមាត្រានៃកិច្ចព្រមព្រៀងដែលទទួលរងនូវការរំលោភបំពាន គឺមានភាពគ្រប់គ្រាន់នៅក្នុងការបំពេញនូវលក្ខខណ្ឌតម្រូវអប្បបរមានៃDSU[46] ប៉ុន្តែបញ្ហាទាំងនេះត្រូវបានពិនិត្យដោយឈរលើមូលដ្ឋានម្តងមួយរឿងក្តីៗ។ ក្នុងករណីជាច្រើន ពេលមានការបដិសេធដំបូងដោយចុងចម្លើយ គណៈវិនិច្ឆ័យនិងអង្គភាពឧទ្ធរណ៍ធ្វើការសាកសួរថាតើ សមត្ថភាពរបស់ចុងចម្លើយក្នុងការការពារខ្លួនដោយធ្វើការបដិសេធនេះ មាននូវបុរេវិនិច្ឆ័យលើការខ្វះខាតនូវភាពច្បាស់លាស់នៅក្នុងសំណើសុំការបង្កើតនូវគណៈវិនិច្ឆ័យរបស់ដើមបណ្តឹងឬទេ។ ប្រសិនបើភាគីមិនបានព្រមព្រៀងគ្នាលើលក្ខខណ្ឌក្នុងការត្រួតពិនិត្យរបស់គណៈវិនិច្ឆ័យ ក្នុងអំឡុងពេល២០ថ្ងៃបន្ទាប់ពីបង្កើតនូវគណៈវិនិច្ឆ័យទេ គណៈវិនិច្ឆ័យមានលក្ខខណ្ឌស្តង់ដាររបស់ខ្លួនដើម្បីយកមកអនុវត្ត។[47] ប៉ុន្តែប្រសិនបើមានការព្រមព្រៀងគ្នាលើលក្ខខណ្ឌផ្សេង សមាជិកណាក៏ដោយអាចលើកឡើងអំពីចំណុចនោះនៅក្នុងអង្គភាពដោះស្រាយវិវាទផងដែរ។[48]

ការបង្កើតនូវគណៈវិនិច្ឆ័យ គឺជាមុខងារមួយរបស់អង្គភាពដោះស្រាយវិវាទ ហើយវាជាស្ថានភាពមួយក្នុងចំណោម ស្ថានភាព៣ក្នុងអង្គភាពដោះស្រាយវិវាទ ដែលការសម្រេចមិនត្រូវការនូវការសម្រេចជាកុងស៊ីងស៊ុស។ នៅក្នុងការប្រជុំដំបូងរបស់អង្គភាពដោះស្រាយវិវាទ ដែលមានការស្នើ

[45] DSU, 1995, មាត្រា 7 ចំណុច 1។

[46] DSU, 1995, មាត្រា 6 ចំណុច 2។

[47] DSU, 1995, មាត្រា 7 ចំណុច 1។

[48] DSU, 1995, មាត្រា 7 ចំណុច 3។

សុំបង្កើតគណៈវិនិច្ឆ័យ ចុងចម្លើយនៅតែអាចរារាំងនូវការបង្កើតគណៈវិនិច្ឆ័យ ដូចជាករណីនៃប្រព័ន្ធនៃការដោះស្រាយវិវាទក្នុង GATT ដែរ។ ប៉ុន្តែនៅក្នុងការប្រជុំទី២ របស់អង្គភាពដោះស្រាយវិវាទនឹងមានការសម្រេចបង្កើតគណៈវិនិច្ឆ័យ ហើយចុងចម្លើយមិនអាចរារាំងទៀតទេ លើកលែងតែមានការសម្រេចជាកុងស៊ិងស៊ុសនៅក្នុងអង្គភាពដោះស្រាយវិវាទថាមិនបង្កើតនូវគណៈវិនិច្ឆ័យ។[49] កិច្ចប្រជុំទី២នេះ ជាទូទៅត្រូវបានធ្វើឡើងក្នុងរយៈពេលប្រហែល ១ខែ បន្ទាប់ពីកិច្ចប្រជុំទី១ ប៉ុន្តែដើមបណ្តឹងអាចស្នើសុំឲ្យមានការប្រជុំពិសេសនៅក្នុងអង្គភាពដោះស្រាយវិវាទ ក្នុងអំឡុងពេល ១៥ នៃការស្នើសុំប្រជុំនេះ ប្រសិនបើមានការជូនដំណឹងជាមុនយ៉ាងតិច១០ថ្ងៃ មុនការប្រជុំ។

វិធាននៃកុងស៊ិងស៊ុសបដិសេធមានន័យថា ដើមបណ្តឹងទទួលបាននូវការធានាថា សំណើសុំបង្កើតគណៈវិនិច្ឆ័យនឹងបានសម្រេចតាមការចង់បានរបស់ខ្លួន។ លទ្ធភាពតែមួយគត់ដែលអាចរារាំងនូវការបង្កើតគណៈវិនិច្ឆ័យ គឺការសម្រេចជាកុងស៊ិងស៊ុសនៅក្នុងអង្គភាពដោះស្រាយវិវាទថាមិនបង្កើតនូវគណៈវិនិច្ឆ័យ ប៉ុន្តែនេះនឹងមិនកើតឡើងទេ ប្រសិនបើដើមបណ្តឹងគ្មានឆន្ទៈចូលរួមនៅក្នុងកុងស៊ិងស៊ុសនោះទេ។ និយាយម្យ៉ាងទៀត ដរាបណាដើមបណ្តឹង ទោះបីជាម្នាក់ឯងក៏ដោយ ធ្វើការប្រឆាំងនឹងការជំទាស់របស់សមាជិកដទៃទៀត ដោយទទូចឲ្យមានការបង្កើតនូវគណៈវិនិច្ឆ័យ វានឹងមិនអាចទៅរួចទេ ដែលអង្គភាពដោះស្រាយវិវាទធ្វើការសម្រេចជាកុងស៊ិងស៊ុសធ្វើការបដិសេធនូវការបង្កើតគណៈវិនិច្ឆ័យ។ ដូច្នេះគេសឹងតែអាចនិយាយជារួមថា មានការសម្រេចបង្កើតនូវគណៈវិនិច្ឆ័យដោយអង្គភាពដោះស្រាយវិវាទដោយស្វ័យប្រវត្តិ។

## ២.២.២. ការចូលរួមរបស់ភាគីទីបីក្នុងការជំនុំជម្រះនៅគណៈវិនិច្ឆ័យ

ដើមបណ្តឹង និងចុងចម្លើយគឺជាភាគីនៃវិវាទ។ សមាជិកដទៃទៀតអាចមានឱកាសនៅក្នុងស្តាប់ការជំនុំជម្រះរបស់គណៈវិនិច្ឆ័យ និងដាក់ជូនឯកសារជាលាយលក្ខណ៍អក្សរក្នុងនាមជាភាគីទី៣ ទោះបីគេមិនបានចូលរួមនៅក្នុងការប្រឹក្សាក៏ដោយ។ ដើម្បីចូលរួមដំណើរការនៅគណៈវិនិច្ឆ័យ សមាជិកទាំងនេះ ត្រូវតែមានផលប្រយោជន៍សំខាន់ពាក់ព័ន្ធនឹងបញ្ហាដែលដាក់ជូនគណៈវិនិច្ឆ័យធ្វើការជំនុំជម្រះ ហើយត្រូវធ្វើការបង្ហាញនូវផលប្រយោជន៍របស់ពួកគេនោះទៅកាន់អង្គភាពដោះស្រាយវិវាទ។

នៅក្នុងការអនុវត្ត អង្គភាពដោះស្រាយវិវាទដាក់កំណត់រយៈពេល១០ថ្ងៃគិតចាប់ពីថ្ងៃបង្កើតគណៈវិនិច្ឆ័យ ថាជាកាលបរិច្ឆេទផុតកំណត់សម្រាប់សមាជិកដទៃទៀត ធានានូវសិទ្ធិរបស់ពួកគេ

[49] DSU, 1995, មាត្រា 6 ចំណុច 1។

ក្នុងការចូលរួមជាភាគីទីបី។ នៅក្នុងកិច្ចប្រជុំបង្កើតនូវគណៈវិនិច្ឆ័យ ភាគីអាចស្នើសុំធ្វើជាភាគីទីបីដោយផ្ទាល់មាត់បាន។ ប៉ុន្តែនៅក្នុងអំឡុងពេល១០ថ្ងៃបន្ទាប់ពីបង្កើតគណៈវិនិច្ឆ័យ សមាជិកអង្គការពាណិជ្ជកម្មពិភពលោកដែលមានបំណងចង់ចូលរួមជាភាគីទីបី ត្រូវតែធ្វើការជូនដំណឹងទៅកាន់អង្គភាពដោះស្រាយវិវាទជាលាយលក្ខណ៍អក្សរ តាមរយៈលេខាធិការដ្ឋានអង្គការ WTO។

វាមាននូវភាពខុសគ្នារវាងផលប្រយោជន៍សំខាន់ផ្នែកពាណិជ្ជកម្ម ដែលជាលក្ខខណ្ឌសម្រាប់ការចូលរួមជាភាគីទីបីនៅក្នុងការប្រឹក្សា និងផលប្រយោជន៍សំខាន់ដែលជាលក្ខខណ្ឌនៅក្នុងការចូលរួមជាភាគីទីបីនៅក្នុងគណៈវិនិច្ឆ័យ។ អ្វីដែលគួរឲ្យកត់សម្គាល់បំផុតនោះគឺថា ដើម្បីអាចចូលរួមនៅក្នុងការប្រឹក្សាបានលុះត្រាតែមានការយល់ព្រមពីចុងចម្លើយ ហើយក្នុងករណីដែលគ្មានការយល់ព្រមនោះ នឹងមិនមានការប្តឹងឧបាស្រ័យដើម្បីបង្ខំអោយមានការអនុញ្ញាតឲ្យចូលរួមពីភាគីទីបីឡើយ។ ផ្ទុយទៅវិញ នៅក្នុងការអនុវត្តចំពោះការចូលរួមជាភាគីទីបីក្នុងដំណើរការជម្រះក្តីរបស់គណៈវិនិច្ឆ័យ សមាជិកណាក៏ដោយដែលផ្អែកលើផលប្រយោជន៍នៃប្រព័ន្ធដោះស្រាយវិវាទអាចចូលរួមក្នុងនីតិវិធីរបស់គណៈវិនិច្ឆ័យក្នុងនាមជាភាគីទីបីបាន ដោយមិនបាច់មានការត្រួតពិនិត្យថាតើផលប្រយោជន៍សំខាន់នោះមានឬទេឡើយ។

ភាគីទីបីទទួលនូវសំណុំលិខិត ដែលភាគីវិវាទដាក់ចូលជាលើកដំបូងទៅកាន់គណៈវិនិច្ឆ័យ និងធ្វើការបង្ហាញនូវការយល់ឃើញជារួមរបស់ខ្លួន ទៅកាន់គណៈវិនិច្ឆ័យនៅក្នុងកិច្ចប្រជុំធំដំបូង។ ភាគីទីបីគ្មានសិទ្ធិអ្វីផ្សេងក្រៅពីនេះទេ ទោះបីជាជាញឹកញាប់គណៈវិនិច្ឆ័យធ្វើការពង្រីកនូវសិទ្ធិរបស់ភាគីទីបីនៅក្នុងការចូលរួមនៅក្នុងករណីនៃរឿងក្តីដាច់ដោយឡែកមួយចំនួនក៏ដោយ។

## ២.២.៣. នីតិវិធីក្នុងគណៈវិនិច្ឆ័យ

នៅពេលដែលគណៈវិនិច្ឆ័យត្រូវបានបង្កើត និងរៀបចំសមាសភាពរួចហើយ គណៈវិនិច្ឆ័យអាចចាប់ផ្តើមការងាររបស់ខ្លួន ដែលក្នុងនោះការងារដំបូងរបស់គណៈវិនិច្ឆ័យ គឺរៀបចំនូវតារាងប្រតិទិនការងាររបស់ខ្លួន។ នីតិវិធីការងារជាបឋមរបស់គណៈវិនិច្ឆ័យ មានកំណត់នៅក្នុងមាត្រា ១២ និងឧបសម្ព័ន្ធ ៣ នៃ DSU ប៉ុន្តែក៏ទុកលទ្ធភាពឲ្យមានការបត់បែនក្នុងកម្រិតជាក់លាក់មួយដែរ។ គណៈវិនិច្ឆ័យអាចធ្វើតាមនីតិវិធីផ្សេងបន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយនឹងភាគីវិវាទ។ នៅក្នុងការអនុវត្ត ជាទូទៅគណៈវិនិច្ឆ័យធ្វើទៅតាមនីតិវិធីដូចមាន កំណត់ក្នុងឧបសម្ព័ន្ធ៣នៃDSU ប៉ុន្តែជាញឹកញាប់ធ្វើការអនុម័តនូវវិធានបន្ថែមទៀតដែលវិវាទជាក់លាក់ណាមួយត្រូវការ ហើយដែលជាធម្មតាកើតមានបន្ទាប់ពីការពិគ្រោះយោបល់ និងការព្រមព្រៀងជាមួយនឹងភាគីវិវាទ នៅក្នុងកិច្ចប្រជុំស្តីពីការរៀបចំគណៈវិនិច្ឆ័យជាមួយភាគី។ ប្រសិនបើការណ៍នេះមិនអាចទៅរួចទេ គណៈវិនិច្ឆ័យធ្វើ

ការសម្រេចចិត្តលើនីតិវិធី ហើយធ្វើការជូនដំណឹងទៅកាន់ភាគី។ ដូច្នេះ ប្រតិទិនការងារត្រូវបាន អនុម័តឡើងដោយផ្អែកលើមូលដ្ឋាននៃតារាងពេលវេលាដែលស្នើឡើងនៅក្នុងឧបសម្ព័ន្ធ៣នៃ DSU ដែលធ្វើការកំណត់នូវកាលបរិច្ឆេទ និងការផុតកំណត់នូវដំណាក់កាលសំខាន់ៗនៃនីតិវិធីក្នុងគណៈ វិនិច្ឆ័យ ឧទាហរណ៍ កាលបរិច្ឆេទនៃការបំពេញសំណុំឯកសារ ការទាញហេតុផលផ្ទាល់មាត់ និង ការចេញសេចក្តីសម្រេចជាដើម។

### ២.២.៣.១. ការដាក់សំណុំឯកសារ និងការទាញហេតុផលផ្ទាល់មាត់[50]

#### ក. ការដាក់សំណុំឯកសារលើកទីមួយ

ស្របតាមប្រតិទិនការងាររបស់គណៈវិនិច្ឆ័យដំណើរការការងាររបស់គណៈវិនិច្ឆ័យចាប់ផ្តើម ដោយការផ្លាស់ប្តូរនូវសំណុំឯកសាររវាងភាគីវិវាទ លើបញ្ហាបឋមដែលត្រូវបានលើកឡើងដោយចុង ចម្លើយ។ ឧទាហរណ៍ ចុងចម្លើយអាចធ្វើការតវ៉ាទៅនឹងភាពគ្រប់គ្រាន់ និងភាពច្បាស់លាស់នៃ សំណើបង្កើតនូវគណៈវិនិច្ឆ័យរបស់ដើមបណ្តឹង។ នៅក្នុងករណីដូចនេះ គណៈវិនិច្ឆ័យអាចដាក់ ចេញនូវវិធានបឋម ដើម្បីដោះស្រាយលើបញ្ហានេះ។

នៅពេលគ្មានបញ្ហាដំបូងចោទឡើងដូចបានលើកឡើងខាងលើទេ ភាគីអាចចាប់ផ្តើមដោយ ការផ្លាស់ប្តូរគ្នាទៅវិញទៅមកនូវសំណុំឯកសារជាលាយលក្ខណ៍អក្សរដំបូងរបស់ខ្លួន។ ក្នុងនោះ ដើមចោទជាធម្មតា គឺជាអ្នកដាក់នូវសំណុំឯកសារមុន បន្ទាប់មកចុងចម្លើយ គឺជាអ្នកដាក់សំណុំ ឯកសារបន្ទាប់ ដោយធ្វើការឆ្លើយតបទៅនឹងដើមបណ្តឹង។[51] ចំណែកភាគីទីបី ជាទូទៅដាក់នូវ សំណុំឯកសាររបស់ខ្លួនបន្ទាប់ពីភាគីដើមចោទ និងចុងចម្លើយ ដាក់សំណុំឯកសាររួចរាល់ ហើយភា គីទីបីនេះមានសិទ្ធិនៅក្នុងការទទួលបាននូវសំណុំឯកសារដំបូងរបស់ភាគីវិវាទ។ ភាគីទីបីនេះ ជា ធម្មតាតែងតែឈរនៅខាងភាគីណាមួយ អាចជាខាងដើមបណ្តឹង ឬចុងចម្លើយ។

DSU បានធ្វើការកំណត់ថា លេខាធិការដ្ឋានជាអ្នកទទួលនូវសំណុំឯកសារទាំងនោះ ហើយ ធ្វើការបញ្ជូនបន្តទៅកាន់ភាគីដទៃទៀត ឬភាគីនៃវិវាទ។ ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែង ភាគីធ្វើ ការដាក់ជូនសំណុំឯកសារទាំងនេះនឹងការិយាល័យចុះបញ្ជីរបស់លេខាធិការដ្ឋាន Secretariat DS registry តែនៅក្នុងចំនួនដែលបានស្នើឡើងដើម្បីផ្តល់ជូនគណៈវិនិច្ឆ័យប៉ុណ្ណោះ ចំណែកឯភាគី និង ភាគីទីបី អាចទទួលបាននូវច្បាប់ចតចម្លងនៃសំណុំឯកសារទាំងនោះដោយផ្ទាល់ពីភាគីដទៃទៀត

[50] *Chapter 3 Settling dispute* [ជំពូកទី 3: ការដោះស្រាយវិវាទ], 57, https://www.wto.org/english/thewto_e/whatis_e/tif_e/utw_chap3_e.pdf (ចូលអាន និងទាញយក ថ្ងៃទី15 ឧសភា 2015)។

[51] DSU, 1995, មាត្រា 12 ចំណុច 6។

និងភាគីទីបីតាមរយៈប្រអប់សំបុត្ររបស់ប្រតិភូពួកគេ នៅអាគារអង្គការពាណិជ្ជកម្មពិភពលោកនៅទីក្រុងហ្សឺណែវ។

សំណុំឯកសាររបស់ភាគី គឺជាឯកសារដែលមានទំហំធំដែលពេលខ្លះមានរាប់សិបទំព័រ អមជាមួយនឹងអត្ថបទពន្យល់បកស្រាយបន្ថែមទៀត។ ភាគីធ្វើការបញ្ជាក់អំពីអង្គហេតុនៃរឿងក្តី និងសំអាងផ្លូវច្បាប់របស់ពួកគេ ដោយជាញឹកញាប់ពួកគេពឹងផ្អែកជាសំខាន់លើយុត្តិសាស្ត្ររបស់គណៈវិនិច្ឆ័យ និងអង្គភាពឧទ្ធរណ៍ពីមុន។ សំណុំឯកសាររបស់ដើមបណ្តឹងជាធម្មតាមានគោលបំណងទាមទារឲ្យមានការចង្អុលបង្ហាញភស្តុតាងឲ្យបានច្បាស់លាស់ ចំពោះការអះអាងអំពីមោឃៈភាពនៃការបំពាន ឬការអះអាងអំពីការមិនបំពានលើវិធានពាណិជ្ជកម្ម។ ចុងចម្លើយធ្វើការបដិសេធទៅនឹងសំអាងហេតុ និងសំអាងច្បាប់ដែលលើកឡើងដោយដើមបណ្តឹង។ ផ្ទុយពីភាគីវិវាទ សំណុំឯកសាររបស់ភាគីទីបី ជាធម្មតាខ្លីជាងត្រឹមតែពីរ ឬបីទំព័រ ដោយគ្រាន់តែធ្វើការផ្តល់យោបល់លើការអះអាងអង្គហេតុ និងអង្គច្បាប់របស់ភាគីប៉ុណ្ណោះ។

សំណុំឯកសារទាំងអស់នេះ ត្រូវបានរក្សាទុកជាការសម្ងាត់[52] ប៉ុន្តែនៅក្នុងរបាយការណ៍របស់គណៈវិនិច្ឆ័យដែលត្រូវបានផ្សព្វផ្សាយទៅកាន់សមាជិក និងសាធារណជន មានឆ្លុះបញ្ចាំងនិងសង្ខេបនូវការអះអាងអង្គហេតុ និងអង្គច្បាប់របស់ភាគីនៅចំពោះមុខគណៈវិនិច្ឆ័យ។ បន្ថែមលើនេះទៀត ភាគីមានសេរីភាពនៅក្នុងការដាក់បង្ហាញនូវសំណុំឯកសាររបស់គេដល់សាធារណៈជន[53] សមាជិកជាច្រើនបានចុះផ្សាយនូវសំណុំឯកសាររបស់ខ្លួននៅក្នុងវែបសាយរបស់ខ្លួនភ្លាមៗ បន្ទាប់ពីបានបំពេញនូវសំណុំឯកសារ និងបន្ទាប់ពីការទាញហេតុផលផ្ទាល់មាត់ ឬនៅពេលដែលបិទបញ្ចប់នូវនីតិវិធី។

ក្នុងការកំណត់ពីនីតិវិធីធ្វើការងាររបស់ខ្លួនសម្រាប់វិវាទជាក់លាក់ណាមួយ គណៈវិនិច្ឆ័យពេលខ្លះអាចស្នើភាគីវិវាទ និងភាគីទីបី ដាក់ជូននូវសេចក្តីសង្ខេបអំពីសំណុំឯកសាររបស់ខ្លួន។ បន្ថែមលើនេះទៀត សេចក្តីសង្ខេបនេះនឹងត្រូវបានប្រើប្រាស់នៅក្នុងការព្រាងនូវសេចក្តីពណ៌នានៃរបាយការណ៍របស់គណៈវិនិច្ឆ័យផងដែរ។

### ខ. ការទាញហេតុផលផ្ទាល់មាត់លើកទីមួយ

[52] DSU, 1995, មាត្រា 18 ចំណុច 2 និង Appendix 3 of DSU: working procedure [ឧបសម្ព័ន្ធ ៣ នៃ DSU : នីតិវិធីការងារ] (ពីពេលនេះទៅហៅថា ឧបសម្ព័ន្ធ 3 នៃ DSU : នីតិវិធីការងារ), 1995, កថាខណ្ឌ ៣។

[53] ដូច 52។

បន្ទាប់ពីផ្លាស់ប្តូរនូវសំណុំឯកសារជាលាយលក្ខណ៍អក្សរដំបូងរបស់ភាគីវិវាទ គណៈវិនិច្ឆ័យចាប់ផ្តើមនីតិវិធីនៃការទាញហេតុផលផ្ទាល់មាត់ ដែលត្រូវបានហៅថាជា ការប្រជុំធំដំបូង។ ដូចជាការប្រជុំទាំងអស់ដែរ ការប្រជុំនេះធ្វើឡើងនៅទីស្នាក់ការកណ្តាលអង្គការពាណិជ្ជកម្មពិភពលោកនៅទីក្រុងហ្សឺណែវ ដែលមានលក្ខណៈស្រដៀងគ្នា ទៅនឹងការទាញហេតុផលផ្ទាល់មាត់ក្នុងនីតិវិធីតុលាការដែរ ប៉ុន្តែទីកន្លែងមានលក្ខណៈមិនផ្លូវការដូចនៅតុលាការនោះទេ។ ផ្ទុយទៅនឹងការអនុវត្តនៅក្នុងយុត្តាធិការក្នុងស្រុកជាច្រើន ការទាញហេតុផលផ្ទាល់មាត់នេះមិនធ្វើឡើងជាសាធារណៈនោះទេ ពោលគឺមានតែភាគីវិវាទ ភាគីទីបី គណៈវិនិច្ឆ័យ បុគ្គលិកលេខាធិការដ្ឋានដែលជួយគណៈវិនិច្ឆ័យ និងអ្នកបកប្រែប៉ុណ្ណោះដែលមានសិទ្ធិចូលរួមនៅក្នុងការប្រជុំនេះ។

នៅក្នុងការប្រជុំដែលមានការថតនូវសម្លេងនេះ ភាគីធ្វើការបញ្ចេញមតិយោបល់របស់ខ្លួនដោយផ្ទាល់មាត់ ដោយឈរលើមូលដ្ឋាននៃសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍ដែលបានរៀបចំទុកនិងដែលបានចែកចាយជូនទៅកាន់គណៈវិនិច្ឆ័យ និងភាគីដទៃទៀតរួចហើយ។[54] បន្ទាប់ពីស្តាប់ដើមចោទ និងចុងចម្លើយរួចហើយ គណៈវិនិច្ឆ័យផ្តល់ឱកាសដល់ភាគីទីបីដើម្បីធ្វើការបញ្ចេញយោបល់របស់ខ្លួនដោយផ្ទាល់មាត់នៅក្នុងពេលពិសេសមួយសម្រាប់ភាគីទីបី។

បន្ទាប់ពីសេចក្តីថ្លែងការណ៍ផ្ទាល់មាត់ ភាគី និងភាគីទីបីត្រូវបានអញ្ជើញឲ្យឆ្លើយតបទៅនឹងសំណួររបស់គណៈវិនិច្ឆ័យ និងសំណួររបស់ភាគីដទៃទៀតដើម្បីធ្វើការបញ្ជាក់ឲ្យច្បាស់អំពីបញ្ហាអង្គហេតុ និងអង្គច្បាប់។[55] បន្ទាប់ពីការសន្និដ្ឋានបិទបញ្ចប់ការទាញហេតុផលផ្ទាល់មាត់លើកទីមួយនេះ ភាគីត្រូវធ្វើការឆ្លើយតបជាលាយ លក្ខណ៍អក្សរចំពោះសំណួររបស់គណៈវិនិច្ឆ័យ និងសំណួររបស់ភាគីដទៃទៀត ក្នុងអំឡុងពេលដែលកំណត់ដោយគណៈវិនិច្ឆ័យ បើទោះបីជាសំណួរទាំងនោះត្រូវបានពិភាក្សាហើយនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ក៏ដោយ។

**គ. ការដាក់សំណុំឯកសារលើកទីពីរ**

ជាធម្មតា ៤ សប្តាហ៍បន្ទាប់ពីការទាញហេតុផលផ្ទាល់មាត់លើកទីមួយនៅក្នុងគណៈវិនិច្ឆ័យ ភាគីធ្វើការផ្លាស់ប្តូរនូវសំណុំឯកសារដើម្បីធ្វើការឆ្លើយតប និងជំទាស់អំពីការលើកឡើងរបស់ភាគីម្ខាងៗ ដែលហៅថា ការដាក់សំណុំឯកសារលើកទី២ ។ នៅក្នុងការដាក់នូវសំណុំឯកសារទាំងនេះ

[54] ឧបសម្ព័ន្ធ 3 នៃ DSU : នីតិវិធីការងារ, 1995, កថាខណ្ឌ 9។

[55] ឧបសម្ព័ន្ធ 3 នៃ DSU : នីតិវិធីការងារ, 1995, កថាខណ្ឌ 8។

ភាគីវិវាទធ្វើការឆ្លើយតបចំពោះការដាក់សំណុំឯកសារលើកទី១ និងសេចក្តីថ្លែងការណ៍ផ្ទាល់មាត់ នៅក្នុងការទាញហេតុផលផ្ទាល់មាត់របស់គ្នាទៅវិញទៅមក ។

**ឃ. ការទាញហេតុផលផ្ទាល់មាត់លើកទីពីរ**

បន្ទាប់ពីភាគីធ្វើការដាក់សំណុំឯកសារជាលើកទីពីរហើយ គណៈវិនិច្ឆ័យចាប់ផ្តើមនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ជាលើកទីពីរជាមួយនឹងភាគី។ ជាថ្មីម្តងទៀត ភាគីធ្វើការបង្ហាញនូវសំអាងហេតុ និងសំអាងច្បាប់ដោយផ្ទាល់មាត់ នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់លើកទី២នេះ ព្រមទាំងធ្វើការឆ្លើយតបទៅនឹងសំណួរបន្ថែមរបស់គណៈវិនិច្ឆ័យ និងភាគីដទៃទៀត ដំបូងឆ្លើយតបដោយផ្ទាល់មាត់បន្ទាប់មកជាលាយលក្ខណ៍អក្សរ។ គួរបញ្ជាក់ថា គណៈវិនិច្ឆ័យមានអំណាចរៀបចំនូវកិច្ចប្រជុំទីបី និងកិច្ចប្រជុំជាច្រើនទៀតក្នុងការដោះស្រាយបញ្ហាវិវាទមួយ។ ពេលខ្លះគណៈវិនិច្ឆ័យរៀបចំនូវកិច្ចប្រជុំទីបី ដោយមានការចូលរួមស្តាប់រឿងក្តីដោយអ្នកជំនាញ។

ក្នុងករណីមានការតវ៉ាច្រើនទៅលើបញ្ហាតែមួយ ហើយដែលមានការបង្កើតគណៈវិនិច្ឆ័យតែមួយ សំណុំឯកសារជាលាយលក្ខណ៍របស់ដើមបណ្តឹងនីមួយៗត្រូវតែអាចជូនដល់ដើមបណ្តឹងផ្សេងទៀត ហើយដើមបណ្តឹងនីមួយៗមានសិទ្ធិមានវត្តមាន នៅពេលដែលដើមបណ្តឹងផ្សេងទៀតធ្វើសេចក្តីថ្លែងការណ៍របស់ខ្លួននៅចំពោះមុខគណៈវិនិច្ឆ័យ។

**២.២.៣.២. ការពិភាក្សារបស់គណៈវិនិច្ឆ័យ**

បន្ទាប់ពីការទាញហេតុផលផ្ទាល់មាត់ត្រូវបានបិទបញ្ចប់ គណៈវិនិច្ឆ័យនឹងឈានដល់ការពិភាក្សាផ្ទៃក្នុង ដើម្បីត្រួតពិនិត្យមើលបញ្ហា និងឈានទៅធ្វើសេចក្តីសន្និដ្ឋានសម្រេចអំពីលទ្ធផលនៃវិវាទ និងមូលហេតុដែលគាំទ្រដល់លទ្ធផល។ គណៈវិនិច្ឆ័យត្រូវបានប្រគល់សិទ្ធិក្នុងការពិនិត្យមើលនូវសំណួរអង្គហេតុដែលពាក់ព័ន្ធ និងបញ្ហាអង្គច្បាប់ដើម្បីធ្វើអោយមានភាពស្របគ្នារវាងវិធានដែលត្រូវបានតវ៉ា និងកិច្ចព្រមព្រៀងពាក់ព័ន្ធដែលដើមបណ្តឹងយកធ្វើជាមូលដ្ឋានធ្វើការតវ៉ា។[56] ជាធម្មតា គណៈវិនិច្ឆ័យធ្វើការត្រួតពិនិត្យអំពីភាពត្រឹមត្រូវនៃការអះអាងរបស់ដើមបណ្តឹងដែលថា ចុងចម្លើយធ្វើសកម្មភាពមិនស្របទៅនឹងកាតព្វកិច្ចរបស់ខ្លួននៅក្នុងអង្គការ WTO។ សិទ្ធិដែលគេប្រគល់ឲ្យគណៈវិនិច្ឆ័យ គឺធ្វើការអនុវត្តច្បាប់ដែលមានស្រាប់នៅក្នុងអង្គការ មិនមែនបង្កើតច្បាប់

[56] DSU, 1995, មាត្រា 11។

នោះទេ។ គណៈវិនិច្ឆ័យ និងអង្គភាពឧទ្ធរណ៍មិនត្រូវបន្ថែម ឬបន្ថយនូវសិទ្ធិ និងកាតព្វកិច្ចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងដែលគ្រប់គ្រងលើកិច្ចការពាណិជ្ជកម្មនោះទេ។[57]

ការពិភាក្សារបស់គណៈវិនិច្ឆ័យត្រូវបានរក្សានូវការសម្ងាត់ ហើយសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យក៏ត្រូវបានព្រាងឡើងដោយអវត្តមានរបស់ភាគីផងដែរ។ ជាមួយគ្នានេះដែរ DSU ក៏ហាមឃាត់មិនឲ្យការទំនាក់ទំនងដោយអវត្តមានរបស់ភាគីម្ខាងទៀត (ex parte communications) ជាមួយនឹងគណៈវិនិច្ឆ័យលើបញ្ហាដែលកំពុងស្ថិតនៅក្នុងការពិចារណានោះទេ មានន័យថា គណៈវិនិច្ឆ័យគ្មានសិទ្ធិនៅក្នុងការទាក់ទងជាមួយនឹងភាគីជាលក្ខណៈបុគ្គលទេ លើកលែងតែមានវត្តមានរបស់ភាគីដទៃទៀត ឬភាគីម្ខាងទៀតនៃវិវាទ។[58]

### ២.២.៣.៣. ការរៀបចំទម្រង់សេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យ

របាយការណ៍របស់គណៈវិនិច្ឆ័យត្រូវបានបែងចែកជាពីរផ្នែកធំៗ គឺ ផ្នែកអត្ថាធិប្បាយ និងផ្នែកសេចក្តីសម្រេច។ ផ្នែកអត្ថាធិប្បាយ ជាទូទៅគឺជាផ្នែកវែង ដែលមាននូវសេចក្តីផ្តើម ចំណុចអង្គហេតុ ការទាមទាររបស់ភាគី (ពេលខ្លះហៅថា ខ្លឹមសារសេចក្តីសម្រេចដែលភាគីស្នើសុំឲ្យគណៈវិនិច្ឆ័យចេញ) ហើយអ្វីដែលសំខាន់នោះគឺ សេចក្តីសង្ខេបនៃសំអាងហេតុ និងសំអាងច្បាប់របស់ភាគី និងភាគីទីបី។

គណៈវិនិច្ឆ័យដំបូងដាក់ចេញនូវពង្រាងផ្នែកសេចក្តីអត្ថាធិប្បាយ ដើម្បីឲ្យភាគីមានមតិយោបល់ជាលាយលក្ខណ៍អក្សរទៅលើផ្នែកនេះ។[59] ស្របតាមប្រតិទិនការងាររបស់គណៈវិនិច្ឆ័យដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធ៣នៃDSU ភាគីត្រូវបានអញ្ជើញឲ្យមានមតិយោបល់លើពង្រាងផ្នែកសេចក្តីអត្ថាធិប្បាយនេះនៅក្នុងអំឡុងពេល២សប្តាហ៍។ នេះជាការផ្តល់ឲ្យភាគីនូវឱកាសដើម្បីធានាថា អំណះអំណាងសំខាន់ៗរបស់គេ ត្រូវបានបង្ហាញនៅក្នុងផ្នែកសេចក្តីអត្ថាធិប្បាយ និងដើម្បីធ្វើការកែតម្រូវនូវចំណុចខុសឆ្គងឲ្យមានភាពច្បាស់លាស់ត្រឹមត្រូវឡើងវិញ។

### ២.២.៣.៤. សេចក្តីសម្រេច សេចក្តីសន្និដ្ឋាន អនុសាសន៍ និងការណែនាំលើការអនុវត្ត

នៅក្នុងសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យ ជាទូទៅមានផ្នែកសេចក្តីសម្រេច ដែលជាផ្នែកដាក់ចេញនូវមូលហេតុគាំទ្រនូវសេចក្តីសន្និដ្ឋានចុងក្រោយរបស់គណៈវិនិច្ឆ័យថាតើ ការទាមទាររបស់ដើមបណ្តឹងអាចទទួលបាន ឬក៏ត្រូវលើកចោល។ មូលហេតុនេះ គឺជាការពិភាក្សាគ្រប់ជ្រុង

[57] DSU, 1995, មាត្រា 19 ចំណុច 2។
[58] DSU, 1995, មាត្រា 18 ចំណុច 1។
[59] DSU, 1995, មាត្រា 15 ចំណុច 1។

ជ្រោយលើច្បាប់ដែលត្រូវយកមកអនុវត្តក្នុងអង្គហេតុបង្កើតឡើងដោយគណៈវិនិច្ឆ័យ ដោយឈរលើមូលដ្ឋាននៃភស្តុតាងចំពោះមុខ និងលើអំណះអំណាងដែលលើកឡើងដោយភាគី។

នៅពេលដែលមានការតវ៉ាចំពោះការរំលោភបំពាន គណៈវិនិច្ឆ័យត្រូវសម្រេចថា ពិតជាមានការរំលោភបំពាន លើបទបញ្ញត្តិនៃកិច្ចព្រមព្រៀងមួយ ឬច្រើនដែលគ្រប់គ្រងលើកិច្ចការពាណិជ្ជកម្មមែនឬទេ។ ចំណែកករណីនៃការតវ៉ាចំពោះការមិនរំលោភបំពានវិញ គណៈវិនិច្ឆ័យត្រូវសម្រេចថា តើផលប្រយោជន៍របស់ដើមបណ្តឹងនៅក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្ម ពិតជាមានការបាត់បង់ដោយសារតែលទ្ធផលនៃវិធាននោះឬទេ បើទោះបីជាវិធាននោះមិនមានការរំលោភបំពានក៏ដោយ ប៉ុន្តែនេះជាករណីដែលកម្រនឹងកើតមានខ្លាំងណាស់។ សមាជិកគណៈវិនិច្ឆ័យម្នាក់ៗមានសិទ្ធិនៅក្នុងការបញ្ចេញមតិយោបល់ក្នុងសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យ។

សេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យភាគច្រើនមានលក្ខណៈលំអិត និងជាក់លាក់ ហើយជាញឹកញាប់ជាការពិភាក្សាច្បាប់យ៉ាងវែងថាតើ ចុងចម្លើយពិតជាមានធ្វើសកម្មភាពមិនស្របទៅនឹងកិច្ចព្រមព្រៀងពាក់ព័ន្ធនឹងកិច្ចការពាណិជ្ជកម្មដែលលើកឡើងដោយដើមបណ្តឹងឬទេ។ ដោយឡែកចំពោះការដោះស្រាយវិវាទក្រោម GATT 1947 សេចក្តីសន្និដ្ឋានរបស់គណៈវិនិច្ឆ័យ មិនមានភាពជាក់លាក់ និងបង្ហាញនូវលទ្ធផលផ្នែកច្បាប់ច្បាស់លាស់ដូចជាករណីរឿងក្តីបច្ចុប្បន្ននេះទេ។ ដូច្នេះហើយមានការលើកឡើងថា ប្រព័ន្ធដោះស្រាយវិវាទនេះត្រូវបានវិវត្តន៍ជាច្រើនឆ្នាំ ពីលក្ខណៈវេទិកាការទូត មកជាលក្ខណៈប្រព័ន្ធយុត្តាធិការច្រើនឡើង។

នៅពេលដែលគណៈវិនិច្ឆ័យធ្វើការសន្និដ្ឋានបញ្ចប់ថា វិធានដែលមានការតវ៉ានោះ ពិតជាមិនស្របទៅនឹងកិច្ចព្រមព្រៀងពាក់ព័ន្ធនឹងកិច្ចការពាណិជ្ជកម្មនោះ គណៈវិនិច្ឆ័យក៏ដាក់ចេញនូវអនុសាសន៍ ដើម្បីតម្រូវឲ្យចុងចម្លើយធ្វើអោយវិធានដែលមានការតវ៉ានោះវិលមកស្របទៅនឹងច្បាប់របស់អង្គការពាណិជ្ជកម្មពិភពលោកវិញ។[60] នៅក្នុងការអនុវត្តអនុសាសន៍ដែលចេញដោយគណៈវិនិច្ឆ័យនេះ គឺដូចជាអនុសាសន៍ដែលចេញដោយអង្គភាពដោះស្រាយវិវាទដែរ ដើម្បីស្នើទៅកាន់សមាជិកដែលពាក់ព័ន្ធ ធ្វើការកែប្រែនូវវិធានរបស់ខ្លួនឲ្យមកស្របតាមកិច្ចព្រមព្រៀងពាក់ព័ន្ធនឹងកិច្ចការពាណិជ្ជកម្ម។ ជាមួយគ្នានេះដែរ គណៈវិនិច្ឆ័យអាចណែនាំរបៀបអនុវត្តនូវអនុសាសន៍ទាំងនោះដល់ភាគីដែលពាក់ព័ន្ធផងដែរ។[61] ទោះបីជាយ៉ាងណាក៏ដោយ គណៈវិនិច្ឆ័យមិនមានកាតព្វកិច្ចក្នុងការណែនាំនូវរបៀបអនុវត្តទាំងនោះទេ ទោះបីមានការស្នើសុំពីដើមបណ្តឹងក៏ដោយ។

[60] DSU, 1995, មាត្រា 19 ចំណុច 1។

[61] DSU, 1995, មាត្រា 19 ចំណុច 1។

បើគណៈវិនិច្ឆ័យប្រើប្រាស់សិទ្ធិរបស់ខ្លួនក្នុងការណែនាំនូវរបៀបអនុវត្តអនុសាសន៍នោះ ការណែនាំនោះមិនមានលក្ខណៈចាប់បង្ខំលើភាគីចុងចម្លើយឡើយ។ ភាគីចុងចម្លើយមានសេរីភាពក្នុងការជ្រើសរើសនូវជម្រើសផ្សេងៗដែលមានស្រាប់ ដើម្បីអនុវត្តតាមអនុសាសន៍។ អ្វីដែលចុងចម្លើយមានកាតព្វកិច្ចត្រូវធ្វើគឺធ្វើឲ្យវិធានរបស់ខ្លួនស្របនឹងច្បាប់របស់អង្គការពាណិជ្ជកម្មពិភពលោក។

ចំពោះការតវ៉ាចំពោះវិធានដែលគ្មានការរំលោភបំពាន (Non-violation complaint) វិញ ប្រសិនបើការតវ៉ានេះទទួលបានជោគជ័យ ចុងចម្លើយគ្មានកាតព្វកិច្ចក្នុងការដកនូវវិធានដែលត្រូវបានរកឃើញថា មានការប៉ះពាល់ដល់ផលប្រយោជន៍ ឬជំទាស់នឹងកម្មវត្ថុនៃកិច្ចព្រមព្រៀងពាក់ព័ន្ធនឹងកិច្ចការពាណិជ្ជកម្មដែលពាក់ព័ន្ធឡើយ។ នៅក្នុងករណីនេះ គណៈវិនិច្ឆ័យផ្តល់ជាអនុសាសន៍អោយភាគីពាក់ព័ន្ធធ្វើការសម្របសម្រួលដើម្បីអោយមានការពេញចិត្តសងខាង។ ទម្រង់នៃការសម្របសម្រួលអាចជា ការដែលចុងចម្លើយប៉ះប៉ូវដល់ដើមបណ្តឹងដោយផ្តល់នូវជម្រើសឱកាសពាណិជ្ជកម្មដើម្បីប៉ះប៉ូវនូវផលប្រយោជន៍ដែលត្រូវរងនូវការប៉ះពាល់។

### ២.២.៣.៥. **ការត្រួតពិនិត្យអន្តរកាល** Interim Review

គណៈវិនិច្ឆ័យចេញសេចក្តីសម្រេចមួយទៅកាន់ភាគីក្នុងទម្រង់បណ្តោះអាសន្ន ឬអន្តរកាល និងក្នុងទម្រង់ជាឯកសារសម្ងាត់ដែលមាននូវចំណុចខាងលើទាំងអស់ ក្នុងពេល២ទៅ៤សប្តាហ៍បន្ទាប់ពីទទួលបានមតិរបស់ភាគីលើផ្នែកសេចក្តីអធិប្បាយ។ សេចក្តីសម្រេចអន្តរកាលនេះមាននូវផ្នែកសេចក្តីអធិប្បាយបានពិនិត្យឡើងវិញរួច សេចក្តីសម្រេច សេចក្តីសន្និដ្ឋាន និងអនុសាសន៍ និងក្នុងករណីខ្លះមានការណែនាំនូវរបៀបអនុវត្តអនុសាសន៍ផងដែរ ។ ដូច្នេះវាប្រៀបដូចជាសេចក្តីសម្រេចពេញលេញផងដែរ ទោះបីវាមិនទាន់ជាសេចក្តីសម្រេចចុងក្រោយក៏ដោយ ដូច្នេះហើយវាមិនងាយទេដែលភាគីអាចស្នើសុំគណៈវិនិច្ឆ័យ ឲ្យបដិសេធនូវសេចក្តីសម្រេចអន្តរកាលរបស់ខ្លួន។ ជាថ្មីម្តងទៀត ភាគីមានសិទ្ធិក្នុងការបញ្ចេញមតិយោបល់ ស្នើសុំឲ្យមានការប្រជុំគណៈវិនិច្ឆ័យបន្ថែមទៀត ដើម្បីធ្វើការជជែកដេញដោលនូវបញ្ហាដែលលេចឡើងនូវក្នុងសេចក្តីសម្រេចអន្តរកាលនោះដែលនេះជាដំណាក់កាលនៃការត្រួតពិនិត្យអន្តរកាល។ ការត្រួតពិនិត្យអន្តរកាលនេះត្រូវបានបង្កើតដើម្បីធ្វើការពិចារណាឡើងវិញនូវចំណុចសំខាន់ៗនៃសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យ។ ភាគីអាចស្នើឲ្យគណៈវិនិច្ឆ័យ ធ្វើការពិនិត្យឡើងវិញនូវចំណុចសំខាន់ៗក្នុងសេចក្តីសម្រេចអន្តរកាលនោះ។ អំឡុងពេលនៃការពិនិត្យឡើងវិញនេះមិនត្រូវលើស២សប្តាហ៍ឡើយ។ គួរបញ្ជាក់ថា ការត្រួតពិនិត្យអន្តរកាល គឺជាឱកាសចុងក្រោយរបស់ភាគីក្នុងការកែតម្រូវនូវកំហុសផ្នែកអង្គហេតុនានានៅក្នុងសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យ ហើយភាគីគួរតែប្រើនូវឱកាសមួយនេះ ត្បិតថាការត្រួតពិនិត្យ

លើអង្គហេតុគឺជា សិទ្ធិផ្តាច់មុខរបស់គណៈវិនិច្ឆ័យ ហើយភាគីមិនអាចស្នើសុំកែប្រែនូវកំហុសឆ្គង ផ្នែកអង្គហេតុនៅក្នុងការប្តឹងឧទ្ធរណ៍ឡើយ ព្រោះអង្គភាពឧទ្ធរណ៍អាចពិនិត្យតែលើផ្នែកច្បាប់ប៉ុណ្ណោះ។

សេចក្តីសម្រេចអន្តរកាល គឺជាការសូចនាករដំបូងដ៏សំខាន់មួយ ដែលបង្ហាញពីលទ្ធផលនៃ សេចក្តីសម្រេចចុងក្រោយដែលភាគីអាចនឹងទទួលបាន។ ទោះបីជាសេចក្តីសម្រេចអន្តរកាលនេះ ត្រូវបានរក្សាជាការសម្ងាត់ក៏ដោយ ភាគីមួយ ឬច្រើន ជាញឹកញាប់តែងតែបញ្ចេញនូវខ្លឹមសារនៃ សេចក្តីសម្រេចនេះទៅកាន់សារព័ត៌មាន។ ដោយមិនគិតថាតើ គណៈវិនិច្ឆ័យនឹងកែប្រែនូវសេចក្តី សម្រេចរបស់ខ្លួនឬអត់ បន្ទាប់ពីការត្រួតពិនិត្យអន្តរកាល សេចក្តីសម្រេចចុងក្រោយត្រូវតែមាន យោងនូវអំណះអំណាង ដែលលើកឡើងដោយភាគីក្នុងដំណាក់កាលនៃការត្រួតពិនិត្យអន្តរកាល នោះ។

### ២.២.៣.៦. ការដាក់ចេញនិងការផ្សព្វផ្សាយនូវសេចក្តីសម្រេចចុងក្រោយរបស់គណៈវិនិច្ឆ័យ

គណៈវិនិច្ឆ័យគួរតែដាក់ជូននូវសេចក្តីសម្រេចចុងក្រោយរបស់ខ្លួនទៅកាន់ភាគីវិវាទ នៅក្នុង អំឡុងពេល២សប្តាហ៍ បន្ទាប់ពីការបិទបញ្ចប់នូវការត្រួតពិនិត្យអន្តរកាលនោះ។ នៅពេលដែល សេចក្តីសម្រេចត្រូវបានបកប្រែជាភាសាផ្លូវការផ្សេងទៀតរបស់អង្គការ វានឹងត្រូវបានផ្សព្វផ្សាយទៅ កាន់សមាជិកទាំងអស់របស់អង្គការ និងក្លាយជាឯកសារសាធារណៈ។

នៅក្នុងករណីដែលមានការតវ៉ាច្រើនលើបញ្ហាដូចគ្នា ហើយដែលមានគណៈវិនិច្ឆ័យតែមួយ ត្រូវបានបង្កើតឡើង គណៈវិនិច្ឆ័យផ្តល់ជូននូវសេចក្តីសម្រេចដាច់ដោយឡែកពីគ្នា ប្រសិនបើភាគី ណាមួយដែលពាក់ព័ន្ធស្នើសុំ។

### ២.២.៣.៧. ការអនុម័តនូវសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យ

ទោះបីជាក្នុងសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យ មាននូវផ្នែកសេចក្តីសម្រេច និងសេចក្តី សន្និដ្ឋានក៏ដោយ ក៏សេចក្តីសម្រេចនេះនឹងមានអនុភាពចាប់បង្ខំទាល់តែត្រូវបានអនុម័តដោយ អង្គភាពដោះស្រាយវិវាទ។ នេះជាមូលហេតុដែល DSU ធ្វើការពណ៌នាតួនាទីរបស់គណៈវិនិច្ឆ័យថា មានតួនាទីជាជំនួយការរបស់អង្គភាពដោះស្រាយវិវាទ ទទួលបន្ទុកកិច្ចការដែលមានកំណត់ក្នុង DSU និងនៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មដែលពាក់ព័ន្ធ ដូចជា ការបង្កើតនូវអនុសាសន៍ និងផ្តល់ វិធានដែលមាននៅក្នុងកិច្ចព្រមព្រៀង។[62] អង្គភាពដោះស្រាយវិវាទ ត្រូវអនុម័តនូវសេចក្តីសម្រេច

[62] DSU, 1995, មាត្រា 11។

នោះ ក្នុងអំឡុងពេលដែលមិនមុន២០ថ្ងៃ និងមិនក្រោយ៦០ថ្ងៃ បន្ទាប់ពីសេចក្តីសម្រេចនោះ ត្រូវបានផ្សព្វផ្សាយដល់សមាជិកទាំងអស់របស់អង្គការពាណិជ្ជកម្មពិភពលោក លើកលែងតែភាគីធ្វើការជូនដំណឹងជាផ្លូវការទៅកាន់អង្គភាពដោះស្រាយវិវាទ អំពីការសម្រេចរបស់ខ្លួនថានឹងប្តឹងឧទ្ធរណ៍ ឬអង្គភាពដោះស្រាយវិវាទសម្រេចជាកុងស៊ុងស៊ុសថា មិនអនុម័តនូវសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យ។

ប្រសិនបើភាគីធ្វើការជូនដំណឹងអំពីការសម្រេចចិត្តក្នុងការប្តឹងឧទ្ធរណ៍ សេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យមិនអាចត្រូវបានអនុម័តទេ ដោយហេតុថាអង្គភាពឧទ្ធរណ៍អាចកែប្រែ ឬបដិសេធនូវសេចក្តីសម្រេចនោះ។ នៅក្នុងករណីដូចនេះ សេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យ អាចត្រូវបានយកមកអនុម័តលុះត្រាតែបានបញ្ចប់ការប្តឹងឧទ្ធរណ៍ហើយ។ បើគ្មានការប្តឹងឧទ្ធរណ៍ដោយភាគីណាមួយទេ អង្គភាពដោះស្រាយវិវាទមានកាតព្វកិច្ចក្នុងការអនុម័តនូវសេចក្តីសម្រេចនេះ លើកលែងតែមានកុងស៊ុងស៊ុសប្រឆាំងនឹងការអនុម័តនូវសេចក្តីសម្រេចនោះ។

ដើម្បីអាចត្រូវបានអនុម័តនៅក្នុងកិច្ចប្រជុំរបស់អង្គភាពដោះស្រាយវិវាទ សេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យ ត្រូវតែដាក់ចូលនៅក្នុងរបៀបវារៈនៃកិច្ចប្រជុំរបស់អង្គភាពដោះស្រាយវិវាទ។ ដូច្នេះ ប្រសិនបើគ្មានសមាជិកណាមួយដាក់នូវសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យនៅក្នុងរបៀបវារៈនៃកិច្ចប្រជុំរបស់អង្គភាពដោះស្រាយវិវាទទេ នោះការអនុម័តនូវសេចក្តីសម្រេចនោះមិនត្រូវបានធ្វើឡើងទេ ទោះបីជានេះមិនស្របទៅនឹងមាត្រា ១៦.៤ នៃDSUក៏ដោយ ។ នៅក្នុងប្រវត្តិរបស់អង្គការពាណិជ្ជកម្មពិភពលោក មានតែម្តងគត់ដែលសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យមិនត្រូវបានអនុម័តព្រោះតែមូលហេតុនេះ។

នៅពេលធ្វើការអនុម័ត សមាជិកមានវត្តមាននៅក្នុងកិច្ចប្រជុំរបស់អង្គភាពដោះស្រាយវិវាទ ជាពិសេសសមាជិកដែលជាប់ពាក់ព័ន្ធនឹងវិវាទ ជាញឹកញាប់ប្រើប្រាស់សិទ្ធិរបស់ខ្លួន ក្នុងការមានមតិយោបល់លើសេចក្តីសន្និដ្ឋាន និងមូលហេតុដែលមានក្នុងសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យ។ ក្នុងកាលៈទេសៈដែលគណៈវិនិច្ឆ័យដាក់ចេញនូវសេចក្តីសម្រេច និងសំអាងហេតុគាំទ្រសេចក្តីសម្រេចដែលមិនដូចការរំពឹងទុករបស់ខ្លួន ភាគី និងសមាជិកដទៃទៀតអាចបង្ហាញការប្រឆាំងរបស់គេលើសេចក្តីសម្រេច និងសំអាងហេតុនោះ។ ក្នុងប្រព័ន្ធដោះស្រាយវិវាទរបស់អង្គការពាណិជ្ជកម្មពិភពលោកពីមុន ប្រធានអង្គភាពដោះស្រាយវិវាទ សាកសួរដើម្បីដឹងថាមានកុងស៊ុងស៊ុសប្រឆាំងនឹងការអនុម័តសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យដែលដាក់ចូលដើម្បីអនុម័តដែរឬទេ។ ប៉ុន្តែបច្ចុប្បន្នប្រធានអង្គភាពដោះស្រាយវិវាទ គ្រាន់តែទុកឱកាសឲ្យភាគីវិវាទ និងសមាជិកដទៃទៀត

បង្ហាញនូវការយល់ឃើញរបស់ពួកគេ។ ពេលខ្លះមានសមាជិកម្នាក់បញ្ចុះបញ្ចូលសមាជិកដទៃទៀត ដើម្បីប្រឆាំងនឹងសេចក្តីសម្រេចនោះ ប៉ុន្តែការណ៍នេះគ្មានផលវិបាកអ្វីទេ ត្បិតថាការបដិសេធមិនទទួលយកសេចក្តីសម្រេចនោះ ទាមទារឲ្យមានកុងស៊ុងស៊ុសពីសំណាក់សមាជិកទាំងអស់ដែលមានវត្តមាននៅក្នុងការប្រជុំ។ ដូច្នេះប្រធានអង្គភាពដោះស្រាយវិវាទគ្រាន់តែលើកឡើងថា អង្គភាពកត់ចំណាំនូវសេចក្តីថ្លែងការណ៍ទាំងអស់ និងអនុម័តនូវសេចក្តីសម្រេចនោះ។ ប្រសិនបើគ្មានការប្តឹងឧទ្ធរណ៍ទេនោះ វិវាទនឹងបន្តទៅកាន់ដំណាក់កាលនៃការអនុវត្តបន្ទាប់ពីអង្គភាពដោះស្រាយវិវាទធ្វើការអនុម័តនូវសេចក្តីសម្រេចនោះ។

ពាក់ព័ន្ធនឹងការអនុម័តលើសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យនេះដែរ ទោះបីជាភាគីមានសិទ្ធិពេញលេញក្នុងការចូលរួមក្នុងការពិចារណា របស់អង្គភាពដោះស្រាយវិវាទលើសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យ ប៉ុន្តែការអនុម័តសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យ មិនទាមទារកុងស៊ុងស៊ុសទេក្នុងប្រព័ន្ធដោះស្រាយវិវាទរបស់អង្គការពាណិជ្ជកម្មពិភពលោក។ សមាជិកតែម្នាក់ឯង ជាពិសេសភាគីដែលចាញ់ក្តី ឬសមាជិកភាគច្រើន មិនអាចធ្វើការរារាំងនូវការអនុម័តនូវសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យទេ លុះត្រាតែមាននូវកុងស៊ុងស៊ុសប្រឆាំងពីសំណាក់សមាជិកទាំងអស់ដែលមានវត្តមាននៅក្នុងកិច្ចប្រជុំរបស់អង្គភាពដោះស្រាយវិវាទ។ និយាយមួយ បែបទៀត សមាជិកតែមួយដែលទទូចសុំ អោយមានការអនុម័តនូវសេចក្តីសម្រេច គឺគ្រប់គ្រាន់ដើម្បីធានាថាសេចក្តីសម្រេចនោះត្រូវបានអនុម័ត។

## ២.៣. ការជំនុំជម្រះក្តីនៅក្នុងអង្គភាពឧទ្ធរណ៍

ការដោះស្រាយវិវាទ ពេលខ្លះមិនអាចត្រូវបានបញ្ចប់ក្នុងដំណាក់កាលគណៈវិនិច្ឆ័យឡើយ ដោយភាគីវិវាទមិនពេញចិត្តទៅនឹងសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យ ហើយធ្វើការប្តឹងឧទ្ធរណ៍ទៅកាន់អង្គភាពឧទ្ធរណ៍ ដើម្បីសម្រេចសេចក្តីបន្ត។

### ២.៣.១. ការដាក់ពាក្យបណ្តឹងឧទ្ធរណ៍ និងលក្ខខណ្ឌបណ្តឹង

សេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យ ត្រូវតែអនុម័តដោយអង្គភាពដោះស្រាយវិវាទ ក្នុងអំឡុងពេល៦០ថ្ងៃ បន្ទាប់ពីការផ្សព្វផ្សាយនូវសេចក្តីសម្រេចនោះទៅកាន់សមាជិកអង្គការពាណិជ្ជកម្មពិភពលោក លើកលែងតែភាគីសម្រេចប្តឹងឧទ្ធរណ៍។ ការប្តឹងឧទ្ធរណ៍ត្រូវចាប់ផ្តើមឡើង ដោយការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់អង្គភាពដោះស្រាយវិវាទ និងស្របពេលជាមួយគ្នាត្រូវធ្វើ

ការបំពេញនូវការជូនដំណឹងអំពីការប្តឹងឧទ្ធរណ៍ ជាមួយនឹងលេខាធិការដ្ឋាននៃអង្គភាពឧទ្ធរណ៍។[63] ភាគីដែលបំពេញនូវការជូនដំណឹងអំពីការប្តឹងឧទ្ធរណ៍ហៅថា ដើមបណ្តឹងឧទ្ធរណ៍។ វិធានទី២០នៃនីតិវិធីការងារត្រួតពិនិត្យឧទ្ធរណ៍ បានកំណត់អំពីអ្វីដែលត្រូវដាក់បញ្ចូលទៅក្នុងការជូនដំណឹងអំពីការប្តឹងឧទ្ធរណ៍។[64]

នៅថ្ងៃជាមួយគ្នានៃការបំពេញពាក្យជូនដំណឹងអំពីការប្តឹងឧទ្ធរណ៍ ដើមបណ្តឹងឧទ្ធរណ៍ក៏ត្រូវបំពេញពាក្យសុំជាលាយលក្ខណ៍អក្សរផងដែរស្របតាមវិធានទី២១ (១) នៃនីតិវិធីការងារត្រួតពិនិត្យឧទ្ធរណ៍។ ភាគីវិវាទដែលមានបំណងឆ្លើយតបទៅនិង ការលើកឡើងរបស់ដើមបណ្តឹងឧទ្ធរណ៍ អាចបំពេញនូវពាក្យសុំជាលាយលក្ខណ៍អក្សររបស់ខ្លួនក្រោមវិធាន ២២ នៃនីតិវិធីការងារត្រួតពិនិត្យឧទ្ធរណ៍ នៅក្នុងអំឡុងពេល ១៨ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងអំពីការប្តឹងឧទ្ធរណ៍ និងពាក្យសុំរបស់ដើមបណ្តឹងឧទ្ធរណ៍ ត្រូវបានបំពេញ។ ភាគីដែលបំពេញពាក្យសុំស្របតាមវិធាន២២នេះហៅថាចុងបណ្តឹងឧទ្ធរណ៍។[65]

នីតិវិធីការងារត្រួតពិនិត្យឧទ្ធរណ៍ទទួលស្គាល់ថា វិវាទមួយចំនួនអាចមានជាប់ពាក់ព័ន្ធនឹងការប្តឹងឧទ្ធរណ៍ច្រើន ដូច្នេះហើយ ក្រោមវិធាន២៣ ភាគីនៃវិវាទមួយក្រៅពីដើមបណ្តឹងឧទ្ធរណ៍ដើមអាចប្តឹងឧទ្ធរណ៍ដោយផ្អែកលើមូលដ្ឋានដូចគ្នា ឬដោយលើកឡើងនូវបញ្ហាផ្សេងទៀត ដោយធ្វើការបំពេញនូវការជូនដំណឹងអំពីការប្តឹងឧទ្ធរណ៍ផ្សេងទៀត និងពាក្យសុំជាលាយលក្ខណ៍អក្សរ ក្នុងអំឡុងពេល៥ថ្ងៃនៃការបំពេញការជូនដំណឹងអំពីការប្តឹងឧទ្ធរណ៍។ ភាគីនេះហៅថា ដើមបណ្តឹងឧទ្ធរណ៍ផ្សេងទៀត។ ភាគីដែលមានបំណងធ្វើការឆ្លើយតបទៅនឹងការលើកឡើងរបស់ដើមបណ្តឹងឧទ្ធរណ៍ផ្សេងទៀតនោះ អាចបំពេញនូវពាក្យសុំជាលាយលក្ខណ៍អក្សរក្នុងអំឡុងពេល១៨ថ្ងៃនៃការបំពេញនូវការជូនដំណឹងអំពីការប្តឹងឧទ្ធរណ៍។[66]

សមាជិកដែលជាភាគីទីបីនៅក្នុងដំណាក់កាលនៃការជម្រះក្តីនៅគណៈវិនិច្ឆ័យ អាចបំពេញនូវពាក្យសុំក្នុងអំឡុងពេល២១ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការបំពេញការជូនដំណឹងអំពីការប្តឹងឧទ្ធរណ៍ ស្របតាមវិធាន២៤នៃនីតិវិធីការងារត្រួតពិនិត្យឧទ្ធរណ៍។ ទោះបីជាភាគីដែលមានបំណងចូលរួមនៅក្នុងការជំនុំជម្រះរបស់គណៈវិនិច្ឆ័យ ត្រូវបានលើកទឹកចិត្តអោយបំពេញនូវពាក្យសុំក៏

[63] Dispute settlement: appellate procedures [ការដោះស្រាយវិវាទ: នីតិវិធីបណ្តឹងឧទ្ធរណ៍], https://www.wto.org/english/tratop_e/dispu_e/ab_procedures_e.htm(ចូលអាន និងទាញយកថ្ងៃទី15 ឧសភា 2015)។

[64] ដូច 63។

[65] ដូច 63។

[66] ដូច 63។

ដោយ ផ្ទុយទៅវិញពួកគេធ្វើការជូនដំណឹងទៅកាន់លេខាធិការដ្ឋានអង្គភាពឧទ្ធរណ៍ នៅក្នុងអំឡុងពេល២១ថ្ងៃនោះ អំពីបំណងរបស់ខ្លួនក្នុងការចូលរួមក្នុងទាញហេតុផលផ្ទាល់មាត់។ ទោះជាយ៉ាងណា ភាគីទីបីដែលមិនបំពេញនូវពាក្យសុំជាលាយលក្ខណ៍អក្សរ ឬធ្វើការជូនដំណឹងនៅក្នុងអំឡុងពេល២១ថ្ងៃ អាចចូលរួមនៅក្នុងការទាញហេតុផលផ្ទាល់មាត់នៅក្នុង the discretion of the Appellate Body Division ដែលមានសមាជិកអង្គភាពឧទ្ធរណ៍៣រូប ធ្វើការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នោះ។ ភាគីទីបីដែលបំពេញនូវពាក្យសុំជាលាយលក្ខណ៍អក្សរ ឬដែលមានវត្តមាននៅក្នុងការទាញហេតុផលផ្ទាល់មាត់ ត្រូវបានហៅថា អ្នកចូលរួមទីបី។[67]

ភាគីនៃវិវាទអាចប្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យពេលណាក៏បាន អោយតែមុនពេលដែលសេចក្តីសម្រេចនោះត្រូវបានអនុម័តដោយអង្គភាពដោះស្រាយវិវាទ។ ភាគីទីបីគ្មានសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ទេ។ ការប្តឹងឧទ្ធរណ៍នេះ ត្រូវបានកម្រិតត្រឹមតែលើបញ្ហាផ្នែកច្បាប់ដែលគ្រប់ដណ្តប់លើសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យ និងការបកស្រាយច្បាប់ដែលធ្វើឡើងដោយគណៈវិនិច្ឆ័យប៉ុណ្ណោះ ។

### ២.៣.២. នីតិវិធីនៃការជំនុំជម្រះ

ការទាញហេតុផលផ្ទាល់មាត់ ត្រូវបានធ្វើឡើងសម្រាប់រាល់ការប្តឹងឧទ្ធរណ៍។ នៅក្នុងការទាញហេតុផលផ្ទាល់មាត់នេះ ដើមបណ្តឹងឧទ្ធរណ៍ ដើមបណ្តឹងឧទ្ធរណ៍ផ្សេងទៀត ចុងបណ្តឹងឧទ្ធរណ៍ និងអ្នកចូលរួមទីបី ត្រូវបានផ្តល់ឱកាសដើម្បីធ្វើសេចក្តីថ្លែងការណ៍ផ្ទាល់មាត់ និងធ្វើការឆ្លើយតបទៅនឹងសំណួរដែលដាក់ជូនដោយអង្គភាពឧទ្ធរណ៍ ដែលជំនុះជម្រះបណ្តឹងឧទ្ធរណ៍។ ការជំនុំជម្រះជាទូទៅធ្វើឡើងក្នុងអំឡុងពេល៣០ទៅ៤៥ថ្ងៃ បន្ទាប់ពីការជូនដំណឹងពីការប្តឹងឧទ្ធរណ៍។ នីតិវិធីជំនុំជម្រះនៅក្នុងអង្គភាពឧទ្ធរណ៍គឺត្រូវបានរក្សាការសម្ងាត់ ដោយមានតែសមាជិកអង្គការពាណិជ្ជកម្មពិភពលោកដែលជាដើមបណ្តឹងឧទ្ធរណ៍ ដើមបណ្តឹងឧទ្ធរណ៍ផ្សេងទៀត ចុងបណ្តឹងឧទ្ធរណ៍ និងអ្នកចូលរួមទីបី ដែលមានសិទ្ធិចូលរួមនៅក្នុងការទាញហេតុផលផ្ទាល់មាត់នេះ។ ទោះជាយ៉ាងណា មានករណីមួយចំនួនដែលការទាញហេតុផលផ្ទាល់មាត់របស់អង្គភាពឧទ្ធរណ៍ត្រូវបានបើកចំហដល់សាធារណៈជនតាមសំណើរបស់ភាគី។[68]

បន្ទាប់ពីការទាញហេតុផលផ្ទាល់មាត់ និងមុនពេលចេញសេចក្តីសម្រេចរបស់អង្គភាពឧទ្ធរណ៍ Appellate Body Division ដែលជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ធ្វើការផ្លាស់ប្តូរយោបល់គ្នាទៅ

[67] ដូច 63 ។

[68] ដូច 63។

វិញទៅមករវាងសមាជិករបស់អង្គភាពឧទ្ធរណ៍ស្របតាម វិធាន៤(៣) នៃនីតិវិធីការងារត្រួតពិនិត្យឧទ្ធរណ៍។

### ២.៣.៣. អំពីសេចក្តីសម្រេចរបស់អង្គភាពឧទ្ធរណ៍

សេចក្តីសម្រេចរបស់អង្គភាពត្រូវបានផ្សព្វផ្សាយទៅកាន់សមាជិករបស់អង្គការ WTO នៅក្នុងពភាសាផ្លូវការរបស់អង្គការ (អង់គ្លេស បារាំង និងអេស្ប៉ាញ) នៅក្នុងអំឡុងពេល៩០ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទនៃការបំពេញពាក្យជូនដំណឹងអំពីការប្តឹងឧទ្ធរណ៍ ហើយសេចក្តីសម្រេចនេះនឹងក្លាយជាឯកសារសាធារណៈភ្លាមៗ បន្ទាប់ពីត្រូវបានផ្សព្វផ្សាយដល់សមាជិក។ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន អង្គភាពឧទ្ធរណ៍អាចរក្សា កែប្រែ ឬបដិសេធនូវការសម្រេច និងការសន្និដ្ឋានផ្នែកច្បាប់របស់គណៈវិនិច្ឆ័យ។[69]

នៅក្នុងអំឡុងពេល៣០ថ្ងៃនៃការផ្សព្វផ្សាយនូវសេចក្តីសម្រេចរបស់អង្គភាពឧទ្ធរណ៍ សេចក្តីសម្រេចនេះ រួមទាំងសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យ ដែលត្រូវបានរក្សាទុកដដែល កែប្រែ ឬបដិសេធនោះ នឹងត្រូវបានដាក់ចូលនៅក្នុងរបៀបវារៈនៃការប្រជុំរបស់អង្គភាពដោះស្រាយវិវាទដើម្បីធ្វើការអនុម័ត។ អង្គភាពដោះស្រាយវិវាទនឹងធ្វើការអនុម័តនូវសេចក្តីសម្រេចនោះ លើកលែងតែអង្គភាពដោះស្រាយវិវាទធ្វើការសម្រេចជាកុងស៊ុងស៊ុសថា មិនអនុម័តនូវសេចក្តីសម្រេចនោះ ដែលការណ៍នេះមិនដែលកើតមានទេកន្លងមក។ សេចក្តីសម្រេចរបស់អង្គភាពឧទ្ធរណ៍ និងគណៈវិនិច្ឆ័យដែលត្រូវបានអនុម័ត ត្រូវតែបានទទួលយកដោយភាគីវិវាទដោយគ្មានលក្ខខណ្ឌ។[70]

### ២.៣.៤. ការអនុម័តនូវសេចក្តីសម្រេចរបស់អង្គភាពឧទ្ធរណ៍

អង្គភាពដោះស្រាយវិវាទ ត្រូវធ្វើការអនុម័តលើសេចក្តីសម្រេចរបស់អង្គភាពឧទ្ធរណ៍ ហើយបន្ទាប់ពីការអនុម័តភាគីត្រូវទទួលយកនូវសេចក្តីសម្រេចនោះដោយគ្មានលក្ខខណ្ឌ លើកលែងតែអង្គភាពដោះស្រាយវិវាទ សម្រេចកុងស៊ុងស៊ុសមិនអនុម័តសេចក្តីសម្រេចរបស់អង្គភាពឧទ្ធរណ៍នៅក្នុងអំឡុងពេល៣០ថ្ងៃ បន្ទាប់ពីការផ្សព្វផ្សាយពីសេចក្តីសម្រេចនោះទៅកាន់សមាជិក។ នីតិវិធីនៃការអនុម័តនេះ គឺដូចគ្នានឹងការអនុម័តសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យដោយអង្គភាពដោះស្រាយវិវាទដូច្នោះដែរ ដូចជា លក្ខណៈស្វ័យប្រវត្តិនៃការអនុម័តការបង្ហាញមតិយោបល់របស់សមាជិកអង្គការ និងការតម្រូវឲ្យដាក់សេចក្តីសម្រេចរបស់អង្គភាពឧទ្ធរណ៍ចូលទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំរបស់អង្គភាពដោះស្រាយវិវាទ ដើម្បីទទួលបានការអនុម័តជាដើម។ ទោះជាយ៉ាងណា

---

[69] ដូច 63។

[70] ដូច 63។

រយៈពេលផុតកំណត់សម្រាប់ការអនុម័តសេចក្តីសម្រេចរបស់អង្គភាពឧទ្ធរណ៍គឺ ត្រឹមតែ៣០ថ្ងៃប៉ុណ្ណោះ ព្រោះថាភាគីមិនចាំបាច់សម្រេចចិត្តថាត្រូវប្តឹងឧទ្ធរណ៍ឬអត់ដូចជាករណីសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យឡើយ។ ជាពិសេសជាងនេះទៀត ភាគីត្រូវតែទទួលយកនូវសេចក្តីសម្រេចរបស់អង្គភាពឧទ្ធរណ៍ដោយគ្មានលក្ខខណ្ឌ និងដោយគ្មានសិទ្ធិប្តឹងឧទ្ធរណ៍បន្តទៀតឡើយ។[71]

ទោះបីជាមាត្រា ១៧ ចំណុច ១៤នៃDSU មិនបានលើកឡើងអំពីសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យក៏ដោយ ក៏វាត្រូវបានគេយល់ថា សេចក្តីសម្រេចរបស់អង្គភាពឧទ្ធរណ៍ត្រូវអនុម័តជាមួយគ្នានឹងសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យ ព្រោះថាគេអាចយល់វិធានទាំងមូលបានលុះត្រាតែអាននូវសេចក្តីសម្រេចទាំងពីរ។ អង្គភាពដោះស្រាយវិវាទនឹងធ្វើការពិចារណាលើសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យចំពោះការអនុម័ត បន្ទាប់ពីបញ្ចប់នូវការប្តឹងឧទ្ធរណ៍។[72] ដូច្នេះ សេចក្តីសម្រេចទាំងពីរត្រូវបានដាក់ចូលក្នុងរបៀបវារៈរបស់អង្គភាពដោះស្រាយវិវាទ ដើម្បីធ្វើការអនុម័ត ហើយអង្គភាពនេះធ្វើការអនុម័តលើសេចក្តីសម្រេចរបស់អង្គភាពឧទ្ធរណ៍ ព្រមជាមួយនិងសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យ ដែលត្រូវបានរក្សានៅដដែល កែប្រែ ឬបដិសេធដោយសេចក្តីសម្រេចរបស់អង្គភាពឧទ្ធរណ៍។ ក្នុងករណីដែលសេចក្តីសន្និដ្ឋានរបស់គណៈវិនិច្ឆ័យ មិនត្រូវបានកែប្រែ ឬបដិសេធ ឬប្តឹងឧទ្ធរណ៍ នោះសេចក្តីសន្និដ្ឋានរបស់គណៈវិនិច្ឆ័យនោះមានអានុភាពចាប់បង្ខំឲ្យភាគីអនុវត្ត។

អនុសាសន៍ និងវិធានរបស់អង្គភាពដោះស្រាយវិវាទ មិនអាចបន្ថែម ឬលុបចោលនូវសិទ្ធិ និងកាតព្វកិច្ច ដែលត្រូវបានផ្តល់នៅក្នុងកិច្ចព្រមព្រៀងពាក់ព័ន្ធនឹងកិច្ចការពាណិជ្ជកម្មឡើយ។[73] មួយវិញទៀត ភាពស្របជាមួយរវាងអនុសាសន៍ វិធានរបស់អង្គភាពដោះស្រាយវិវាទ និងបទបញ្ញត្តិដែលមានចែងក្នុងកិច្ចព្រមព្រៀងពាក់ព័ន្ធនឹងកិច្ចការពាណិជ្ជកម្ម ពិតជាមានសារៈសំខាន់ក្នុងការធានានូវប្រសិទ្ធិភាពនៃដំណោះស្រាយវិវាទ និងដើម្បីអាចផ្តល់នូវផលប្រយោជន៍ទៅកាន់សមាជិកអង្គការពាណិជ្ជកម្មពិភពលោកទាំងអស់។[74] អង្គភាពដោះស្រាយវិវាទ ទទួលខុសត្រូវក្នុងការពិនិត្យមើលនូវការអនុវត្តវិធាន និងអនុសាសន៍របស់ខ្លួនដោយសមាជិកអង្គការពាណិជ្ជកម្មពិភពលោក។

[71] DSU, 1995, មាត្រា 17 ចំណុច 14។

[72] DSU, 1995, មាត្រា 16 ចំណុច 4។

[73] DSU, 1995, មាត្រា 3 ចំណុច 2។

[74] DSU, 1995, មាត្រា 21 ចំណុច 1។

## ២.៤. អានុភាពនៃសេចក្តីសម្រេចដែលអនុម័តដោយអង្គភាពដោះស្រាយជម្លោះ

ទាំងសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យ និងអង្គភាពឧទ្ធរណ៍ ដែលត្រូវបានអនុម័តរួចរាល់ដោយអង្គភាពដោះស្រាយវិវាទ នឹងបង្កើតអានុភាពអោយភាគីធ្វើការអនុវត្តតាមសេចក្តីសម្រេចនោះ ហើយក្នុងករណីដែលភាគីមិនអនុវត្តតាមសេចក្តីសម្រេចនោះទេ សេចក្តីសម្រេចនេះក៏នឹងបង្កើតអានុភាពដោយអនុញ្ញាតឲ្យអង្គភាពដោះស្រាយវិវាទមានចំណាត់ការចំពោះការមិនអនុវត្ត។

### ២.៤.១. ការអនុវត្តតាមសេចក្តីសម្រេចរបស់ភាគី

នៅពេលដែលអង្គភាពដោះស្រាយវិវាទ ធ្វើការអនុម័តសេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យ និងអង្គភាពឧទ្ធរណ៍ អង្គភាពនេះក៏ផ្តល់នូវអនុសាសន៍ និងវិធានសម្រាប់អនុវត្តទៅកាន់ភាគីដែលចាញ់ក្តី ដើម្បីរៀបចំវិធានពាណិជ្ជកម្មរបស់ខ្លួនដែលត្រូវបានតវ៉ានោះ អោយវិលមកស្របនឹងច្បាប់របស់អង្គការពាណិជ្ជកម្មពិភពលោកវិញ នៅពេលដែលការតវ៉ាអំពីការរំលោភបំពាន បានសម្រេច ឬស្វែងរកនូវការសម្រុះសម្រួលដែលមានការពេញចិត្តទៅវិញទៅមក ក្នុងករណីដែលការតវ៉ាដែលមិនពាក់ព័ន្ធនឹងការមិនរំលោភបំពានបានជោគជ័យ។

ក្នុងករណីដែលអវត្តមាននូវដំណោះស្រាយវិវាទដែលមានការព្រមព្រៀងទៅវិញទៅមក កម្មវត្ថុចំបងនៃយន្តការដោះស្រាយវិវាទ គឺជានាអំពីការដកចេញនូវវិធានដែលត្រូវបានរកឃើញថាមិនស្របទៅនឹងច្បាប់របស់អង្គការ WTO។[75] ហើយការប្រព្រឹត្តឲ្យស្របតាមអនុសាសន៍ និងវិធានរបស់អង្គភាពដោះស្រាយវិវាទឲ្យបានត្រឹមត្រូវ ពិតជាមានសារៈសំខាន់ដើម្បីធានាអំពីប្រសិទ្ធិភាពនៃដំណោះស្រាយវិវាទ។[76]

អង្គភាពដោះស្រាយវិវាទ គឺជាអង្គភាពមួយរបស់អង្គការពាណិជ្ជកម្មពិភពលោក ដែលទទួលខុសត្រូវក្នុងការណែនាំពីការអនុវត្តសេចក្តីសម្រេចគណៈវិនិច្ឆ័យ និងអង្គភាពឧទ្ធរណ៍។[77] ចំណែកភាគីចាញ់ក្តី ឬចុងចម្លើយ មានកាតព្វកិច្ចជូនដំណឹងទៅកាន់អង្គភាពដោះស្រាយវិវាទ ក្នុងអំឡុងពេល៣០ថ្ងៃ បន្ទាប់ពីការអនុម័តនូវសេចក្តីសម្រេចអំពីឆន្ទៈនៅក្នុងការអនុវត្តតាមអនុសាសន៍ និងវិធានដែលដាក់ចេញដោយអង្គភាពដោះស្រាយវិវាទ។[78]

[75] DSU, 1995, មាត្រា 3 ចំណុច 7។
[76] DSU, 1995, មាត្រា 21 ចំណុច 1។
[77] DSU, 1995, មាត្រា 2។
[78] DSU, 1995, មាត្រា 21 ចំណុច 3។

## ២.៤.២. ចំណាត់ការចំពោះការមិនអនុវត្តតាមសេចក្តីសម្រេច

ប្រសិនបើភាគីចាញ់ក្តី ឬចុងចម្លើយមិនអាចធ្វើឲ្យវិធានរបស់ខ្លួនវិលមកស្របតាមកាតព្វកិច្ច និងច្បាប់ក្រោមអង្គការពាណិជ្ជកម្មពិភពលោកក្នុងអំឡុងពេលសមរម្យដែលបានផ្តល់ឲ្យទេ នោះដើមបណ្តឹង ឬភាគីឈ្នះក្តីមានសិទ្ធិប្រើប្រាស់នូវវិធានបណ្តោះអាសន្ន ដែលអាចជាការសងសំណងខូចខាត ឬការព្យួរកាតព្វកិច្ច។ ប៉ុន្តែវិធីទាំងពីរនេះ មិនត្រូវបានគេជំរុញឲ្យប្រើដូចការអនុវត្តដោយពេញលេញនូវអនុសាសន៍ និងវិធានរបស់អង្គភាពដោះស្រាយវិវាទឡើយ។[79]

### ២.៤.២.១. អំពីសំណងការខូចខាត

ប្រសិនបើភាគីដែលត្រូវអនុវត្តតាមអនុសាសន៍ និងវិធានដែលដាក់ចេញដោយអង្គភាពដោះស្រាយវិវាទ មិនអាចធ្វើការអនុវត្តតាមបាននៅក្នុងអំឡុងពេលសមរម្យដែលបានផ្តល់ជូននោះ ភាគីនោះត្រូវធ្វើការចរចាជាមួយនឹងដើមបណ្តឹង ឬភាគីឈ្នះក្តី អំពីសំណងនៃការខូចខាតដែលអាចទទួលយកបានដោយភាគីទាំងសងខាង។[80] សំណងនេះមិនសំដៅលើសំណងជាប្រាក់កាសនោះទេ ប៉ុន្តែចុងចម្លើយឬភាគីចាញ់ក្តី ត្រូវផ្តល់នូវអត្ថប្រយោជន៍ណាមួយ ឧទាហរណ៍ ការកាត់បន្ថយពន្ធនាំចូល ដែលស្មើនឹងអត្ថប្រយោជន៍ដែលចុងចម្លើយបានធ្វើឲ្យដើមបណ្តឹងបាត់បង់ ឬថមថយដោយសារតែការអនុវត្តនូវវិធានរបស់ចុងចម្លើយនោះ។

ម្យ៉ាងទៀត ភាគីនៃវិវាទត្រូវធ្វើការយល់ព្រមទៅលើសំណងនៃការខូចខាតនោះ ដែលត្រូវតែស្របទៅនឹងកិច្ចព្រមព្រៀងដែលគ្រប់គ្រងលើកិច្ចការពាណិជ្ជកម្ម។[81] នេះប្រហែលជាមូលហេតុមួយ ដែលភាគីពិបាកនៅក្នុងការកំណត់នូវសំណងនៃការខូចខាតនៅពេលដែលរឿងក្តីឈានដល់ដំណាក់កាលនេះ។ បន្ថែមលើនេះទៀត បើសំណងត្រូវបានផ្តល់ជូននៅក្នុងទម្រង់ជាកាត់បន្ថយនូវពន្ធនាំចូល នោះសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ក្រៅពីដើមបណ្តឹងក៏អាចទទួលបានផលប្រយោជន៍ដែរ ។ ការណ៍នេះនាំអោយសំណងនៃការខូចខាតមិនសូវមានការទាក់ទាញដល់ភាគីទាំងពីរ ទាំងចុងចម្លើយដែលជាអ្នកលើកឡើងនូវតម្លៃនៃសំណងនៃការខូចខាត និងភាគីដើមបណ្តឹងដែលមិនអាចទទួលបាននូវផលប្រយោជន៍ផ្ទាល់មុខ។ ទោះជាយ៉ាងណាក៏ដោយ បើភាគីជ្រើសរើសយកផលប្រយោជន៍ពាណិជ្ជកម្ម(ការកាត់បន្ថយពន្ធនាំចូល) ក្នុងផលប្រយោជន៍នៃវិស័យ

[79] DSU, 1995, មាត្រា 3 ចំណុច 7 និងមាត្រា 22 ចំណុច 1។

[80] DSU, 1995, មាត្រា 22 ចំណុច 2។

[81] DSU, 1995, មាត្រា 22 ចំណុច 1។

នាំចេញជាក់លាក់ណាមួយរបស់ដើមបណ្តឹង ហើយសមាជិកដទៃទៀតមានផលប្រយោជន៍តិចតួច ក្នុងវិស័យ ឬផលិតផលនោះ ឧបសគ្គទាំងនោះអាចជម្នះបាន។

**២.៤.២.២. វិធានការតបត(ការព្យួរកាតព្វកិច្ច)**

ប្រសិនបើក្នុងអំឡុងពេល២០ថ្ងៃ បន្ទាប់ពីថ្ងៃផុតកំណត់អំឡុងពេលសមហេតុផលហើយ ភាគីវិវាទមិនមានការព្រមព្រៀងលើសំណងការខូចខាតទេ ដើមបណ្តឹងអាចស្នើសុំការអនុញ្ញាតពីអង្គភាពដោះស្រាយវិវាទ ដើម្បីដាក់ចេញនូវទណ្ឌកម្មពាណិជ្ជកម្មប្រឆាំងនឹងចុងចម្លើយដែលមិនអនុវត្តតាមសេចក្តីសម្រេច។ ជាលក្ខណៈបច្ចេកទេស នេះហៅថា ការព្យួរសម្បទាន ឬកាតព្វកិច្ចដទៃទៀតនៅក្នុងកិច្ចព្រមព្រៀងដែលពាក់ព័ន្ធ។

សម្បទាននេះ មានជាឧទាហរណ៍ ការប្តេជ្ញាកាត់បន្ថយពន្ធគយ ដែលសមាជិកអង្គការបានធ្វើនៅក្នុងការចរចាពាណិជ្ជកម្មពហុភាគី និងដែលស្ថិតនៅក្រោមអានុភាពមាត្រា ២ នៃ GATT។ សម្បទានដែលចងភ្ជាប់ទាំងនេះ គឺស្ថិតនៅក្នុងទម្រង់មួយនៃកាតព្វកិច្ចរបស់អង្គការពាណិជ្ជកម្មពិភពលោក។ ការព្យួរកាតព្វកិច្ចក្នុងទំនាក់ទំនងជាមួយនឹងសមាជិកដទៃទៀត ទាមទារនូវការផ្តល់អំណាចពីអង្គភាពដោះស្រាយវិវាទជាមុន។ ដូច្នេះ ដើមបណ្តឹងត្រូវបានការអនុញ្ញាតអោយដាក់ចេញនូវវិធានការតបត ដើម្បីជាការឆ្លើយតបចំពោះការរំលោភបំពានជាមុន ទើបអាចប្រើវិធាននេះបាន។ នេះត្រូវបានហៅក្រៅផ្លូវការថា ការតបត ឬទណ្ឌកម្ម។ ការព្យួរកាតព្វកិច្ចដូចនេះ ធ្វើឡើងចំពោះតែសមាជិកដែលបរាជ័យក្នុងការអនុវត្តតែប៉ុណ្ណោះ។

ការតបតគឺជាវិធានការចុងក្រោយ និងធ្ងន់ធ្ងរបំផុតដែលភាគីមិនអនុវត្តតាមសេចក្តីសម្រេចត្រូវប្រឈមនៅក្នុងប្រព័ន្ធដោះស្រាយវិវាទរបស់អង្គការពាណិជ្ជកម្មពិភពលោក។[82] ទោះបីជាការតបតនេះ ត្រូវទទួលបានការយល់ព្រមជាមុនពីអង្គភាពដោះស្រាយវិវាទក៏ដោយ ក៏វិធានការតបតនេះត្រូវបានអនុវត្តតែចំពោះសមាជិកម្នាក់ទល់នឹងម្នាក់ប៉ុណ្ណោះ។

## ២.៥. ការអនុគ្រោះពិសេសក្នុងដំណើរការដោះស្រាយវិវាទចំពោះប្រទេសកំពុងអភិវឌ្ឍ និងប្រទេសមានការអភិវឌ្ឍន៍តិចតួចដែលជាប់ពាក់ព័ន្ធក្នុងបញ្ហាវិវាទ

នៅក្នុងប្រព័ន្ធដោះស្រាយវិវាទរបស់អង្គការពាណិជ្ជកម្មពិភពលោក មានបទបញ្ញត្តិពិសេសសម្រាប់ការអនុវត្តក្នុងការដោះស្រាយវិវាទដែលមានជាប់ពាក់ព័ន្ធនឹងប្រទេសកំពុងអភិវឌ្ឍន៍ និងប្រព័ន្ធអភិវឌ្ឍន៍តិចតួច។ នៅក្នុងកិច្ចព្រមព្រៀងអង្គការ WTO មានរួមបញ្ចូលនូវបទបញ្ញត្តិជាច្រើន

[82] DSU, 1995, មាត្រា 3 ចំណុច 7។

ដែលផ្តល់អោយប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍តិចតួចនូវសិទ្ធិពិសេស ឬការអត់អោនបន្ថែម ដែលជាការអនុគ្រោះពិសេស និងដាច់ដោយឡែក។ ក្នុងចំណោមនេះ មានបទបញ្ញត្តិដែលអនុញ្ញាតអោយប្រទេសអភិវឌ្ឍន៍អនុគ្រោះច្រើនចំពោះប្រទេសកំពុងអភិវឌ្ឍន៍ ជាងសមាជិកដទៃរបស់អង្គការ WTO។

### ២.៥.១. ការអនុគ្រោះចំពោះប្រទេសកំពុងអភិវឌ្ឍន៍

ជាទូទៅមានការយល់ថា រាល់ប្រព័ន្ធដោះស្រាយវិវាទពហុភាគីដែលមានស្រាប់ ផ្តល់ផលប្រយោជន៍ដល់ប្រទេសកំពុងអភិវឌ្ឍន៍ និងសមាជិកតូចតាច ក្នុងលក្ខណៈត្រង់ថាសមាជិកទាំងអស់អាចប្រើប្រាស់នូវប្រព័ន្ធដោះស្រាយវិវាទនោះដូចគ្នា ហើយសេចក្តីសម្រេចគឺត្រូវបានធ្វើឡើងដោយផ្អែកលើវិធានច្បាប់ជាជាងអំណាចខាងសេដ្ឋកិច្ច។ លក្ខណៈបែបនេះបានផ្តល់សិទ្ធិអំណាចឲ្យប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសដែលមានសេដ្ឋកិច្ចតូចតាច អាចឈរស្មើភាពគ្នាជាមួយនឹងប្រទេសខ្លាំង។ ក្នុងន័យនេះ ប្រព័ន្ធអនុវត្តច្បាប់ជាច្រើន ផ្តល់ផលប្រយោជន៍ដល់ប្រទេសទន់ខ្សោយច្រើនជាប្រទេសខ្លាំង ពីព្រោះថាប្រទេសខ្លាំងតែងតែមានមធ្យោបាយផ្សេងទៀត ក្នុងការការពារផលប្រយោជន៍របស់ពួកគេទោះបីគ្មានប្រព័ន្ធនៃការអនុវត្តច្បាប់ទាំងនោះក៏ដោយ។

ទោះជាយ៉ាងណាក៏ដោយ យើងអាចមើលឃើញយ៉ាងច្បាស់ថា សមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍ដែលចង់ទាញយកផលប្រយោជន៍ពីប្រព័ន្ធដោះស្រាយវិវាទនេះ គឺត្រូវជួបប្រទះនូវផលវិបាកគួរឲ្យកត់សម្គាល់។ ឧទាហរណ៍ ប្រទេសទាំងនោះ មិនមានធនធានមនុស្សដែលមានជំនាញខាងច្បាប់របស់អង្គការពាណិជ្ជកម្មពិភពលោក និងខាងនីតិវិធីដោះស្រាយវិវាទគ្រប់គ្រាន់ឡើយ។ កំនើនឡើងនូវយុត្តិសាស្ត្ររបស់គណៈវិនិច្ឆ័យ និងអង្គភាពឧទ្ធរណ៍ បានធ្វើឲ្យមន្ត្រីពាណិជ្ជកម្មជុំវិញពិភពលោក ពិបាកក្នុងការយល់ដឹងនូវច្បាប់ និងនីតិវិធីរបស់អង្គការពាណិជ្ជកម្មពិភពលោក។ បន្ថែមលើនេះទៀត វាមានការលំបាកចំពោះរដ្ឋបាលពាណិជ្ជកម្មតូចតាចក្នុងការចាត់បញ្ជូនមន្ត្រីរបស់ខ្លួនទៅចូលរួមក្នុងការដោះស្រាយវិវាទ ត្បិតថាពួកគេត្រូវប្រឈមនឹងការលំបាកក្នុងការតាមដានជាប់អំពីរាល់បញ្ហារបស់អង្គការ។ វិវាទមួយអាចធ្វើឲ្យមន្ត្រីរបស់ប្រទេសជាភាគីវិវាទជាប់រវល់រហូតដល់២ឆ្នាំ ដែលនេះវាផ្តល់ផលលំបាកដល់ប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងការធានាចំពោះការខូចខាតសេដ្ឋកិច្ចដែលលេចឡើងពីរបាំងពាណិជ្ជកម្មរបស់សមាជិកម្ខាងទៀត នៅក្នុងអំឡុងពេលនៃដំណើរការដោះស្រាយវិវាទ។ ប្រសិនបើរបាំងពាណិជ្ជកម្មនោះ ធ្វើឲ្យអន្តរាយដល់ឱកាសនាំចេញរបស់ប្រទេសកំពុងអភិវឌ្ឍ ហើយប្រសិនបើវាត្រូវបានរកឃើញថាវាមិនស្របទៅនឹងច្បាប់អង្គការ

ពាណិជ្ជកម្មពិភពលោក ការដកចេញនូវរបាំងពាណិជ្ជកម្មនោះ នឹងអាចកើតឡើងក្នុងរយៈពេល ២ ទៅ៣ឆ្នាំ បន្ទាប់ពីការប្ដឹងតវ៉ាឲ្យធ្វើការដោះស្រាយវិវាទតាមអង្គការ។

ដូច្នេះហើយ DSU បានផ្ដល់នូវវិធានពិសេសសម្រាប់អនុវត្ត ចំពោះជម្លោះដែលមានជាប់ពាក់ព័ន្ធនឹងសមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍។ ក្នុងនោះអង្គការ WTO ដោះស្រាយចំពោះតម្រូវការពិសេសរបស់ប្រទេសកំពុងអភិវឌ្ឍន៍ក្នុងវិធី ៣យ៉ាងដូចខាងក្រោម[83]៖

☞កិច្ចព្រមព្រៀង WTO មានបទបញ្ញត្តិពិសេសស្ដីពីប្រទេសកំពុងអភិវឌ្ឍន៍

☞គណៈកម្មាធិការពាណិជ្ជកម្ម និងអភិវឌ្ឍន៍ គឺជាអង្គភាពចំបងដែលផ្ដោតលើកិច្ចការនៅក្នុងផ្នែកនេះក្នុងអង្គការ WTO ព្រមទាំងការដោះស្រាយខ្លះៗផ្សេងទៀតទៅលើប្រធានបទដូចជាពាណិជ្ជកម្ម និងបំណុល ការផ្ទេរបច្ចេកវិទ្យា ជាដើម។

☞លេខាធិការដ្ឋានអង្គការ WTO ផ្ដល់នូវជំនួយបច្ចេកទេស (ការបណ្ដុះបណ្ដាលចំបងៗក្នុងផ្នែកជាច្រើន)សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍។

បើសង្កេតមើលទៅលើប្រព័ន្ធដោះស្រាយវិវាទរបស់ WTO ឃើញថា មានកំណត់អំពីការអនុគ្រោះពិសេស និងដាច់ដោយឡែកចំពោះប្រទេសកំពុងអភិវឌ្ឍន៍ ដែលជាប់ពាក់ព័ន្ធនៅក្នុងបញ្ហាជម្លោះ ដែលការអនុគ្រោះពិសេស និងដាច់ដោយឡែកនេះនៅក្នុង DSU មានទម្រង់ខុសគ្នាពីការអនុគ្រោះនៅក្នុងកិច្ចព្រមព្រៀងដែលពាក់ព័ន្ធផ្សេងទៀត ដែលមានវិធានសំខាន់ៗគ្រប់គ្រងលើការធ្វើពាណិជ្ជកម្មអន្តរជាតិ។ DSU បានទទួលស្គាល់នូវស្ថានភាពពិសេសរបស់សមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសមានការអភិវឌ្ឍន៍តិចតួច ដូចជាការផ្ដល់ជូននូវនីតិវិធីបន្ថែម ឬនីតិវិធីពិសេស និងជំនួយផ្នែកច្បាប់ដល់ប្រទេសទាំងនោះ។

ប្រទេសកំពុងអភិវឌ្ឍន៍ជ្រើសរើសនូវនីតិវិធីដែលមានភាពឆាប់រហ័ស ស្នើនូវកាលកំណត់ដែលមានរយៈពេលវែង ស្នើសុំជំនួយផ្នែកច្បាប់។ សមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោកត្រូវបានលើកទឹកចិត្តអោយផ្ដល់ការយកចិត្តទុកដាក់ និងពិចារណាជាពិសេសចំពោះស្ថានភាពរបស់សមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍។ មានវិធានមួយចំនួនត្រូវបានប្រើប្រាស់ជាប្រចាំ ប៉ុន្តែមួយ

[83] Dispute Settlement System Training Module [ មេរៀនបណ្ដុះបណ្ដាលស្ដីពីប្រព័ន្ធដោះស្រាយវិវាទ], https://www.wto.org/english/tratop_e/dispu_e/disp_settlement_cbt_e/signin_e.htm (ចូលអាន និងទាញយក ថ្ងៃទី 5 ឧសភា 2015)។

ចំនួនទៀតមិនទាន់បានអនុវត្តនូវវិធានពិសេសទាំងនោះនៅឡើយទេ។ មានការរិះគន់ជាទូទៅមួយថា វិធានទាំងនេះមិនមានលក្ខណៈជាក់លាក់ច្បាស់នោះទេ។

### ២.៥.១.១. ការអនុគ្រោះពិសេស និងដាច់ដោយឡែកនៅក្នុងការប្រឹក្សា

នៅក្នុងពេលនៃការប្រឹក្សា សមាជិកត្រូវយកចិត្តទុកដាក់ពិសេសចំពោះបញ្ហាជាក់លាក់ និងផលប្រយោជន៍របស់សមាជិកដែលជាប្រទេសកំពុងអភិវឌ្ឍ។[84] ប្រសិនបើកម្មវត្ថុនៃការប្រឹក្សាគឺជាវិធានរបស់សមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍ សមាជិកអាចធ្វើការព្រមព្រៀង ក្នុងការបន្ថែមរយៈពេលសម្រាប់ការប្រឹក្សាលើសពីរយៈពេលធម្មតា។ ប្រសិនបើនៅចុងបញ្ចប់នៃអំឡុងពេលប្រឹក្សាភាគីមិនអាចព្រមព្រៀងគ្នាបិទបញ្ចប់ការប្រឹក្សានោះទេ ប្រធានអង្គភាពដោះស្រាយវិវាទ អាចបន្ថែមរយៈពេលសម្រាប់ការប្រឹក្សាបន្ថែមទៀត។[85]

### ២.៥.១.២. ការអនុគ្រោះពិសេស និងដាច់ដោយឡែកនៅក្នុងដំណាក់កាលគណៈវិនិច្ឆ័យ

ការអនុគ្រោះពិសេសនិងដាច់ដោយឡែក ក៏មានផងដែរនៅក្នុងដំណាក់កាលគណៈវិនិច្ឆ័យ នៅពេលដែលវិវាទរវាងសមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍ តាមសំណើររបស់ប្រទេសកំពុងអភិវឌ្ឍន៍ គណៈវិនិច្ឆ័យត្រូវតែមានរួមបញ្ចូលយ៉ាងហោចណាស់សមាសភាពគណៈវិនិច្ឆ័យម្នាក់ដែលមកពីសមាជិកជាប្រទេសកំពុងអភិវឌ្ឍន៍។[86]

ប្រសិនបើប្រទេសកំពុងអភិវឌ្ឍន៍ជាចុងចម្លើយ គណៈវិនិច្ឆ័យត្រូវផ្តល់នូវពេលវេលាគ្រប់គ្រាន់ដើម្បីអោយចុងចម្លើយ ធ្វើការរៀបចំ និងបង្ហាញការការពាររបស់ខ្លួន ប៉ុន្តែមិនត្រូវប៉ះពាល់ដល់រយៈពេលជារួមសម្រាប់គណៈវិនិច្ឆ័យ ក្នុងការបិទបញ្ចប់នូវនីតិវិធីដោះស្រាយវិវាទក្នុងដំណាក់កាលគណៈវិនិច្ឆ័យនោះទេ។[87]

នៅពេលដែលប្រទេសកំពុងអភិវឌ្ឍន៍ជាភាគីនៃវិវាទ ហើយលើកឡើងពីវិធានស្តីពីការអនុគ្រោះពិសេស នោះគណៈវិនិច្ឆ័យត្រូវចង្អុលបង្ហាញឲ្យជាក់លាក់នូវទម្រង់ដែលវិធានទាំងនេះត្រូវបានយកមកពិចារណា។[88] នេះមានគោលបំណងដើម្បីបង្កើតឲ្យមានភាពច្បាស់លាស់អំពី

---

[84] DSU, 1995, មាត្រា 4 ចំណុច 10។

[85] DSU, 1995, មាត្រា 12 ចំណុច 10។

[86] DSU, 1995, មាត្រា 8 ចំណុច 10។

[87] DSU, 1995, មាត្រា 12 ចំណុច 10។

[88] DSU, 1995, មាត្រា 12 ចំណុច 11។

ប្រសិទ្ធិភាពនៃវិធានទាំងនេះនៅក្នុងរឿងក្តីណាមួយ និងដើម្បីបង្ហាញថា វិធានទាំងនេះពិតជាត្រូវបានអនុវត្ត។

### ២.៥.១.៣. ការអនុគ្រោះពិសេស និងដាច់ដោយឡែកនៅក្នុងដំណាក់កាលអនុវត្ត

នៅដំណាក់កាលអនុវត្ត DSU បានកំណត់ថា ត្រូវមានការយកចិត្តទុកដាក់ជាពិសេសលើបញ្ហាដែលប៉ះពាល់ដល់ ផលប្រយោជន៍របស់ប្រទេសកំពុងអភិវឌ្ឍន៍។[89] បទបញ្ញត្តិនេះត្រូវបានអនុវត្តជាញឹកញាប់ដោយមជ្ឍត្តករ នៅក្នុងការកំណត់អំពីអំឡុងពេលសមរម្យសម្រាប់ការអនុវត្ត។ មជ្ឍត្តករម្នាក់ផ្តល់រយៈពេលបន្ថែម៦ខែសម្រាប់ការអនុវត្តនៅក្នុងករណីរឿងក្តីពិសេស។[90]

នៅក្នុងក្របខណ្ឌនៃការណែនាំអំពីការអនុវត្ត អង្គភាពដោះស្រាយវិវាទ ត្រូវពិចារណាសកម្មភាពបន្ថែម និងសមស្របដែលខ្លួនត្រូវធ្វើបន្ថែមទៅលើការធ្វើអោយស្របតាម និងឋានៈរបស់របាយការណ៍ ប្រសិនបើប្រទេសកំពុងអភិវឌ្ឍន៍លើកឡើងអំពីបញ្ហានេះ។ នៅក្នុងការពិចារណាអំពីវិធានការសមស្របនៅក្នុងរឿងក្តីដែលប្តឹងមកដោយប្រទេសកំពុងអភិវឌ្ឍន៍ អង្គភាពដោះស្រាយវិវាទត្រូវពិចារណាមិនត្រឹមតែទំហំពាណិជ្ជកម្មនៃវិធានដែលចោទជាបញ្ហាទេ តែក៏ត្រូវពិចារណាអំពីផលប៉ះពាល់របស់វាលើសេដ្ឋកិច្ចរបស់ប្រទេសកំពុងអភិវឌ្ឍន៍ដែលពាក់ព័ន្ធដែរ។[91]

ប្រសិនបើប្រទេសកំពុងអភិវឌ្ឍន៍ប្តឹងប្រឆាំងនឹងប្រទេសអភិវឌ្ឍន៍ ភាគីដើមបណ្តឹងមានសិទ្ធិសម្រេចធ្វើការអះអាងនូវនីតិវិធីពន្លឿននៃសេចក្តីសម្រេចចិត្តចុះថ្ងៃទី ៥ ខែ មេសា ឆ្នាំ ១៩៦៦ បន្ថែមលើបទបញ្ញត្តិនៃមាត្រា ៤ ៥ ៦ និង ១២ នៃ DSU។ វិធាន និងនីតិវិធីនៃ សេចក្តីសម្រេចឆ្នាំ ១៩៦៦ បានបង្ហាញពីភាពខុសគ្នានិងវិធាន និងនីតិវិធីដែលពាក់ព័ន្ធក្នុងមាត្រា ៤ ៥ ៦ និង ១២ នៃ DSU។

ទីមួយ សេចក្តីសម្រេចនេះបានផ្តល់ថា អគ្គនាយកអាចប្រើប្រាស់ Good office របស់ខ្លួន និងធ្វើការប្រឹក្សាតាមសំណើរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ជាមួយនឹងទស្សនៈនៃការជួយសម្របសម្រួលក្នុងការរកដំណោះស្រាយវិវាទ ដែលភាគីមិនអាចស្វែងរកបានដំណោះស្រាយនៅក្នុងការប្រឹក្សារវាងភាគី។ ទីពីរ ប្រសិនបើការប្រឹក្សាដែលធ្វើដោយអគ្គនាយកនេះ មិនអាចនាំមកនូវដំណោះស្រាយដែលមានការពេញចិត្តទាំងសងខាង ក្នុងអំឡុងពេល២ខែ អគ្គនាយកដាក់ជូននូវរបាយការណ៍សកម្មភាពរបស់ខ្លួន តបតាមសំណើរបស់ភាគីណាមួយ។ បន្ទាប់មកអង្គភាពដោះ

[89] DSU, 1995, មាត្រា 21 ចំណុច 2។

[90] DSU, 1995, មាត្រា 21 ចំណុច 2។

[91] DSU, 1995, មាត្រា 21 ចំណុច 8។

ស្រាយវិវាទបង្កើតនូវគណៈវិនិច្ឆ័យដែលមានការយល់ព្រមពីសំណាក់ភាគី។ ទីបី គណៈវិនិច្ឆ័យត្រូវគិតពិចារណាលើកាលៈទេសៈ និងការពិចារណាទាំងអស់ដែលពាក់ព័ន្ធនឹងវិធានដែលត្រូវបានតវ៉ាព្រមទាំងផលប៉ះពាល់របស់វាលើពាណិជ្ជកម្ម និងការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់សមាជិកដែលរងផលប៉ះពាល់។ ទីបួន សេចក្តីសម្រេចផ្តល់ត្រឹមរយៈពេល ៦០ថ្ងៃ សម្រាប់គណៈវិនិច្ឆ័យក្នុងការដាក់ជូននូវការរកឃើញរបស់ខ្លួន គិតចាប់ពីកាលបរិច្ឆេទដែលបញ្ហាត្រូវបានដាក់ជូនមកគណៈវិនិច្ឆ័យ។ ករណីដែលគណៈវិនិច្ឆ័យពិចារណាឃើញថា រយៈពេលនេះមិនគ្រប់គ្រាន់ គណៈវិនិច្ឆ័យអាចពន្យាពេលដោយមានការព្រមព្រៀងពីភាគីដើមបណ្តឹង។ រយៈពេលនៃសេចក្តីសម្រេច ត្រូវបានអនុវត្តម្តងគត់នៅក្នុង GATT 1947 ក៏ប៉ុន្តែមិនទាន់ត្រូវបានអនុវត្តនៅក្នុង WTO នោះទេ។ នៅក្នុងអនុវត្តប្រទេសកំពុងអភិវឌ្ឍន៍ជ្រើសយកការមានពេលវេលាច្រើន ដើម្បីរៀបចំនូវសំណុំឯកសាររបស់ខ្លួន។ ទោះជាយ៉ាងណាក៏ដោយ ប្រទេសកំពុងអភិវឌ្ឍន៍ជាញឹកញាប់ទទូចអោយគណៈវិនិច្ឆ័យគោរពនូវរយៈពេលជារួមដើម្បីបញ្ចប់ដំណើរការនីតិវិធី។

ក្រៅពីនេះ អង្គការ WTO បានព្យាយាមជួយដល់ប្រទេសកំពុងអភិវឌ្ឍន៍លើផ្នែកផ្សេងទៀតផងដែរ ដូចជាការផ្តល់ជំនួយផ្នែកច្បាប់។ ក្នុងនោះលេខាធិការដ្ឋាន WTO មាននូវអ្នកផ្តល់ប្រឹក្សាផ្នែកច្បាប់ពិសេសសម្រាប់ជួយ ប្រទេសកំពុងអភិវឌ្ឍន៍នៅក្នុងបញ្ហាវិវាទនានានៅក្នុងអង្គការ WTO សម្រាប់ផ្តល់ឲ្យប្រទេសកំពុងអភិវឌ្ឍន៍ទាំងនោះនូវការប្រឹក្សាផ្នែកច្បាប់។ សេវាកម្មនេះត្រូវបានផ្តល់ជូនដោយវិទ្យាស្ថានបណ្តុះបណ្តាល និងសហប្រតិបត្តិការបច្ចេកទេស របស់អង្គការពាណិជ្ជកម្មពិភពលោក។ បន្ថែមលើនេះទៀត នៅក្នុងឆ្នាំ ២០០១ រដ្ឋាភិបាលនៃអង្គការ WTO ចំនួន ៣២ បានបង្កើតនូវមជ្ឈមណ្ឌលផ្តល់ប្រឹក្សាលើច្បាប់អង្គការ WTO មួយ។ សមាជិករបស់មជ្ឈមណ្ឌលនេះ រួមមានប្រទេសដែលរួមចំណែកក្នុងការផ្តល់មូលនិធិ និងប្រទេសដែលទទួលការប្រឹក្សាផ្នែកច្បាប់។ គ្រប់ប្រទេសអភិវឌ្ឍន៍តិចតួចទាំងអស់មានសិទ្ធិក្នុងការស្នើសុំការប្រឹក្សាជាស្វ័យប្រវត្តិ។ ប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងទៀត ត្រូវបង់ចំណាយដើម្បីទទួលបាននូវការប្រឹក្សា។

### ២.៥.២. ប្រទេសមានការអភិវឌ្ឍន៍តិចតួចពាក់ព័ន្ធក្នុងវិវាទ

ប្រទេសមានការអភិវឌ្ឍន៍តិចតួចទទួលបានការយកចិត្តទុកដាក់បន្ថែមទៀតនៅក្នុង WTO។ ចាប់តាំងពីកិច្ចព្រមព្រៀងអ៊ុយរ៉ាហ្គាយ បានចុះហត្ថលេខានៅឆ្នាំ ១៩៩៤ មក មានសេចក្តីសម្រេចជាច្រើនដែលផ្តល់អត្ថប្រយោជន៍ដល់ប្រទេសអភិវឌ្ឍន៍តិចតួច។

វិធាននៃប្រព្រឹត្តកម្មពិសេស និងផ្សេងគ្នា ដែលអនុវត្តចំពោះប្រទេសកំពុងអភិវឌ្ឍ ក៏អនុវត្តចំពោះប្រទេសដែលមានការអភិវឌ្ឍតិចតួចដែរ។ បន្ថែមលើនេះទៀត DSU បានកំណត់វិធាន

ពិសេសមួយចំនួនដែលអនុវត្តចំពោះតែប្រទេសដែលមានការអភិវឌ្ឍតិចតួច។ នៅពេលដែលមានសមាជិកជាប្រទេសដែលមានការអភិវឌ្ឍតិចតួចជាប់ពាក់ព័ន្ធនឹងវិវាទ ការពិចារណាពិសេសត្រូវបានផ្តល់ចំពោះស្ថានភាពពិសេសនៃសមាជិកនោះគ្រប់ដំណាក់កាលទាំងអស់នៃវិវាទ។ សមាជិកត្រូវមានការបន្ធូរបន្ថយ ចំពោះការដាក់ពាក្យបណ្តឹងប្រឆាំងនឹងប្រទេសដែលមានការអភិវឌ្ឍតិចតួច និងចំពោះការទាមទារឲ្យមានសំណងការខូចខាត និងការព្យួរកាតព្វកិច្ចរបស់ប្រទេសមានការអភិវឌ្ឍតិចតួចដែលចាញ់ក្តី។ DSU ក៏មានកំណត់មុនជាពិសេសពាក់ព័ន្ធនឹង Good Office ការសម្រុះសម្រួល និងសន្ទានកម្មផងដែរ ចំពោះវិវាទដែលជាប់ពាក់ព័ន្ធនឹងប្រទេសដែលមានការអភិវឌ្ឍតិចតួច។ នៅពេលដែលការប្រឹក្សាមិនមានលទ្ធផលជាផ្លែផ្កា ក្នុងការស្វែងរកដំណោះស្រាយជាទីពេញចិត្ត អគ្គនាយក ឬប្រធានអង្គភាពដោះស្រាយវិវាទ ត្រូវផ្តល់នូវ Good Office ការសម្រុះសម្រួល និងសន្ទានកម្មតាមសំណើរប្រទេសដែលមានការអភិវឌ្ឍតិចតួច។ គោលបំណងគឺដើម្បីជួយដល់ភាគីក្នុងការដោះស្រាយវិវាទមុនពេលបង្កើតនូវគណៈវិនិច្ឆ័យ។

## ២.៦. ចំណុចខ្លាំង និងចំណុចខ្សោយរបស់ប្រព័ន្ធដោះស្រាយវិវាទ

ប្រព័ន្ធដោះស្រាយវិវាទនេះ មានទាំងភាពខ្លាំង និងភាពខ្សោយ។ ឧទាហរណ៍ បើគិតពីភាពខ្សោយ គឺការចំណាយពេលវេលាច្រើននៅក្នុងដំណើរការនៃការដោះស្រាយវិវាទ ដែលក្នុងអំឡុងពេលនេះ ដើមបណ្តឹងនឹងនៅបន្តទទួលរងការខូចខាតខាងសេដ្ឋកិច្ចបន្តទៀត ប្រសិនបើវិធានច្បាប់ដែលរងការប្តឹងតវ៉ានោះ ពិតជាមិនស្របទៅនឹងអង្គការពាណិជ្ជកម្មពិភពលោក។ បន្ថែមលើនេះទៀត គ្មានវិធានណាមួយជាបណ្តោះអាសន្ន ដែលអាចធ្វើការការពារនូវផលប្រយោជន៍សេដ្ឋកិច្ច និងពាណិជ្ជកម្មសម្រាប់ដើមបណ្តឹងដែលឈ្នះក្តីដោយជោគជ័យ នៅក្នុងអំឡុងពេលនៃនីតិវិធីដោះស្រាយវិវាទ។ មួយវិញទៀត បន្ទាប់ពីបានជោគជ័យនៅក្នុងការដោះស្រាយវិវាទ ភាគីចាញ់ក្តីមានអំឡុងពេលសមរម្យមួយ ដើម្បីអនុវត្តតាមសេចក្តីសម្រេចដែលត្រូវបានអនុម័តដោយអង្គភាពដោះស្រាយវិវាទ ចំណែកភាគីដែលឈ្នះក្តីនឹងមិនទទួលបាននូវសំណងណាមួយសម្រាប់ការខូចខាតដែលទទួលរងក្នុងអំឡុងពេលនោះឡើយ។ ប្រការមួយទៀត ភាគីដែលឈ្នះក្តី ក៏មិនទទួលបាននូវសំណងណាមួយពីភាគីម្ខាងទៀត សម្រាប់ការចំណាយលើកិច្ចការច្បាប់នៅក្នុងដំណើរការដោះស្រាយវិវាទឡើយ។ នៅក្នុងករណីដែលភាគីចាញ់ក្តីមិនអនុវត្តតាមសេចក្តីសម្រេចវិញ មិនមែនសមាជិកដែលជាភាគីឈ្នះក្តីទាំងអស់ សុទ្ធតែមានសមត្ថភាពដូចគ្នាក្នុងការពឹងផ្អែកលើការព្យួរកាតព្វកិច្ចឡើយ។ ចុងក្រោយមានករណីមួយចំនួនដែលការព្យួរសម្បទាន ឬព្យួរកាតព្វកិច្ច មិនមានប្រសិទ្ធិភាពនៅក្នុងការធ្វើអោយមានការអនុវត្តនូវសេចក្តីសម្រេចពីសំណាក់ភាគីចាញ់ក្តី។

ផ្ទុយទៅវិញ ប្រសិនបើប្រៀបធៀបរវាងប្រព័ន្ធដោះស្រាយវិវាទរបស់អង្គការពាណិជ្ជកម្មពិភពលោក និងប្រព័ន្ធនៃការដោះស្រាយវិវាទរបស់GATT 1947 ពីមុន ឃើញថាប្រព័ន្ធដោះស្រាយវិវាទបច្ចុប្បន្នមានប្រសិទ្ធិភាពច្រើនជាង។ លើសពីនេះទៀត លក្ខណៈពាក់កណ្តាលតុលាការ និងពាក់កណ្តាលស្វ័យប្រវត្តិនៃការអនុម័តសេចក្តីសម្រេចនានា អាចធ្វើឲ្យប្រព័ន្ធនេះធ្វើការដោះស្រាយរឿងក្តីដែលលំបាកៗបានច្រើន ហើយក៏បានផ្តល់នូវការធានាសម្រាប់សមាជិកដែលចង់ការពារសិទ្ធិរបស់ពួកគេផងដែរ។ ប្រសិនបើប្រៀបធៀបជាមួយនឹងប្រព័ន្ធនៃការដោះស្រាយវិវាទពហុភាគីផ្សេងទៀតនៅក្នុងច្បាប់អន្តរជាតិ លក្ខណៈចាប់បង្ខំ និងយន្តការនៃការអនុវត្តរបស់ប្រព័ន្ធដោះស្រាយវិវាទរបស់អង្គការពាណិជ្ជកម្មពិភពលោកគឺលេចធ្លោជាងគេ។

# សេចក្តីសន្និដ្ឋាន

តាមរយៈការស្វែងយល់អំពីប្រព័ន្ធដោះស្រាយវិវាទពាណិជ្ជកម្មអន្តរជាតិ របស់អង្គការពាណិជ្ជកម្មពិភពលោក សង្កេតឃើញថាប្រព័ន្ធនេះជាចំណែកមួយនៃការបំពេញមុខងាររបស់អង្គការពាណិជ្ជកម្មពិភពលោកពាក់ព័ន្ធនឹងការជួយសម្របសម្រួល និងដោះស្រាយវិវាទដែលកើតមានរវាងប្រទេសជាសមាជិករបស់អង្គការ និងជួយធានាដល់ការអនុវត្តកិច្ចព្រមព្រៀងនានារបស់អង្គការរួមទាំងធានាបាននូវសុវត្ថិភាពនៃការធ្វើពាណិជ្ជកម្មជាអន្តរជាតិរបស់សមាជិក។ ដូចដែលបានបង្ហាញខាងលើ ប្រព័ន្ធដោះស្រាយវិវាទរបស់អង្គការ WTO ត្រូវបានបង្កើតឡើង ដើម្បីដោះស្រាយនូវបញ្ហាដែលជាចំណុចខ្វះចន្លោះរបស់ប្រព័ន្ធដោះស្រាយវិវាទ តាមកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្ម និងពន្ធគយ ដោយមានបញ្ចូលនៅចំណុចថ្មីមួយចំនួន ដែលធ្វើអោយប្រព័ន្ធដោះស្រាយវិវាទរបស់អង្គការ WTO បច្ចុប្បន្នមានភាពរឹងមាំ និងអាចជឿទុកចិត្តបានក្នុងការដោះស្រាយវិវាទជូនសមាជិករបស់អង្គការ ធានាយ៉ាងណាបំពេញឲ្យបាននូវមុខងារ និងគោលបំណងរបស់ប្រព័ន្ធដោះស្រាយវិវាទនេះ។ ជាមួយគ្នានេះដែរ ប្រព័ន្ធដោះស្រាយវិវាទរបស់អង្គការ WTO មានការចូលរួមពីសំណាក់ភាគីជាច្រើន រួមមានទាំងភាគីវិវាទ ភាគីទីបី អង្គភាពមួយចំនួនរបស់អង្គការពាណិជ្ជកម្មពិភពលោក បុគ្គលខាងក្រៅដូចជា មជ្ឈត្តករ និងអ្នកជំនាញជាដើម។

ការដោះស្រាយវិវាទពាណិជ្ជកម្មអន្តរជាតិ តាមរយៈប្រព័ន្ធដោះស្រាយវិវាទរបស់អង្គការ WTO មានទាំងលក្ខណៈការទូត និងលក្ខណៈជាប្រព័ន្ធយុត្តាធិការ ហើយមានដំណាក់កាលច្រើនដែលអាចផ្តល់លទ្ធភាពដល់សមាជិករបស់អង្គការ ប្រើប្រាស់សិទ្ធិ និងការពារផលប្រយោជន៍របស់ខ្លួន ក្នុងករណីដែលភាគីនៃវិវាទមានការមិនពេញចិត្តនូវដំណោះស្រាយវិវាទក្នុងដំណាក់កាលណាមួយ ឬមិនព្រមបញ្ចប់វិវាទរបស់ខ្លួននៅក្នុងដំណាក់កាលនោះ។ ក្នុងនោះដំណាក់កាលដំបូង គឺការប្រឹក្សារវាងភាគី ដែលដំណាក់កាលនេះផ្តល់លទ្ធភាពអោយភាគីនៃវិវាទធ្វើការចរចាជាមួយគ្នាទៅវិញទៅមក ដើម្បីស្វែងរកនូវដំណោះស្រាយដែលអាចទទួលយកបានដោយភាគីទាំងសងខាង។ ជាមួយគ្នានោះដែរ ក៏អាចមានការចូលរួមពីសំណាក់ភាគីទីបី និងបុគ្គលសំខាន់ណាមួយចូលរួមនៅក្នុងដំណើរការប្រឹក្សានេះ ដូចជា ការចូលរួមពីសំណាក់អគ្គនាយកអង្គការពាណិជ្ជកម្មពិភពលោកក្នុងការធ្វើនូវសកម្មភាព Good Office សន្ធានកម្ម និងការសម្រុះសម្រួលជាដើម។ ក្នុងករណីដែលភាគីជម្លោះមិនអាចស្វែងរកនូវដំណោះស្រាយនៅក្នុងដំណាក់កាលនៃការប្រឹក្សានេះទេ នោះភាគីអាចដាក់បណ្តឹងរបស់ខ្លួនដើម្បីដោះស្រាយក្នុងដំណាក់កាលមួយទៀត នៅគណៈវិនិច្ឆ័យ ដែលត្រូវបានដោះស្រាយដោយសមាសភាពគណៈវិនិច្ឆ័យអាជបាកចំនួន៥រូប ។ ការដោះស្រាយក្នុង

ដំណាក់កាលនេះ ត្រូវឆ្លងកាត់នីតិវិធីជាច្រើនដូចបានបង្ហាញពីខាងដើម ដែលមានលក្ខណៈស្រដៀងនឹងការដោះស្រាយវិវាទ នៅក្នុងប្រព័ន្ធយុត្តាធិការក្នុងស្រុកផងដែរ ប៉ុន្តែក៏នៅមានចំណុចជាច្រើនដែលធ្វើអោយមានលក្ខណៈខុសគ្នាផងដែរ។ ជាបន្ទាប់ប្រសិនបើ ភាគីនៃវិវាទនៅតែមិនពេញចិត្តនឹងដំណោះស្រាយដែលរកឃើញនៅដំណាក់កាលគណៈវិនិច្ឆ័យ ឬមិនព្រមបញ្ចប់វិវាទរបស់ខ្លួននៅដំណាក់កាលនេះទេ ប្រព័ន្ធនេះផ្តល់នូវលទ្ធភាពមួយទៀតសម្រាប់ភាគី ប្រើប្រាស់នូវសិទ្ធិ និងការពារផលប្រយោជន៍របស់ខ្លួនអោយអស់លទ្ធភាព នោះគឺការប្តឹងឧទ្ធរណ៍ទៅកាន់អង្គភាពឧទ្ធរណ៍របស់អង្គការ WTO។ ការដោះស្រាយវិវាទនៅអង្គភាពឧទ្ធរណ៍ គឺជាដំណាក់កាលចុងក្រោយ ដែលភាគីមិនអាចប្តឹងតវ៉ាទៀតនោះទេ។ អ្វីដែលគួរអោយកត់សម្គាល់នោះគឺថាទោះបីជា បញ្ហាវិវាទត្រូវបានដោះស្រាយដោយគណៈវិនិច្ឆ័យ និងអង្គភាពឧទ្ធរណ៍ក៏ដោយ ក៏ដំណោះស្រាយឬសេចក្តីសម្រេចទាំងនោះ នឹងមានអានុភាពចាប់បង្ខំអោយភាគីអនុវត្ត លុះណាតែត្រូវបានទទួលការអនុម័តពីអង្គភាពដោះស្រាយវិវាទ។

ទោះបីជាប្រព័ន្ធដោះស្រាយវិវាទនេះ នៅមានចំណុចខ្សោយមួយចំនួនក៏ដោយ ក៏យើងសង្កេតឃើញថា តាមរយៈប្រព័ន្ធដោះស្រាយវិវាទពាណិជ្ជកម្មរបស់អង្គការពាណិជ្ជកម្មពិភពលោក ការធ្វើ ពាណិជ្ជកម្មជាអន្តរជាតិក្នុងក្របខណ្ឌអង្គការ WTO មានភាពល្អប្រសើរឡើង ដោយហេតុថាប្រព័ន្ធនេះបានជួយបង្ការនូវការខូចខាតប្រយោជន៍ ដែលកើតចេញពីវិវាទពាណិជ្ជកម្មអន្តរជាតិដែលមិនត្រូវបានដោះស្រាយ និងជួយសម្រួលដល់បញ្ហាអតុល្យភាពរវាងប្រទេសខ្លាំង និងប្រទេសខ្សោយ ដោយតម្រូវអោយប្រទេសទាំងនេះដាក់វិវាទរបស់ខ្លួនចូលមកអង្គការដើម្បីដោះស្រាយ ហើយមិនអនុញ្ញាតអោយរដ្ឋជាសមាជិកធ្វើការដោះស្រាយវិវាទ ដោយសកម្មភាពឯកតោភាគីឡើយ។ ប្រការ មួយទៀត ការដោះស្រាយវិវាទដោយឈរលើមូលដ្ឋាននៃច្បាប់ ជាជាងអំណាចមកធ្វើការកំណត់ពីលទ្ធផលរបស់ប្រព័ន្ធនេះ និងការផ្តល់ការអនុគ្រោះច្រើនដល់ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសមានការអភិវឌ្ឍន៍តិចតួចជាច្រើនបានចូលជាសមាជិករបស់អង្គការ ដែលការណ៍នេះជំរុញអោយសកម្មភាពពាណិជ្ជកម្មអន្តរជាតិកាន់តែមានសន្ទុះ ដែលជាប្រការល្អសម្រាប់សេដ្ឋកិច្ចពិភពលោក។

ដូចនេះ ប្រទេសជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ដែលមានកម្ពុជាផងដែរនោះ គប្បីត្រូវសិក្សាស្វែងយល់អំពីប្រព័ន្ធដោះស្រាយវិវាទនេះ ព្រមទាំងក្តាប់អោយបាននូវគ្រប់ការវិវឌ្ឍន៍របស់អង្គការ ការកើតមាននូវលិខិតបទដ្ឋានគតិយុត្តថ្មីៗ បន្ថែមពីលើការជួយជ្រុមជ្រែងពីសំណាក់អង្គការ ដើម្បីអោយកម្ពុជាអាចទាញយកនូវផលប្រយោជន៍បានច្រើនពីការចូលជាសមាជិករបស់

អង្គការ និងអាចអោយកម្ពុជាការពារនូវសិទ្ធិ ព្រមទាំងផលប្រយោជន៍របស់ខ្លួននៅក្នុងកិច្ចការពាណិជ្ជកម្មអន្តរជាតិជាមួយបណ្តាប្រទេសជាសមាជិកដទៃទៀត។ ជាមួយគ្នានេះដែរ ដើម្បីឲ្យកម្ពុជាអាចធ្វើដូច្នោះបាន វាទាមទារឲ្យរដ្ឋាភិបាលយកចិត្តទុកដាក់ក្នុងការជួយជម្រុញឲ្យមន្ត្រីទទួលបន្ទុកកិច្ចការពាណិជ្ជកម្ម និងកិច្ចការអន្តរជាតិ ស្វែងយលឲ្យបានច្រើនពាក់ព័ន្ធនឹងបញ្ហានេះ ព្រមទាំងជម្រុញឲ្យមានការសិក្សាយ៉ាងទូលំទូលាយលើវិស័យនេះ ក្នុងគ្រឹះស្ថានសិក្សា សាធារណៈ និងឯកជននានា។ ចំណែកឯកូនខ្មែរដែលជាអ្នកសិក្សា ក៏ត្រូវមានឆន្ទៈ និងស្វ័យសិក្សាស្រាវជ្រាវបន្ថែមដោយខ្លួនឯងផងដែរលើបញ្ហាទាំងអស់នេះ សម្រាប់ជាចំណេះដឹងផ្ទាល់ខ្លួន ក្នុងបញ្ហាអន្តរជាតិ ព្រោះថាប្រទេសកម្ពុជាកំពុងតែបោះជំហានយ៉ាងខ្លាំងចូលទៅក្នុងឆាកអន្តរជាតិ។

# អនុសាសន៍

យោងតាមការសិក្សាលើប្រព័ន្ធដោះស្រាយវិវាទពាណិជ្ជកម្មអន្តរជាតិ របស់អង្គការ WTO ខាងលើ យើងសង្កេតឃើញថា ប្រព័ន្ធដោះស្រាយវិវាទនេះ មានលក្ខណៈល្អប្រសើរច្រើន បើប្រៀបធៀបទៅនឹងប្រព័ន្ធដោះស្រាយវិវាទពាណិជ្ជកម្មតាមកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្ម និងពន្ធគយ ឆ្នាំ ១៩៤៧ និងប្រព័ន្ធដោះស្រាយវិវាទអន្តរជាតិមួយចំនួនទៀត។ ប៉ុន្តែយ៉ាងណាក៏ដោយ ដូចដែលបានបង្ហាញពីខាងលើស្រាប់ ប្រព័ន្ធដោះស្រាយវិវាទនេះ នៅតែមានចំណុចខ្វះចន្លោះ និងចំណុចខ្សោយមួយចំនួន ពាក់ព័ន្ធទៅនឹងរយៈពេលនៃការដោះស្រាយវិវាទ ការមិនមាននូវចំណាត់ការបណ្តោះអាសន្នណាមួយ ដើម្បីការពារផលប្រយោជន៍របស់ភាគីក្នុងអំឡុងពេលនៃការដោះស្រាយវិវាទ ការមិនទទួលបាននូវសំណងចំពោះការចំណាយផ្សេងៗក្នុងដំណើរការបណ្តឹង បន្ទាប់ពីឈ្នះក្តី ព្រមទាំងភាពដែលអាចប្រឈមនូវការបន្តទទួលរងផលប៉ះពាល់ ទោះបីមានសេចក្តីសម្រេចថាខ្លួនឈ្នះក្តីហើយក៏ដោយ។ ឆ្លើយតបនឹងបញ្ហា អង្គការពាណិជ្ជកម្មពិភពលោកគួរពិចារណា យកនូវយន្តការមួយចំនួនដែលប្រើសម្រាប់ការដោះស្រាយវិវាទឯកជន មកអនុវត្តនៅក្នុងប្រព័ន្ធដោះស្រាយវិវាទនេះ ដែលមានដូចខាងក្រោម៖

ប្រព័ន្ធនេះគួរយកយន្តការនៃការប្រើពេលវេលាតិចក្នុងការដោះស្រាយវិវាទពាណិជ្ជកម្ម នៅក្នុងតុលាការមជ្ឈត្តកម្មមកប្រើ ដើម្បីកាត់បន្ថយនូវការអូសបន្លាយពេលវេលាច្រើនក្នុងការដោះស្រាយវិវាទក្នុងអង្គការពាណិជ្ជកម្មពិភពលោក ឬក៏ព្យាយាមបង្រួញពេលវេលានៃដំណាក់កាលនីមួយៗនៃការដោះស្រាយអោយខ្លីជាងមុន ដូចជាពាក់ព័ន្ធនឹងការរៀបចំសមាសភាពគណៈវិនិច្ឆ័យ និងការរៀបចំនូវសេចក្តីសម្រេចជាដើម ព្រោះថាក្នុងអំឡុងពេលនៃការដោះស្រាយ ភាគីដែលនៅតែបន្តទទួលផលប៉ះពាល់ពីបញ្ហាដែលដាក់ចូលដោះស្រាយ។

ជាមួយគ្នានេះ ដើម្បីជៀសវាងការបន្តរងផលប៉ះពាល់ដូចបានលើកឡើងខាងលើ ប្រព័ន្ធនេះ គួរបង្កើតអោយមាននូវយន្តការណាមួយ ដែលអនុញ្ញាតអោយភាគីរងផលប៉ះពាល់ ឬមានការព្រួយបារម្ភអំពីការខូចខាត អាចស្នើសុំនូវវិធានការណាមួយជាបណ្តោះអាសន្ន ដើម្បីការពារផលប្រយោជន៍របស់ខ្លួន។ ក្នុងនោះប្រព័ន្ធនេះអាចស្រង់យកគំនិតពីការចេញដីកាចាត់ចែងរក្សាការពារដែលមានប្រើប្រាស់នៅក្នុងប្រព័ន្ធយុត្តាធិការក្នុងស្រុក ពាក់ព័ន្ធនឹងការដោះស្រាយវិវាទរដ្ឋប្បវេណី ដើម្បីការពារផលប្រយោជន៍ភាគីជាបណ្តោះអាសន្ន។

មួយវិញទៀត ឆ្លើយតបនឹងបញ្ហានៃការមិនទទួលបាននូវសំណងចំពោះការចំណាយផ្សេងៗក្នុងដំណើរការបណ្តឹងក្នុងអង្គការ ប្រព័ន្ធដោះស្រាយវិវាទនេះ អាចស្រង់យកនីតិវិធីដែលបានប្រើ

ក្នុងប្រព័ន្ធយុត្តាធិការក្នុងស្រុកលើបណ្តឹងរដ្ឋប្បវេណី ដែលតម្រូវអោយភាគីចាញ់ក្តី ជាអ្នកទទួលបន្ទុករាល់សោហ៊ុយចំណាយផ្សេងៗនៅក្នុងដំណើរការនីតិវិធី។ តាមរយៈនេះ ប្រព័ន្ធដោះស្រាយវិវាទរបស់អង្គការ WTO អាចស្វែងរកនូវលទ្ធភាពណាមួយដើម្បីជួយដោះស្រាយជូនភាគីវិវាទ ពាក់ព័ន្ធនឹងការចំណាយនៅក្នុងនីតិវិធីបណ្តឹង។

ចុងក្រោយគឺពាក់ព័ន្ធនឹងភាពដែលអាចប្រឈមនូវការបន្តការខូចខាត ឬរងផលប៉ះពាល់ ទោះបីជាមានសេចក្តីសម្រេចអំពីការឈ្នះក្តីហើយក៏ដោយ។ ដូចដែលបានលើកឡើងនៅក្នុងកិច្ចការខាងលើ បន្ទាប់ពីមានសេចក្តីសម្រេចអំពីការឈ្នះក្តីហើយ ភាគីចាញ់ក្តីត្រូវទទួលបាននូវពេលវេលាសមរម្យដើម្បីធ្វើការកែប្រែនូវវិធានរបស់ខ្លួនដែលរំលោភបំពានលើកិច្ចព្រមព្រៀង WTO ឲ្យវិលមកស្របតាមកិច្ចព្រមព្រៀងវិញ ឬក៏អាចមានករណីដែលភាគីចាញ់ក្តីមិនព្រមអនុវត្តតាមសេចក្តីសម្រេច ដែលទាមទារអោយភាគីឈ្នះក្តីត្រូវធ្វើការតវ៉ាទៅកាន់អង្គភាពដោះស្រាយវិវាទអំពីការមិនអនុវត្តតាមសេចក្តីសម្រេចនេះ។ អំឡុងពេលនេះភាគីឈ្នះក្តីអាចថានឹងបន្តរងផលប៉ះពាល់ ពីវិធានដែលតម្រូវឲ្យដកចេញ ឬកែតម្រូវនោះ។ ដូច្នេះ ប្រព័ន្ធនេះគួរមានជាយន្តការមួយ ដែលតម្រូវឲ្យភាគីចាញ់ក្តីធ្វើការទូទាត់នូវការសំណងការខូចខាត ដែលភាគីឈ្នះក្តីអាចទទួលរងក្នុងអំឡុងពេលនោះ។

ដូច្នេះហើយ ប្រទេសជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសមានការអភិវឌ្ឍន៍តិចតួច ដែលជាញឹកញាប់ត្រូវបានរំលោភបំពានពីប្រទេសអភិវឌ្ឍន៍ ត្រូវលើកឡើងពីបញ្ហាទាំងអស់នេះទៅកាន់អង្គការ ដើម្បីឲ្យអង្គការស្វែងរកនូវយន្តការណាមួយ ឆ្លើយតបនឹងបញ្ហានេះ ក្នុងគោលដៅកាត់បន្ថយនូវចំណុចខ្វះខាតរបស់ប្រព័ន្ធដោះស្រាយវិវាទនេះនិងក្នុងគោលដៅធានាសិទ្ធិនិងផលប្រយោជន៍របស់គ្រប់សមាជិកទាំងអស់របស់អង្គការ។

# ឯកសារយោង

## លិខិតបទដ្ឋានគតិយុត្តអន្តរជាតិ


-កិច្ចព្រមព្រៀងបង្កើតអង្គការពាណិជ្ជកម្មពិភពលោក, 1995។

-Understanding on rules and procedures governing the settlement of dispute or dispute settlement understanding (DSU) [ការស្វែងយល់ពីវិធាន និងនីតិវិធីគ្រប់គ្រងលើការដោះស្រាយវិវាទ ឬការស្វែងយល់ពីការដោះស្រាយវិវាទ], 1995 ។

-Appendix 3 of Dispute settlement understanding: working procedure [ឧបសម្ព័ន្ធ៣ នៃ ការស្វែងយល់ពីការដោះស្រាយវិវាទ DSU: នីតិវិធីការងារ], 1995។

-កិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្ម និងពន្ធគយ GATT, 1947។


## សៀវភៅ


-កៅ សីហា. *WTO និងកម្ពុជា*. ភ្នំពេញ។


## ឯកសារក្នុងអ៊ីនធឺណេត


-*Dispute Settlement System Training Module* [មេរៀនបណ្តុះបណ្តាលស្តីពីប្រព័ន្ធដោះស្រាយវិវាទ], https://www.wto.org/english/tratop_e/dispu_e/disp_settlement_cbt_e/signin_e.htm

-Shedd, Daniel T., Murrill, Brandon J. និងSmith, Jane M. November 26, 2012. *Dispute settlement in the World Trade Organization: An overview* [ការដោះស្រាយវិវាទនៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក: ទិដ្ឋភាពទូទៅ]. USA: Congressional Research Service. https://www.fas.org/sgp/crs/misc/RS20088.pdf ។

-*Understanding The WTO: Settling Disputes, A unique contribution* [ការស្វែងយល់ពីអង្គការ WTO : ការដោះស្រាយវិវាទ, ការរួមចំណែកពិសេស], https://www.wto.org/english/thewto_e/ whatis_e/tif_e/disp1_e.htm ។

-*Chapter 3: Settling dispute* [ជំពូកទី 3: ការដោះស្រាយវិវាទ], https://www.wto.org/english/thewto_e/whatis_e/tif_e/utw_chap3_e.pdf ។

-*Dispute settlement: appellate procedures* [ការដោះស្រាយវិវាទៈ នីតិវិធីបណ្ដឹងឧទ្ធរណ៍], https://www.wto.org/english/tratop_e/dispu_e/ab_procedures_e.htm ។